ធនាគារជាតិនៃកម្ពុជា
ប្រាក់រៀល ស្ថិរភាព អភិវឌ្ឍន៍

# របាយការណ៍ប្រចាំឆ្នាំ២០២១
# ស្តីពី ប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជា



ខែមិថុនា ឆ្នាំ២០២១

# អបអរសាទរ

ទេសាភិបាលឆ្នើមប្រចាំឆ្នាំ២០២១
នៅតំបន់អាស៊ីប៉ាស៊ីហ្វិក



The Banker

CENTRAL BANKER OF THE YEAR
AWARDS 2021



# អារម្ភកថា

ប្រព័ន្ធទូទាត់សងប្រាក់ ជាហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុកន្លែងមួយដែលមានតួនាទីជាសារវន្ត ក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រព័ន្ធទូទាត់មានការរីកចម្រើនគួរឱ្យកត់សម្គាល់ និងបានវិវត្តទៅរកការទូទាត់ឌីជីថល ឆ្លើយតបទៅនឹងការផ្លាស់ប្តូរឥរិយាបថរបស់អ្នកប្រើប្រាស់ដែលមានតម្រូវការលើសេវានិងឧបករណ៍ទូទាត់ថ្មីៗប្រកបដោយនវានុវត្តន៍ ផ្តល់ភាពងាយស្រួល សុវត្ថិភាព និងចំណាយទាប។ ទាំងនេះជាលទ្ធផលនៃការអភិវឌ្ឍយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យា ជាពិសេសក្នុងវិស័យហិរញ្ញវត្ថុដែលត្រូវបានគេស្គាល់ថាបច្ចេកវិទ្យាហិរញ្ញវត្ថុ។ បច្ចុប្បន្នបច្ចេកវិទ្យាហិរញ្ញវត្ថុត្រូវបានគេមើលឃើញថាជាកត្តាជំរុញចម្បងក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុដើម្បីគាំទ្រដល់ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុនិងការអនុវត្តគោលនយោបាយសេដ្ឋកិច្ចឌីជីថលរបស់រាជរដ្ឋាភិបាល។ ជាក់ស្តែង បច្ចេកវិទ្យាទាំងនេះត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយក្នុងវិស័យធនាគារដើម្បីបង្កើតនូវផលិតផលថ្មីៗប្រកបដោយនវានុវត្តន៍ និងបានផ្លាស់ប្តូររបៀបនៃការផ្តល់សេវាហិរញ្ញវត្ថុតាមមធ្យោបាយឌីជីថល ជាពិសេសសេវាទូទាត់ និងផ្ទេរប្រាក់ត្រូវបានគេសង្កេតឃើញថាកំពុងមានការអភិវឌ្ឍយ៉ាងឆាប់រហ័ស។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានដាក់ឱ្យប្រើប្រាស់សេវាទូទាត់និងផ្ទេរប្រាក់ឌីជីថលថ្មីៗ ដែលក្នុងនោះសេវាផ្ទេរប្រាក់និងទូទាត់តាមទូរស័ព្ទចល័ត ដូចជាការទូទាត់និងផ្ទេរប្រាក់តាមរយៈឃ្យូអរកូដ និងលេខទូរស័ព្ទទទួលបានការនិយមប្រើប្រាស់ពីសំណាក់យុវវ័យដែលអាចងាយសម្របទៅនឹងការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ។

សមិទ្ធផលដែលទទួលបានគួរជាទីមោទនទាំងនេះ ជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរបស់ធនាគារជាតិនៃកម្ពុជាក្នុងការបង្កនូវបរិស្ថានអំណោយផលជំរុញការអភិវឌ្ឍ និងប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងការគាំទ្រនវានុវត្តន៍នៃប្រព័ន្ធទូទាត់ដែលរួមមាន ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទូទាត់ ការរៀបចំក្របខណ្ឌបទប្បញ្ញត្តិនិងត្រួតពិនិត្យ និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ។ ជាក់ស្តែង បន្ទាប់ពីដាក់ឱ្យដំណើរការប្រព័ន្ធបាគង ធនាគារជាតិនៃកម្ពុជាបានមើលឃើញពីឱកាសក្នុងការអភិវឌ្ឍប្រព័ន្ធបាគងក្នុងជំហានបន្ទាប់ ដើម្បីឱ្យប្រព័ន្ធនេះអាចផ្តល់នូវសេវាទូទាត់ឌីជីថលសម្បូរបែប និងមានការចូលរួមពីគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលជាផ្នែកមួយនាំទៅរកការសម្រេចបាននូវអន្តរប្រតិបត្តិការពេញលេញសម្រាប់ប្រព័ន្ធទូទាត់នៅប្រទេសកម្ពុជា។ លើសពីនេះ ការដាក់ឱ្យប្រើប្រាស់ខេអេចឃ្យូអរកូដដែលជាស្តង់ដារឃ្យូអរកូដសម្រាប់ការទូទាត់នៅប្រទេសកម្ពុជាក៏ជាកត្តារួមចំណែកមួយជំរុញ និងសម្រួលអន្តរប្រតិបត្តិការទូទាត់តាមឃ្យូអរកូដឆ្លើយតបទៅនឹងកំណើន និងប្រជាប្រិយភាពនៃការទូទាត់ទាំងក្នុងប្រទេស និងក្នុងតំបន់។

ការទូទាត់ឌីជីថលទាមទារឱ្យមានការគាំទ្រជាចាំបាច់ពីហេដ្ឋារចនាសម្ព័ន្ធដទៃទៀតដើម្បីឱ្យដំណើរការទូទាត់អាចប្រព្រឹត្តិទៅដោយប្រសិទ្ធភាព សុវត្ថិភាព និងភាពងាយស្រួល តួយ៉ាងដូចជាហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាទូរគមនាគមន៍ និងអត្តសញ្ញាណឌីជីថលជាដើម។ ជាមួយនឹងការរីកចម្រើនយ៉ាងរហ័សនិងទំហំដ៏ច្រើននៃការប្រើប្រាស់ទូរស័ព្ទឆ្លាតវៃ ក៏ដូចជាការផ្គត់ផ្គង់សេវាអ៊ីនធឺណិតកាន់តែទូលំទូលាយទូទាំងប្រទេសក្នុងតម្លៃសមរម្យ បានធ្វើឱ្យការប្រើប្រាស់សេវាទូទាត់ឌីជីថលតាមទូរស័ព្ទចល័តកាន់តែមានភាពងាយស្រួល និងក្លាយជាមធ្យោបាយទូទាត់យ៉ាងសំខាន់ជំនួសឱ្យការ

ប្រើប្រាស់សាច់ប្រាក់ ជាពិសេសក្នុងបរិបទនៃការរីករាលដាលឆ្លងនៃជំងឺកូវីដ-១៩ ដែលតម្រូវការទូទាត់ឌីជីថលមានការកើនឡើង។ លើសពីនេះ ការផ្ទៀងផ្ទាត់អត្តសញ្ញាណអតិថិជនក្នុងការបើកគណនីក៏ដូចជាការធ្វើប្រតិបត្តិការទូទាត់ឌីជីថលជាផ្នែកដ៏សំខាន់មួយនៃដំណើរការទូទាត់ដែលទាមទារឱ្យមានការគាំទ្រពីហេដ្ឋារចនាសម្ព័ន្ធអត្តសញ្ញាណឌីជីថល ដើម្បីសម្រួលឱ្យប្រតិបត្តិការអាចធ្វើឡើងដោយស្វ័យប្រវត្តិភ្លាមៗ។ ទាំងនេះបញ្ជាក់ឱ្យឃើញពីសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរពាក់ព័ន្ធដើម្បីជំរុញឱ្យការងារនេះអាចសម្រេចបានក្នុងកម្រិតវិស័យ ឬថ្នាក់ជាតិ។

ទោះបីជាបច្ចេកវិទ្យាហិរញ្ញវត្ថុបានផ្តល់នូវកាលានុវត្តភាពផ្នែកនវានុវត្តន៍យ៉ាងច្រើនសម្រាប់ប្រព័ន្ធទូទាត់និងសេវាទូទាត់ ក៏មានបញ្ហាប្រឈមជាច្រើន ជាពិសេស កម្រិតនៃការយល់ដឹងផ្នែកឌីជីថល និងហានិភ័យផ្នែកបច្ចេកវិទ្យា ដែលទាមទារឱ្យមានការយកទុកដាក់ក្នុងការគ្រប់គ្រង និងដោះស្រាយបន្ថែមទៀតពីអាជ្ញាធរនិងភាគីពាក់ព័ន្ធ ដើម្បីធានាបាននូវការអភិវឌ្ឍប្រកបដោយស្ថិរភាព។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជានឹងបន្តរៀបចំក្របខណ្ឌបទប្បញ្ញត្តិ និងអនុវត្តការត្រួតពិនិត្យដោយប្រុងប្រយ័ត្ន ដើម្បីកាត់បន្ថយហានិភ័យនិងការពារផលប្រយោជន៍អតិថិជនបានជាអតិបរមា។ បន្ថែមពីនេះ ការលើកកម្ពស់ចំណេះដឹងផ្នែកឌីជីថលជាការងារដែលចាំបាច់ត្រូវអនុវត្តដើម្បីជំរុញការប្រើប្រាស់សេវាទូទាត់ឌីជីថលឱ្យទូលំទូលាយប្រកបដោយសុវត្ថិភាព។

របាយការណ៍ប្រចាំឆ្នាំ២០២១ ស្តីពីប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជា នេះ នឹងក្លាយជាឯកសារដ៏មានប្រយោជន៍សម្រាប់សាធារណជនទាំងអស់សិក្សាស្វែងយល់ឱ្យកាន់តែច្បាស់អំពីការងារដែលធនាគារជាតិនៃកម្ពុជាបាននិងកំពុងអនុវត្តនិងវឌ្ឍនភាពថ្មីៗពាក់ព័ន្ធនឹងការអភិវឌ្ឍប្រព័ន្ធទូទាត់នៅកម្ពុជា។

# មាតិកា


**អារម្ភកថា** ..... i

**បញ្ជីតារាង ប្រអប់ និងក្រាហ្វ** ..... v

**អក្សរកាត់** ..... vii

**បរិយាយសង្ខេប** ..... ix

**១. ក្របខណ្ឌគោលនយោបាយប្រព័ន្ធទូទាត់សងប្រាក់** ..... ១

**១.១. ការអភិវឌ្ឍចម្បងៗ** ..... ១

**១.២. គោលនយោបាយគាំទ្រ** ..... ៤

**១.៣. ជំហានបន្ទាប់** ..... ៦

**២. ការអភិវឌ្ឍប្រព័ន្ធបាគង** ..... ៧

**២.១. វឌ្ឍនភាព និងសមិទ្ធផលនៃប្រព័ន្ធបាគង** ..... ៧

២.១.១. អតិថិជនចុះឈ្មោះប្រើប្រាស់ប្រព័ន្ធបាគង ..... ៧

២.១.២. ប្រតិបត្តិការប្រព័ន្ធបាគង ..... ៨

**២.២. ការអភិវឌ្ឍបន្ត** ..... ៩

២.២.១. ប្រព័ន្ធបាគងជាមជ្ឈមណ្ឌលទូទាត់ ..... ៩

២.២.២. ប្រព័ន្ធបាគងសម្រាប់ការផ្ទេរប្រាក់ និងទូទាត់ឆ្លងដែន ..... ៩

២.២.៣. ប្រព័ន្ធបាគងសម្រាប់ប្រព័ន្ធទូទាត់តម្លៃធំ ..... ១០

២.២.៤. ប្រព័ន្ធបាគងជាផ្លែតហ្វមធនាគារបើកចំហ ..... ១១

២.២.៥. ការលើកកម្ពស់ចំណេះដឹង និងការផ្សព្វផ្សាយជំរុញការប្រើប្រាស់ប្រព័ន្ធបាគង ..... ១១

**៣. ការត្រួតពិនិត្យតាមដានប្រព័ន្ធទូទាត់សងប្រាក់** ..... ១៤

**៣.១. ទិដ្ឋភាពទូទៅនៃហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់** ..... ១៤

៣.១.១. ប្រព័ន្ធផាត់ទាត់ជាតិ - NCS ..... ១៤

៣.១.២. ប្រព័ន្ធសេវាទូទាត់រហ័ស - FAST ..... ១៨

៣.១.៣. ប្រព័ន្ធខេមបូឌានស៊ែស្វីច - CSS ..... ១៩

៣.១.៤. ប្រព័ន្ធធនាគារអនឡាញ - OBS ..... ២០

៣.១.៥. ប្រព័ន្ធរីផែលផេ - RPS ...... ២២

**៣.២. ការពង្រឹងស្ថិរភាពប្រព័ន្ធទូទាត់សងប្រាក់** ...... ២៤

៣.២.១. ការគ្រប់គ្រងហានិភ័យសន្ទនីយភាព ហានិភ័យទូទាត់ និងហានិភ័យឥណទាន ...... ២៤

៣.២.២. ការគ្រប់គ្រងហានិភ័យប្រតិបត្តិការ និងហានិភ័យដួលរលំជាប្រព័ន្ធ ...... ២៥

**៤. ការគ្រប់គ្រងសេវាទូទាត់សងប្រាក់** ...... ២៦

**៤.១. ការវិវត្តន៍នៃសេវាទូទាត់សងប្រាក់** ...... ២៦

**៤.២. ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិសេវាទូទាត់សងប្រាក់** ...... ៣០

**៤.៣. ការពង្រឹងស្ថិរភាពសេវាទូទាត់សងប្រាក់** ...... ៣១

**៥. ការផ្ទេរប្រាក់ឆ្លងដែននៅកម្ពុជា** ...... ៣៤

**៥.១. ទិដ្ឋភាពទូទៅ** ...... ៣៤

**៥.២. គោលនយោបាយគាំទ្រ** ...... ៣៦

**៥.៣. របាយការណ៍ផ្ទេរប្រាក់ឯកជនឆ្លងដែនតាមប្រព័ន្ធរបាយការណ៍ប្រតិបត្តិការអន្តរជាតិ - ITRS** .. ៣៧

**ឧបសម្ព័ន្ធ១ - ច្បាប់ និងបទប្បញ្ញត្តិ** ...... ៤១

**ឧបសម្ព័ន្ធ២ - បញ្ជីរាយនាមឈ្មោះសមាជិកប្រព័ន្ធបាគង** ...... ៤៣

**ឧបសម្ព័ន្ធ៣ - បញ្ជីរាយនាមឈ្មោះគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់** ...... ៤៤

**ឧបសម្ព័ន្ធ៤ - គ្រឹះស្ថានផ្តល់សេវាធនាគារអេឡិចត្រូនិក** ...... ៥១

**ឧបសម្ព័ន្ធ៥ - លំហូរប្រតិបត្តិការរបស់ប្រព័ន្ធទូទាត់សងប្រាក់** ...... ៥៣

# បញ្ជីតារាង ប្រអប់ និងក្រាហ្វ

## តារាង


តារាង ១ - ការផាត់ទាត់ និងទូទាត់មូលប្បទានបត្រ ជាប្រាក់រៀល ........ ១៥

តារាង ២ - ការផាត់ទាត់ និងទូទាត់មូលប្បទានបត្រ ជាប្រាក់ដុល្លារអាមេរិក........ ១៥

តារាង ៣ - បញ្ជាផ្ទេរឥណទានតាមប្រព័ន្ធផាត់ទាត់ជាតិ........១៧

តារាង ៤ - បញ្ជាផ្ទេរឥណទាន តាមប្រព័ន្ធ FAST ........ ១៨

តារាង ៥ - ការទូទាត់លើប្រតិបត្តិការប័ណ្ណឥណពន្ធតាមប្រព័ន្ធ CSS ........ ២០

តារាង ៦ - ការផ្ទេរប្រាក់រវាងគណនីនៅស្នាក់ការកណ្តាល តាមប្រព័ន្ធ OBS ........ ២១

តារាង ៧ - ការផ្ទេរប្រាក់ពីគណនីនៅស្នាក់ការកណ្តាលទៅសាខារាជធានី-ខេត្ត តាមប្រព័ន្ធ OBS ........ ២១

តារាង ៨ - ប្រតិបត្តិការបញ្ជាផ្ទេរអេឡិចត្រូនិកតាមប្រព័ន្ធ RFT ........ ២៣


## ប្រអប់


ប្រអប់ ១ - ការអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ ........ ១២

ប្រអប់ ២ - ទិដ្ឋភាពទូទៅនៃសេវាទូទាត់សងប្រាក់នៅកម្ពុជា........ ៣៣


## ក្រាហ្វ


ក្រាហ្វ ១ - រូបិយវត្ថុក្នុងចរាចរណ៍ និងទំហំប្រាក់ទូទាត់តាមអេឡិចត្រូនិកជាប្រាក់រៀល ........ ២

ក្រាហ្វ ២ - ប្រតិបត្តិការទូទាត់តាមរយៈប័ណ្ណទូទាត់ និងការស្កេន QR Code ........ ៣

ក្រាហ្វ ៣ - ចំនួនអតិថិជនចុះឈ្មោះប្រើប្រាស់ជាមួយកម្មវិធីបាគង........ ៧

ក្រាហ្វ ៤ - ប្រតិបត្តិការផ្ញើឡើងតាមរយៈប្រព័ន្ធបាគង ........ ៨

ក្រាហ្វ ៥ - ទំហំប្រតិបត្តិការទូទាត់សងប្រាក់ជាអេឡិចត្រូនិកមុនដាក់និងបន្ទាប់ពីបានដាក់ដំណើរការប្រព័ន្ធបាគង..៨

ក្រាហ្វ ៦ - ការផាត់ទាត់ និងទូទាត់មូលប្បទានបត្រ ........ ១៦

ក្រាហ្វ ៧ - បញ្ជាផ្ទេរប្រាក់អេឡិចត្រូនិក ជាប្រាក់រៀល និងជាប្រាក់ដុល្លារអាមេរិក ........ ១៧

ក្រាហ្វ ៨ - បញ្ជាផ្ទេរឥណទាន តាមប្រព័ន្ធ FAST ........ ១៩

ក្រាហ្វ ៩ - ការទូទាត់លើប្រតិបត្តិការប័ណ្ណឥណពន្ធតាមប្រព័ន្ធ CSS ........ ២០

ក្រាហ្វ ១០ - ប្រតិបត្តិការផ្ទេរប្រាក់ តាមប្រព័ន្ធ OBS ........ ២២

ក្រាហ្វ ១១ - ប្រតិបត្តិការបញ្ជាផ្ទេរអេឡិចត្រូនិក តាមប្រព័ន្ធ RFT ....... ២៣

ក្រាហ្វ ១២ - ចំនួន និងទំហំប្រាក់ប្រតិបត្តិការនៃប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជា ....... ២៤

ក្រាហ្វ ១៣ - ចំនួនភ្នាក់ងារ អតិថិជនចុះឈ្មោះអ៊ីវ៉ាឡេត និងអតិថិជន Walk-in របស់គ្រឹះស្ថានធនាគារនិង ហិរញ្ញវត្ថុផ្តល់សេវាទូទាត់ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ....... ២៧

ក្រាហ្វ ១៤ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការនៃសេវាទូទាត់ចល័តតាមកាបូបអេឡិចត្រូនិក (Mobile E-wallet) ....... ២៧

ក្រាហ្វ ១៥ - សមតុល្យរូបិយវត្ថុអេឡិចត្រូនិកសរុបដែលបានចេញផ្សាយ ....... ២៧

ក្រាហ្វ ១៦ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការរបស់សេវាធនាគារអ៊ីនធឺណិត និងសេវាធនាគារចល័ត (Internet Banking and Mobile Banking) ....... ២៨

ក្រាហ្វ ១៧ - ចំនួនប័ណ្ណទូទាត់ដែលបានចេញផ្សាយ (រួមទាំងប័ណ្ណទូទាត់អន្តរជាតិ) ....... ២៩

ក្រាហ្វ ១៨ - ចំនួនម៉ាស៊ីន ATM និង ម៉ាស៊ីនឆូតកាត POS ....... ២៩

ក្រាហ្វ ១៩ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការទូទាត់តាម QR Code ....... ៣០

ក្រាហ្វ ២០ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែន ....... ៣៥

ក្រាហ្វ ២១ - ទំហំប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែនជាលក្ខណៈឯកជន តាមប្រព័ន្ធ ITRS ....... ៣៧

# អក្សរកាត់

| | |
|---|---|
| ACH | Automatic Clearing House |
| ATM | Automatic Teller Machine |
| BAKONG LVPS | BAKONG Large Value Payment System |
| CAMDX | Cambodia Data Exchange |
| CPSS | Committee on Payment and Settlement Systems |
| CSS | Cambodian Shared Switch System |
| DLT | Distributed Ledger Technology |
| ECS | Electronic Clearing System |
| EMV | Europay, Mastercard, and Visa |
| FAST | Fast Payment System |
| FINTECH | Financial Technology |
| IOSCO | International Organization of Securities and Commissions |
| ITRS | International Transactions Reporting System |
| KHQR Code | Khmer Quick Response Code |
| KYC | Know Your Customer |
| ML/FT | Money Laundering / Financing of Terrorism |
| MPS | Mobile Payment System |
| NCS | National Clearing System |
| OBS | Online Banking System |
| PFMI | Principles for Financial Market Infrastructure |
| POS | Point of Sale |
| PSI | Payment Service Institution |
| RFT | Real Time Fund Transfer |
| RPS | Retail Payment System |
| SIPS | Systemically Important Payment System |

| | |
|---|---|
| STP | Straight Through Processing |
| SWIFT | Society for the Worldwide Interbank Financial Telecommunication |
| TPP | Third Party Processor |
| QPS | QR Code Payment System |
| QR Code | Quick Response Code |

# បរិយាយសង្ខេប

ស្ថិតក្នុងបរិបទនៃបដិវត្តន៍ឧស្សាហកម្ម ៤.០ បានធ្វើឱ្យបច្ចេកវិទ្យាហិរញ្ញវត្ថុក្លាយជាសមាសធាតុយ៉ាងសំខាន់ក្នុងការអភិវឌ្ឍប្រព័ន្ធទូទាត់នាពេលបច្ចុប្បន្ន ជាពិសេស ប្រព័ន្ធទូទាត់ឌីជីថលដែលបាននិងកំពុងដើរតួយ៉ាងសំខាន់ក្នុងការសម្រួលការទូទាត់ជាអេឡិចត្រូនិក ក្នុងអំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ-១៩។ ដើម្បីឆ្លើយតបទៅនឹងវឌ្ឍនភាពនេះ ធនាគារជាតិនៃកម្ពុជាបានបន្តអភិវឌ្ឍ និងដាក់ឱ្យដំណើរការប្រព័ន្ធទូទាត់តាមដំណាក់កាល រួមមាន ប្រព័ន្ធផាត់ទាត់ជាតិ ប្រព័ន្ធសេវាទូទាត់រហ័ស ប្រព័ន្ធធនាគារអនឡាញ ប្រព័ន្ធខេមបូឌានស៊ែស្វីច ប្រព័ន្ធរីថែលផេ និងប្រព័ន្ធបាគង ដើម្បីសម្រួលការទូទាត់អន្តរធនាគារប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព។

ប្រព័ន្ធផាត់ទាត់ជាតិដែលជាប្រព័ន្ធទូទាត់សំខាន់មានលក្ខណៈជាប្រព័ន្ធបានដំណើរការដោយរលូនក្នុងការផាត់ទាត់និងទូទាត់ប្រតិបត្តិការតាមរយៈមូលប្បទានបត្រ និងបញ្ជាទូទាត់សងប្រាក់អេឡិចត្រូនិក។ គួរកត់សម្គាល់ថា ចំនួនប្រតិបត្តិការតាមរយៈមូលប្បទានបត្រទាំងប្រាក់រៀល និងដុល្លារអាមេរិកមានការថយចុះ ក្នុងអត្រា ១២,៧៦% និង ១៤,២៥% រៀងគ្នា ចំណែកឯការទូទាត់តាមបញ្ជាទូទាត់សងប្រាក់អេឡិចត្រូនិកជាប្រាក់រៀលនិងប្រាក់ដុល្លារអាមេរិកបានកើនឡើង ៥៨% និង ៨៦% រៀងគ្នាធៀបនឹងឆមាសទី១ ឆ្នាំ២០២០។ ទន្ទឹមនេះ ចំនួនប្រតិបត្តិការតាមរយៈប្រព័ន្ធសេវាទូទាត់រហ័ស ប្រព័ន្ធខេមបូឌានស៊ែស្វីច និងប្រព័ន្ធរីថែលផេ ក៏បន្តកើនឡើងខ្ពស់ក្នុងអត្រា ៨៧% ១៤២,១៧% និង ៩១៧,៧៥% រៀងគ្នា។ ដោយឡែក ប្រព័ន្ធបាគងដែលជាប្រព័ន្ធទូទាត់ជំនាន់ថ្មីក៏កំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការបំពេញតម្រូវការទូទាត់ឌីជីថលតាមរយៈទូរស័ព្ទចល័ត ដោយក្នុងនោះចំនួនប្រតិបត្តិការសរុបដែលត្រូវបានដំណើរការទូទាត់តាមប្រព័ន្ធបាគងមានចំនួន ១,៤២ លានប្រតិបត្តិការ។

ស្របពេលជាមួយនឹងការដាក់ឱ្យដំណើរការហេដ្ឋារចនាសម្ព័ន្ធទូទាត់ថ្មីៗ គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ក៏បាននិងកំពុងប្រកួតប្រជែងក្នុងការដាក់ឱ្យប្រើប្រាស់សេវាទូទាត់ឌីជីថលប្រកបដោយនវានុវត្តន៍ ជាពិសេស ការទូទាត់និងផ្ទេរប្រាក់តាមមធ្យោបាយអេឡិចត្រូនិកដូចជា សេវាធនាគារអ៊ីនធឺណិត សេវាធនាគារចល័ត សេវាទូទាត់ចល័ត ដែលរួមមានការទូទាត់តាមយ្យអរកូតផងដែរ។ លើសពីនេះ ចំនួនគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ចំនួនគណនីកាបូបអេឡិចត្រូនិក ទំហំប្រតិបត្តិការអេឡិចត្រូនិក ជាពិសេស ការទូទាត់តាមយ្យអរកូតមានការកើនឡើងគួរឱ្យកត់សម្គាល់ បើធៀបនឹងឆមាសទី១ និងឆមាសទី២ ឆ្នាំ២០២០។

បន្ទាប់ពីដាក់ឱ្យប្រព័ន្ធបាគងដំណើរការបានជោគជ័យ ធនាគារជាតិនៃកម្ពុជាបានមើលឃើញពីឱកាសក្នុងការបន្តអភិវឌ្ឍប្រព័ន្ធបាគងនៅក្នុងជំហានបន្ទាប់ ដើម្បីឱ្យប្រព័ន្ធបាគងអាចបំពេញមុខងារសម្បូរបែប និងភាពងាយស្រួលសម្រាប់អតិថិជនធ្វើប្រតិបត្តិការទូទាត់ឌីជីថល សំដៅសម្រេចបាននូវប្រតិបត្តិការពេញលេញ។ មុខងារចម្បងៗដែលបាននិងកំពុងត្រូវបានអនុវត្តក្នុងការអភិវឌ្ឍប្រព័ន្ធបាគងក្នុងជំហានបន្ទាប់រួមមាន ១/.ជាមជ្ឈមណ្ឌលទូទាត់សម្រាប់សម្រួលដល់ការទូទាត់ឆ្លងគ្រឹះស្ថានតាមរយៈខេអេចយ្យអរកូត ២/.សម្រាប់ការផ្ទេរប្រាក់និងទូទាត់ឆ្លងដែន ៣/.ជាប្រព័ន្ធទូទាត់តម្លៃធំ និង ៤/.ជាផ្លែតហ្វមធនាគារបើកចំហសម្រាប់មុខងារផ្ទៀងផ្ទាត់គណនីអ្នកទទួលផល។

ធនាគារជាតិនៃកម្ពុជាក៏បាននិងកំពុងបន្តដាក់ឱ្យអនុវត្តស្តង់ដារជាបន្តបន្ទាប់ដើម្បីលើកកម្ពស់អន្តរប្រតិបត្តិការ និងសុវត្ថិភាពក្នុងការទូទាត់។ កន្លងមកធនាគារបានដាក់ឱ្យប្រើប្រាស់នូវមូលប្ប-

ទានបត្រស្តង់ដារ និងគំរូបញ្ជាទូទាត់សងប្រាក់សម្រាប់ការផ្ទេរឥណទាន ដើម្បីសម្រួលដល់ការផាត់ទាត់និងទូទាត់នៅសភាផាត់ទាត់ជាតិ។ បន្ថែមពីនេះ ស្តង់ដារ EMV CHIP សម្រាប់ប័ណ្ណទូទាត់ឥណពន្ធ និងខេអេចឃ្យូអរកូតដែលជាស្តង់ដារឃ្យូអរកូតសម្រាប់ការទូទាត់ក៏ត្រូវបានដាក់ឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអនុវត្ត ឆ្លើយតបទៅនឹងការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុនិងតម្រូវការទីផ្សារលើសេវានិងឧបករណ៍ទូទាត់ថ្មីៗ ជាពិសេស ប័ណ្ណទូទាត់ និងការទូទាត់តាមឃ្យូអរកូត។

ក្នុងក្របខណ្ឌបទប្បញ្ញត្តិ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញប្រកាសមួយចំនួនរួចមកហើយ និងកំពុងបន្តរៀបចំប្រកាស និងសេចក្តីណែនាំថ្មីៗបន្ថែមទៀតដើម្បីគ្រប់គ្រងប្រតិបត្តិការប្រព័ន្ធទូទាត់សងប្រាក់ ព្រមទាំងការផ្តល់សេវានិងឧបករណ៍ទូទាត់សងប្រាក់។ ការរៀបចំបទប្បញ្ញត្តិផ្តោតសំខាន់លើការលើកកម្ពស់ប្រសិទ្ធភាព សុវត្ថិភាព និងការជំរុញនវានុវត្តន៍ ស្របតាមការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ។ ប្រកាសដែលបាននិងកំពុងរៀបចំបន្ថែមទៀតរួមមានប្រកាសពាក់ព័ន្ធនឹងការដាក់ឱ្យប្រើប្រាស់វិធាននិងនីតិវិធីប្រព័ន្ធទូទាត់តម្លៃធំ ការគណនាមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ការគ្រប់គ្រងភ្នាក់ងាររបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ការគ្រប់គ្រងគណនីអាណត្តិព្យាបាល និងនីតិវិធីត្រួតពិនិត្យគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់។

ធនាគារជាតិនៃកម្ពុជាបន្តពង្រឹងការត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ក្នុងគោលដៅធានាបានស្ថិរភាព បង្កើនជំនឿទុកចិត្តរបស់សាធារណជនលើប្រព័ន្ធទូទាត់ និងជំរុញការទូទាត់ជាអេឡិចត្រូនិកក្នុងសេដ្ឋកិច្ច។ ការត្រួតពិនិត្យប្រព័ន្ធទូទាត់ផ្តោតសំខាន់លើប្រសិទ្ធភាពនិងសុវត្ថិភាពនៃប្រតិបត្តិការប្រព័ន្ធទូទាត់ ដោយរួមមានទាំងការតាមដាននិន្នាការនៃប្រតិបត្តិការទូទាត់ និងការគ្រប់គ្រងហានិភ័យ ដូចជា ហានិភ័យសន្ទនីយភាព ហានិភ័យឥណទាន ហានិភ័យប្រតិបត្តិការ ហានិភ័យទូទាត់ និងជាពិសេសហានិភ័យដួលរលំជាប្រព័ន្ធ។ ចំណែកឯការត្រួតពិនិត្យលើគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ក៏ត្រូវបានអនុវត្តតាមរយៈការត្រួតពិនិត្យលើឯកសារ និងការត្រួតពិនិត្យដល់ទីកន្លែង ដោយយកចិត្តទុកដាក់លើការអនុវត្តតាមបទប្បញ្ញត្តិជាធរមាន ជាពិសេសការវាយតម្លៃផ្អែកលើបទប្បញ្ញត្តិប្រុងប្រយ័ត្ន។

ការផ្ទេរប្រាក់និងការទូទាត់ឆ្លងដែនកាន់តែមានភាពងាយស្រួល រហ័ស និងមានកម្រៃកាន់តែសមរម្យ ដោយសារមានគ្រឹះស្ថានជាច្រើនបាននិងកំពុងប្រកួតប្រជែងក្នុងការផ្តល់សេវានេះដែលធ្វើឱ្យអតិថិជនមានជម្រើសកាន់តែច្រើន។ បច្ចុប្បន្ន អតិថិជនអាចធ្វើការផ្ទេរប្រាក់និងទូទាត់ឆ្លងដែនតាមរយៈគ្រឹះស្ថានធនាគារ អ្នកដំណើរការតតិយភាគី និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ដែលប្រតិបត្តិការអាចធ្វើឡើងតាមរយៈប្រព័ន្ធស្វីស (SWIFT) ឬដៃគូសហការផ្ទេរប្រាក់ក្រៅប្រទេសនានា។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាក៏បាននិងកំពុងផ្តួចផ្តើមភ្ជាប់ការទូទាត់ឆ្លងដែនជាមួយប្រទេសក្នុងតំបន់ ជាពិសេសតំបន់អាស៊ាន ដូចជា ការភ្ជាប់ការទូទាត់តាមឃ្យូអរកូតជាមួយប្រទេសថៃ និងការភ្ជាប់ប្រព័ន្ធបាគងជាមួយធនាគារមេយប៊ែង ដើម្បីសម្រួលការផ្ទេរប្រាក់រវាងប្រទេសកម្ពុជា និងម៉ាឡេស៊ីជាដើម។ ម្យ៉ាងទៀត ជាមួយនឹងការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ គ្រឹះស្ថានមួយចំនួនក៏បានដាក់ឱ្យប្រើប្រាស់សេវាផ្ទេរប្រាក់ និងទូទាត់ឆ្លងដែនតាមរយៈមធ្យោបាយឌីជីថល បន្ថែមពីលើការផ្តល់សេវាតាមភ្នាក់ងារនិងបញ្ជរ។ ទន្ទឹមនោះ គ្រឹះស្ថានមួយចំនួនក៏កំពុងផ្តល់សេវាទទួលការទូទាត់ជាមួយក្រុមហ៊ុនទូទាត់វីឆាតផេ និងអាលីផេ ផងដែរ។

# ១. ក្របខណ្ឌគោលនយោបាយប្រព័ន្ធទូទាត់សងប្រាក់

## ១.១. ការអភិវឌ្ឍថ្មីៗ

ប្រព័ន្ធទូទាត់នៅក្នុងប្រទេសកម្ពុជាបាននិងកំពុងមានការរីកចម្រើនគួរជាទីមោទន និងកំពុងវិវត្តទៅរកការទូទាត់ឌីជីថលជាមួយនិងវឌ្ឍនភាពថ្មីៗទាំងហេដ្ឋារចនាសម្ព័ន្ធទូទាត់ សេវាទូទាត់ និងឧបករណ៍ទូទាត់។ គួរកត់សម្គាល់ថា ទំហំនៃការទូទាត់មូលប្បទានបត្រតាមរយៈប្រព័ន្ធផាត់ទាត់ជាតិមាននិន្នាការធ្លាក់ចុះ ខណៈការទូទាត់តាមបញ្ជាទូទាត់អេឡិចត្រូនិកមានការកើនឡើង។ ទាំងនេះជាលទ្ធផលនៃការអនុវត្តគោលនយោបាយស្តីពី សមាជិកភាពប្រព័ន្ធផាត់ទាត់ជាតិដែលធនាគារជាតិនៃកម្ពុជាបានដាក់ចេញដោយកំណត់លក្ខខណ្ឌក្នុងការចូលរួមជាសមាជិកប្រព័ន្ធផាត់ទាត់ជាតិឡើងវិញ ស្របពេលនឹងការអនុវត្តគោលនយោបាយផ្សេងៗទៀត ដើម្បីលើកកម្ពស់ការទូទាត់ឌីជីថល ដូចជា ការដាក់ឱ្យដំណើរការប្រព័ន្ធទូទាត់ថ្មីៗបន្ថែមទៀត ដើម្បីផ្តល់ជម្រើសដល់អតិថិជនក្នុងការធ្វើប្រតិបត្តិការទូទាត់ជាអេឡិចត្រូនិកជាដើម។ លើសពីនេះ ប្រតិបត្តិការទូទាត់តាមរយៈប្រព័ន្ធសេវាទូទាត់រហ័សក៏មាននិន្នាការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ដែលបង្ហាញឱ្យឃើញពីសញ្ញាណវិជ្ជមានក្នុងការផ្លាស់ប្តូរទៅរកការទូទាត់ជាអេឡិចត្រូនិកក្នុងសេដ្ឋកិច្ចកម្ពុជា។ កាលពីខែមករា ឆ្នាំ២០២១ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការជាផ្លូវការប្រព័ន្ធរីផែលផេ ដើម្បីផ្តល់ជម្រើសបន្ថែមទៀតសម្រាប់អតិថិជនក្នុងការធ្វើប្រតិបត្តិការទូទាត់ជាអេឡិចត្រូនិកឱ្យកាន់តែមានភាពងាយស្រួល។

ក្រៅពីមូលប្បទានបត្រនិងបញ្ជាទូទាត់អេឡិចត្រូនិក ប័ណ្ណទូទាត់ក៏ជាឧបករណ៍ទូទាត់សំខាន់មួយ ដែលបានរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់ប្រតិបត្តិការទូទាត់ឌីជីថល និងពាណិជ្ជកម្មអេឡិចត្រូនិកនៅប្រទេសកម្ពុជា ជាពិសេសក្នុងស្ថានភាពនៃការរីករាលដាលនៃជំងឺកូវីដ-១៩ ដែលវិធានការការពារផ្សេងៗត្រូវបានអនុវត្ត។ ប័ណ្ណទូទាត់ត្រូវបានប្រើប្រាស់សម្រាប់ទូទាត់លើការទិញទំនិញ-សេវា និងប្រតិបត្តិការធនាគារផ្សេងៗទៀត។ ការដាក់ឱ្យដំណើរការប្រព័ន្ធខេមបូឌានស្វៃស៊ីចក៏បានបំពេញមុខងារយ៉ាងសំខាន់ក្នុងការសម្រួលដល់អន្តរប្រតិបត្តិការតាមរយៈប័ណ្ណទូទាត់ឥណពន្ធក្នុងស្រុក។ លើសពីនេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុជាច្រើនបាននិងកំពុងផ្លាស់ប្តូរពីការចេញផ្សាយប័ណ្ណទូទាត់ដែលប្រើប្រាស់បច្ចេកវិទ្យា Magnetic stripe មកប័ណ្ណទូទាត់ដែលប្រើប្រាស់បច្ចេកវិទ្យា EMV Chip ជំនួសវិញដើម្បីពង្រឹងសុវត្ថិភាពក្នុងការប្រើប្រាស់ប័ណ្ណទូទាត់ស្របតាមស្តង់ដារ និងឧត្តមានុវត្តអន្តរជាតិ។ ទន្ទឹមនោះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក៏កំពុងពង្រីកបណ្តាញម៉ាស៊ីនដាក់/ដកប្រាក់ (ATM) និងម៉ាស៊ីនឆូតកាត (POS) ទូទាំងប្រទេស ដើម្បីផ្តល់ភាពងាយស្រួល និងបំពេញតម្រូវការអតិថិជនក្នុងការប្រើប្រាស់ប័ណ្ណទូទាត់។

ក្រៅពីវឌ្ឍនភាពថ្មីៗពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់និងប័ណ្ណទូទាត់ មធ្យោបាយទូទាត់ឌីជីថលផ្សេងៗទៀតក៏កំពុងរីកលូតលាស់យ៉ាងឆាប់រហ័សផងដែរ។ ការរីកចម្រើននៃបច្ចេក-វិទ្យាហិរញ្ញវត្ថុដែលជាលទ្ធផលនៃបដិវត្តន៍ឧស្សាហកម្មទី៤ ក៏បានផ្តល់នូវកាលានុវត្តភាពយ៉ាងច្រើនសម្រាប់នវានុវត្តន៍ក្នុងវិស័យហិរញ្ញវត្ថុនិងធនាគារ ជាពិសេសលើផ្នែកប្រព័ន្ធទូទាត់ សេវាទូទាត់ និងឧបករណ៍ទូទាត់ ព្រមទាំងបានផ្លាស់ប្តូររបៀបនៃការផ្តល់និងការប្រើប្រាស់សេវាទូទាត់នៅក្នុងប្រទេសកម្ពុជា។ ជាមួយនឹងការរក្សាបាននូវស្ថិរភាពនយោបាយ និងការអនុវត្តគោលនយោបាយ

អភិវឌ្ឍវិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលបានធ្វើឱ្យវិស័យធនាគារដែលជាចំណែកដ៏ចម្បងនៃវិស័យហិរញ្ញវត្ថុមានការរីកចម្រើនយ៉ាងឆាប់រហ័ស និងបានផ្ដល់លទ្ធភាពខ្ពស់ក្នុងការទាញយកផលប្រយោជន៍ពីសន្ទុះនៃការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ។ តាមការសង្កេតឃើញថា គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានផ្ដល់សេវាទូទាត់សងប្រាក់បាននិងកំពុងប្រកួតប្រជែងក្នុងការដាក់ឱ្យប្រើប្រាស់សេវានិងឧបករណ៍ទូទាត់ឌីជីថលថ្មីៗ ដូចជា សេវាធនាគារអ៊ីនធឺណិត សេវាធនាគារចល័ត សេវាទូទាត់ចល័តតាមរយៈកម្មវិធីទូរស័ព្ទវៃឆ្លាត ការទូទាត់តាមរយៈឧបករណ៍ Contactless ជាដើម។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ទំហំនៃការទូទាត់តាមមធ្យោបាយឌីជីថលមានការកើនឡើងគួរឱ្យកត់សម្គាល់ ជាពិសេសក្នុងអំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ-១៩។ នវានុវត្តន៍ផ្នែកប្រព័ន្ធទូទាត់ស្របពេលជាមួយនឹងបទពិសោធន៍ពីជំងឺកូវីដ-១៩ បានក្លាយជាកត្តាដ៏សំខាន់មួយ ក្នុងការផ្លាស់ប្ដូរឥរិយាបថរបស់ប្រជាជនកម្ពុជាឱ្យងាកមកប្រើប្រាស់ការទូទាត់ឌីជីថលជំនួសឱ្យសាច់ប្រាក់។ ជាមួយគ្នានេះ ការទូទាត់អេឡិចត្រូនិកជាប្រាក់រៀលក៏មាននិន្នាការកើនឡើងបើធៀបនឹងឆ្នាំកន្លងទៅ ស្របពេលជាមួយនឹងកំណើននៃតម្រូវការប្រើប្រាស់ប្រាក់រៀលក្នុងសេដ្ឋកិច្ចដូចមានបង្ហាញក្នុងក្រាហ្វខាងក្រោម។ ជាងនេះទៅទៀត ការទូទាត់ឌីជីថលនេះក៏ជាផ្នែកមួយដ៏សំខាន់ដែលជួយគាំទ្រសកម្មភាពធុរកិច្ចឱ្យអាចបន្តប្រតិបត្តិការជាប្រក្រតី ដែលការណ៍នេះបានជួយកាត់បន្ថយផលប៉ះពាល់នៃជំងឺកូវីដ-១៩ មកលើសេដ្ឋកិច្ចកម្ពុជាបានមួយកម្រិត និងការស្ដារសេដ្ឋកិច្ចឡើងវិញ។ ទន្ទឹមនោះ ការទូទាត់ឌីជីថលក៏បានរួមចំណែកយ៉ាងច្រើនក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងការអនុវត្តគោលនយោបាយសេដ្ឋកិច្ចឌីជីថលរបស់រាជរដ្ឋាភិបាលកម្ពុជា បន្ទាប់ពីរាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រជាតិស្ដីពីបរិយាបន្នហិរញ្ញវត្ថុ ២០១៩-២០២៥ កាលពីឆ្នាំ២០១៩ និងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថល ២០២១-២០៣៥ កាលពីខែឧសភា ឆ្នាំ២០២១។

ក្រាហ្វ ១ - រូបិយវត្ថុក្នុងចរាចរណ៍ និងទំហំប្រាក់ទូទាត់តាមអេឡិចត្រូនិកជាប្រាក់រៀល




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ការទូទាត់តាមរយៈឃ្យូអរកូដជាមធ្យោបាយទូទាត់ថ្មីមួយ ដែលទើបតែលេចឡើងនៅលើទីផ្សារ ប៉ុន្តែទទួលបាននូវការពេញនិយមគួរឱ្យកត់សម្គាល់ក្នុងចំណោមប្រជាជនកម្ពុជា ជាពិសេសប្រជាជនវ័យក្មេងដែលអាចសម្របខ្លួនក្នុងការទទួលយកនូវបច្ចេកវិទ្យាថ្មីៗ ព្រោះការទូទាត់តាមឃ្យូអរកូដមានភាពងាយស្រួល រហ័ស និងមានសុវត្ថិភាព។ ក្រាហ្វខាងក្រោមបង្ហាញថា ការទូទាត់

តាមឃ្យូអរកូតកំពុងបន្តកើនឡើង បើទោះបីជាទំហំនៃការទូទាត់នៅមានកម្រិតធៀបនឹងការទូទាត់តាមប័ណ្ណទូទាត់។ ស្របពេលជាមួយគ្នានេះ ការរីកចម្រើននៃបច្ចេកវិទ្យាទូរគមនាគមន៍ ដូចជា ការរីកចម្រើននៃបច្ចេកវិទ្យាទូរស័ព្ទចល័ត និងអ៊ីនធឺណិត បានរួមចំណែកគាំទ្រ និងផ្តល់ភាពងាយស្រួលយ៉ាងច្រើនក្នុងការធ្វើប្រតិបត្តិការទូទាត់ឌីជីថល និងបានប្រែក្លាយទូរស័ព្ទវៃឆ្លាតឱ្យក្លាយជាមធ្យោបាយទូទាត់មួយដ៏សំខាន់នាពេលបច្ចុប្បន្ន។ ទន្ទឹមនោះ ក្នុងក្របខណ្ឌនៃការធ្វើសមាហរណកម្មប្រព័ន្ធទូទាត់ក្នុងតំបន់អាស៊ាន ការទូទាត់តាមឃ្យូអរកូតក៏បានក្លាយជាការងារអាទិភាពមួយ សម្រាប់ប្រទេសសមាជិកអាស៊ានក្នុងការភ្ជាប់ប្រព័ន្ធទូទាត់រវាងគ្នា។ ជាក់ស្តែង ធនាគារជាតិនៃកម្ពុជាក៏បានដាក់ឱ្យដំណើរការជាផ្លូវការការភ្ជាប់ការទូទាត់តាមឃ្យូអរកូតរវាងប្រទេសកម្ពុជា និងប្រទេសថៃ និងកំពុងបន្តអនុវត្តការងារនេះជាមួយប្រទេសផ្សេងៗទៀតក្នុងតំបន់អាស៊ាន។

ក្រាហ្វ ២ - ប្រតិបត្តិការទូទាត់តាមរយៈប័ណ្ណទូទាត់ និងការស្កេន QR Code




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

សមិទ្ធផលដែលទទួលបានដូចបានរៀបរាប់ខាងលើ ជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរបស់ធនាគារជាតិនៃកម្ពុជាក្នុងការដាក់ចេញនូវក្របខណ្ឌគោលនយោបាយ និងបទប្បញ្ញត្តិដែលគាំទ្រ និងជំរុញដល់នវានុវត្តផ្នែកប្រព័ន្ធទូទាត់។ ដើម្បីបន្តជំរុញការអភិវឌ្ឍប្រព័ន្ធទូទាត់ស្របតាមការរីកចម្រើនយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានរៀបចំ និងដាក់ឱ្យប្រើប្រាស់ផែនទីមគ្គុទ្ទេសក៍អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ២០២០-២០២៥ ដោយបានកំណត់ពីគោលដៅ និងផែនការសកម្មភាពដែលត្រូវអនុវត្តតាមដំណាក់កាល ដើម្បីជំរុញការអភិវឌ្ឍប្រព័ន្ធទូទាត់ឱ្យកាន់តែទំនើបស្របតាមការរីកចម្រើននៃបច្ចេកវិទ្យាឌីជីថល។

## ១.២. គោលនយោបាយគាំទ្រ

ទោះបីជាការទូទាត់តាមរយៈប្រព័ន្ធសេវាទូទាត់រហ័សមានការកើនឡើងក្នុងរយៈពេលថ្មីៗនេះ ប៉ុន្តែការប្រើប្រាស់ប្រព័ន្ធនេះអាចធ្វើបានតែនៅតាមបញ្ជរសាខារបស់គ្រឹះស្ថានសមាជិក ដែលមិនទាន់មានភាពងាយស្រួលសម្រាប់អតិថិជននៅឡើយ។ បច្ចុប្បន្ន គ្រឹះស្ថានសមាជិកមួយចំនួនបានដាក់ឱ្យដំណើរការប្រព័ន្ធនេះតាមសេវាធនាគារអ៊ីនធឺណិត ឬសេវាធនាគារចល័ត ក៏ប៉ុន្តែទំហំប្រតិបត្តិការនៅមានកម្រិតទាបបើធៀបនឹងប្រព័ន្ធផ្សេងៗ។ ម្យ៉ាងទៀត ការអនុវត្តគោលនយោបាយមួយចំនួន និងលក្ខណៈបច្ចេកទេសរបស់ប្រព័ន្ធ ក៏ជាកត្តារួមចំណែកបង្កការលំបាកសម្រាប់អតិថិជនក្នុងការប្រើប្រាស់ផងដែរ។ ជាក់ស្តែង ប្រព័ន្ធសេវាទូទាត់រហ័សអនុញ្ញាតឱ្យធ្វើប្រតិបត្តិការតែជាប្រាក់រៀលប៉ុណ្ណោះ និងមិនទាន់មានមុខងារផ្ទៀងផ្ទាត់ព័ត៌មានអ្នកទទួលផល (Recipient Account Inquiry) នៅឡើយ។ ដើម្បីជំរុញការប្រើប្រាស់ប្រព័ន្ធសេវាទូទាត់រហ័សកាន់តែមានភាពងាយស្រួល និងប្រសិទ្ធភាព ធនាគារជាតិនៃកម្ពុជាបាននិងកំពុងធ្វើទំនើបកម្មប្រព័ន្ធសេវាទូទាត់រហ័សទៅជាប្រព័ន្ធសេវាទូទាត់រហ័សជំនាន់ថ្មី ដោយដាក់ឱ្យប្រើប្រាស់មុខងារថ្មីៗបន្ថែមទៀតតាមដំណាក់កាល។ ដំណាក់កាលទី១ ជាការធ្វើទំនើបកម្មប្រព័ន្ធផ្ទៃក្នុងរបស់គ្រឹះស្ថានសមាជិក (Upgrading the Client Module System) និងការផ្លាស់ប្តូរការតភ្ជាប់មកកាន់ប្រព័ន្ធទូទាត់រហ័សជំនាន់ថ្មី និងដំណាក់កាលទី២ គឺការធ្វើសន្ទានកម្មលើមុខងារថ្មីទាំងបី ដែលរួមមាន ១/.មុខងារផ្ទៀងផ្ទាត់ព័ត៌មានអ្នកទទួលផល (Recipient Account Inquiry) ២/.ផាត់ទាត់និងទូទាត់ប្រតិបត្តិការជារូបិយប័ណ្ណដុល្លារអាមេរិក (US Dollar Transaction) និង ៣/.ការធ្វើប្រតិបត្តិការជាលក្ខណៈស្វ័យប្រវត្តិពេញលេញ (Full Straight Through Processing – STP)។ ធនាគារជាតិនៃកម្ពុជារំពឹងទុកថា បន្ទាប់ពីគ្រឹះស្ថានសមាជិកទាំងអស់បញ្ចប់ការធ្វើទំនើបកម្មប្រព័ន្ធលើគ្រប់មុខងារនឹងធ្វើឱ្យការប្រើប្រាស់ប្រព័ន្ធសេវាទូទាត់រហ័សកាន់តែមានភាពងាយស្រួលសម្រាប់អតិថិជន ហើយចំនួនប្រតិបត្តិការនឹងបន្តកើនឡើងបន្ថែមទៀត។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាក៏កំពុងពិនិត្យលទ្ធភាពភ្ជាប់ប្រព័ន្ធសេវាទូទាត់រហ័សជាមួយប្រព័ន្ធផ្សេងៗទៀតដែលដំណើរការដោយធនាគារជាតិនៃកម្ពុជា ដើម្បីជំរុញអន្តរប្រតិបត្តិការរវាងប្រព័ន្ធទូទាត់ និងជួយសម្រួលអតិថិជនក្នុងការធ្វើប្រតិបត្តិការឆ្លងប្រព័ន្ធ។

ទន្ទឹមនឹងការដាក់ឱ្យអនុវត្តគោលនយោបាយថ្មីៗបន្ថែមទៀតសម្រាប់ប្រព័ន្ធផាត់ទាត់ជាតិ និងប្រព័ន្ធសេវាទូទាត់រហ័ស ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យអនុវត្តវិធាននិងនីតិវិធីរបស់ប្រព័ន្ធរីធែលផេ និងប្រកាសស្តីពី ការដាក់ឱ្យប្រើស្លាកសញ្ញារបស់ប្រព័ន្ធរីធែលផេ ដើម្បីគ្រប់គ្រងកិច្ចដំណើរការរបស់ប្រព័ន្ធរីធែលផេ និងធានាបានសង្គតិភាពក្នុងការប្រើប្រាស់ប្រព័ន្ធជាសាធារណៈ ជាពិសេសរក្សាបាននូវប្រតិបត្តិការប្រព័ន្ធប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព។

ដោយឡែកការប្រើប្រាស់ប័ណ្ណទូទាត់ឥណពន្ធក្នុងស្រុក ក៏នៅមានបញ្ហាប្រឈមមួយចំនួនដែលត្រូវដោះស្រាយផងដែរ។ ការចេញផ្សាយប័ណ្ណទូទាត់ឥណពន្ធក្នុងស្រុកនៅមិនទាន់ឆ្លើយតបទៅនឹងស្តង់ដារសុវត្ថិភាពទាំងស្រុងនៅឡើយ ដោយសារនៅមានគ្រឹះស្ថានមួយចំនួនបាននិងកំពុងចេញផ្សាយប័ណ្ណទូទាត់ដោយប្រើបច្ចេកវិទ្យា Magnetic stripe ដែលត្រូវបានគេជឿថាមានកម្រិតសុវត្ថិភាពទាបក្នុងការការពារអ្នកប្រើប្រាស់ពីការលួចបន្លំផ្សេងៗក្នុងប្រតិបត្តិការទូទាត់។ ទន្ទឹមនោះ

ម៉ាស៊ីន ATM និងម៉ាស៊ីន POS របស់គ្រឹះស្ថានសមាជិកមួយចំនួនក៏នៅមិនទាន់បំពាក់នូវបច្ចេកវិទ្យាសុវត្ថិភាពគ្រប់គ្រាន់នៅឡើយ។ ការប្រើប្រាស់ប័ណ្ណទូទាត់ក៏ដូចជាម៉ាស៊ីន ATM និងម៉ាស៊ីន POS ដែលមានស្តង់ដារសុវត្ថិភាពទាបអាចធ្វើឱ្យគ្រឹះស្ថានផ្តល់សេវា និងអតិថិជនប្រឈមនឹងហានិភ័យផ្សេងៗ ដែលប៉ះពាល់ដល់ផលប្រយោជន៍របស់ពួកគេ ហើយជាលទ្ធផលនឹងធ្វើឱ្យអតិថិជនបាត់បង់នូវជំនឿចិត្តក្នុងការប្រើប្រាស់ប័ណ្ណទូទាត់។ ក្នុងគោលដៅការពារផលប្រយោជន៍អតិថិជន និងលើកកម្ពស់សុវត្ថិភាពនៃការប្រើប្រាស់ប័ណ្ណទូទាត់ ឆ្លើយតបទៅនឹងស្តង់ដារសុវត្ថិភាព និងនិន្នាការនៃការអនុវត្តក្នុងតំបន់ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញសេចក្តីជូនដំណឹងស្តីពី គោលនយោបាយប្រព័ន្ធខេមប៊ូឌានស៊ែស្វីច ដោយតម្រូវឱ្យគ្រឹះស្ថានសមាជិកប្រព័ន្ធខេមបូឌានស៊ែស្វីចអនុវត្តនូវស្តង់ដារ EMV Chip ក្នុងការចេញផ្សាយប័ណ្ណឥណពន្ធក្នុងស្រុក និងគោលការណ៍សុវត្ថិភាពសម្រាប់ម៉ាស៊ីន ATM និងម៉ាស៊ីន POS ដើម្បីរួមចំណែកលើកកម្ពស់ប្រសិទ្ធភាព និងសុវត្ថិភាពនៃការធ្វើប្រតិបត្តិការប័ណ្ណទូទាត់តាមរយៈប្រព័ន្ធខេមប៊ូឌានស៊ែស្វីច។ បច្ចុប្បន្ន គ្រឹះស្ថានសមាជិកបាននិងកំពុងអនុវត្តគោលនយោបាយទាំងនេះក្នុងដំណាក់កាលផ្សេងៗគ្នា។ ការអនុលោមតាមសេចក្តីជូនដំណឹងនេះនឹងរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់ សុវត្ថិភាព ភាពងាយស្រួល កាត់បន្ថយការលួចបន្លំព័ត៌មាន និងពង្រឹងការអនុវត្តតាមស្តង់ដារនៃការប្រើប្រាស់ប័ណ្ណទូទាត់ក្នុងស្រុក។

ទន្ទឹមនោះ ទោះបីជាការទូទាត់ឌីជីថលមាននិន្នាការកើនឡើងយ៉ាងឆាប់រហ័សក្នុងពេលបច្ចុប្បន្ន និងនាពេលអនាគតក៏ដោយ ក៏នៅមានបញ្ហាជាសារវន្តមួយចំនួនដែលចាំបាច់ត្រូវដោះស្រាយដើម្បីបង្កើនសុវត្ថិភាព និងប្រសិទ្ធភាពនៃការទូទាត់ឌីជីថល ព្រមទាំងទទួលបាននូវការជឿទុកចិត្តពីសាធារណជនកាន់តែខ្លាំង។ បញ្ហាចម្បងដែលត្រូវយកចិត្តទុកដាក់នោះ គឺហានិភ័យផ្សេងៗក្នុងការប្រើប្រាស់សេវាទូទាត់ឌីជីថលស្របពេលនឹងការរីកចម្រើនយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ ដែលការណ៍នេះអាចធ្វើឱ្យប៉ះពាល់ផលប្រយោជន៍អតិថិជន និងអាចធ្វើឱ្យអតិថិជនបាត់បង់ជំនឿចិត្ត ហើយងាកមកប្រើប្រាស់សាច់ប្រាក់វិញ។ ខណៈបច្ចេកវិទ្យាកាន់តែទំនើប ហានិភ័យកាន់តែមានភាពស្មុគស្មាញ ដូច្នេះអតិថិជនត្រូវមានការយល់ដឹង និងប្រុងប្រយ័ត្នជានិច្ចចំពោះការប្រើប្រាស់សេវាទូទាត់ឌីជីថល ដើម្បីជៀសវាងឱ្យបាននូវហានិភ័យផ្សេងៗដែលអាចកើតមានឡើង។ ក្នុងន័យនេះ ការចូលរួមពីភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសធនាគារជាតិនៃកម្ពុជា និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ គឺជាការចាំបាច់ក្នុងការអនុវត្តកម្មវិធី ឬយុទ្ធនាការផ្សេងៗដើម្បីលើកកម្ពស់ចំណេះដឹងប្រជាជនកម្ពុជា និងធុរជនឱ្យយល់ច្បាស់អំពីគោលការណ៍សុវត្ថិភាព និងអត្ថប្រយោជន៍នៃការទូទាត់ឌីជីថល ឬដាក់បញ្ចូលកម្មវិធីនេះជាផ្នែកមួយនៃកម្មវិធីលើកកម្ពស់ចំណេះដឹងហិរញ្ញវត្ថុ។ ស្របពេលជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជាក៏បានដាក់ចេញនូវ "គោលការណ៍គ្រប់គ្រងហានិភ័យបច្ចេកវិទ្យាព័ត៌មានវិទ្យា" សម្រាប់គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានផ្តល់សេវាទូទាត់អនុវត្ត ដើម្បីពង្រឹងប្រព័ន្ធសុវត្ថិភាពផ្ទៃក្នុងរបស់ខ្លួនក្នុងការផ្តល់សេវាទូទាត់ឌីជីថលប្រកបដោយសុវត្ថិភាព។

កំណើននៃការទូទាត់តាមរយៈឃ្យូអរកូត ជាសញ្ញាណវិជ្ជមានមួយដែលបង្ហាញឱ្យឃើញពីវឌ្ឍនភាពថ្មីក្នុងវិស័យធនាគារនៅប្រទេសកម្ពុជាផ្សារភ្ជាប់ជាមួយបច្ចេកវិទ្យាហិរញ្ញវត្ថុ។ ទោះជាយ៉ាងនេះក្តី ការទូទាត់តាមរយៈឃ្យូអរកូតបច្ចុប្បន្ននៅមិនទាន់មានភាពងាយស្រួលទាំងស្រុងនៅឡើយ ដោយសារគ្រឹះស្ថានធនាគារ និងគ្រឹះស្ថានផ្តល់សេវាទូទាត់នីមួយៗប្រើប្រាស់នូវស្តង់ដារឃ្យូអរកូត

ផ្សេងៗគ្នា មិនទាន់មានលក្ខណៈស្តង់ដាររួមមួយស្របតាមស្តង់ដារអន្តរជាតិ ដែលធ្វើឱ្យអតិថិជន មិនអាចធ្វើប្រតិបត្តិការឆ្លងគ្រឹះស្ថានបាន។ បន្ថែមពីនេះ អវត្តមាននៃស្តង់ដារឃ្យូអរកូតរួមមួយក៏ជាបញ្ហាប្រឈមសម្រាប់ប្រទេសកម្ពុជាក្នុងការភ្ជាប់ការទូទាត់តាមឃ្យូអរកូតក្នុងតំបន់អាស៊ានផងដែរ។ ដើម្បីដោះស្រាយបញ្ហានេះ កាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ ធនាគារជាតិនៃកម្ពុជាសហការជាមួយសមាគមធនាគារនៅកម្ពុជា និងភាគីពាក់ព័ន្ធបានរៀបចំ និងដាក់ឱ្យប្រើប្រាស់ប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់គំរូបរិច្ឆិនភាពបច្ចេកទេសខេអេចឃ្យូអរកូត (KHQR Code) សម្រាប់ការទូទាត់សងប្រាក់ ដែលជាស្តង់ដារឃ្យូអរកូតសម្រាប់ការទូទាត់នៅកម្ពុជាស្របតាមស្តង់ដារអន្តរជាតិ EMV។ ការដាក់ឱ្យប្រើប្រាស់ស្តង់ដារខេអេចឃ្យូអរកូតនឹងរួមចំណែកលើកកម្ពស់អន្តរប្រតិបត្តិការនៃការទូទាត់តាមឃ្យូអរកូតឆ្លងគ្រឹះស្ថានសម្រាប់អតិថិជន ព្រមទាំងផ្តល់លទ្ធភាពសម្រាប់ប្រទេសកម្ពុជាក្នុងការធ្វើសមាហរណកម្មការទូទាត់ក្នុងតំបន់ផងដែរ។

## ១.៣. ជំហានបន្ទាប់

ដើម្បីសម្រេចបាននូវគោលដៅនៃការអនុវត្តគោលនយោបាយដូចបានរៀបរាប់ខាងលើ ការផ្តល់ការគាំទ្រនិងកិច្ចសហការដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលជាសមាជិកប្រព័ន្ធ និងភាគីពាក់ព័ន្ធគឺជាកត្តាចាំបាច់។ ក្រុមការងារអភិវឌ្ឍប្រព័ន្ធសេវាទូទាត់រហ័សរបស់ធនាគារជាតិនៃកម្ពុជា នៅតែបន្តផ្តល់កិច្ចសហការ ការណែនាំ និងគាំទ្រយ៉ាងពេញលេញដល់គ្រឹះស្ថានជាសមាជិកទាំងអស់ ដើម្បីជំរុញឱ្យគ្រឹះស្ថានជាសមាជិកទាំងនោះមានលទ្ធភាពក្នុងការធ្វើទំនើបកម្មប្រព័ន្ធសេវាទូទាត់រហ័សជំនាន់ថ្មីបានដោយជោគជ័យតាមដំណាក់កាលនីមួយៗ។ ម្យ៉ាងទៀត ក្នុងគោលបំណងបង្កើនប្រសិទ្ធភាពនៃការអនុលោមតាមសេចក្តីជូនដំណឹងស្តីពី គោលនយោបាយប្រព័ន្ធខេមប៊ូខានស៊ើស្វីច ធនាគារជាតិនៃកម្ពុជានឹងបន្តតាមដានវឌ្ឍនភាព និងសហការជាមួយគ្រឹះស្ថានសមាជិក និងភាគីពាក់ព័ន្ធដើម្បីដោះស្រាយបញ្ហានានាដែលកើតមានឡើង ដើម្បីអាចឱ្យការអនុវត្តគោលនយោបាយដែលមានចែងក្នុងសេចក្តីជូនដំណឹងសម្រេចបានតាមគោលដៅ។ ធនាគារជាតិនៃកម្ពុជាក៏នឹងបន្តគាំទ្រដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងការអនុវត្តខេអេចឃ្យូអរកូត ដើម្បីឱ្យការអនុវត្តស្តង់ដារឃ្យូអរកូតសម្រាប់ការទូទាត់អាចសម្រេចបានទាំងស្រុងក្នុងការត្រៀមខ្លួនសម្រាប់ការធ្វើអន្តរប្រតិបត្តិការទូទាត់តាមរយៈឃ្យូអរកូតទាំងក្នុងប្រទេសកម្ពុជានិងក្នុងតំបន់។

ដើម្បីជំរុញការប្រើប្រាស់សេវាទូទាត់ឌីជីថលប្រកបដោយសុវត្ថិភាពនិងនិរន្តរភាព ការបង្កើនការយល់ដឹងដល់សាធារណជនអំពីរបៀបប្រើប្រាស់ឱ្យបានទូលំទូលាយគឺជាកត្តាចាំបាច់ និងទាមទារឱ្យមានការរៀបចំជាក្របខណ្ឌ និងផែនការសកម្មភាពផ្សេងៗក្រោមកិច្ចសហការជាមួយគ្រប់ភាគីពាក់ព័ន្ធក្នុងការអនុវត្តផែនការលើកកម្ពស់ចំណេះដឹងឌីជីថលទទួលបានប្រសិទ្ធភាពខ្ពស់។ ទន្ទឹមនោះ ធនាគារជាតិនៃកម្ពុជាក៏ត្រូវបន្តតាមដាននិងគាំទ្រដល់គ្រឹះស្ថានទាំងអស់ដែលផ្តល់សេវាទូទាត់តាមឃ្យូអរកូតក្នុងការអនុវត្តខេអេចឃ្យូអរកូត ដើម្បីឈានទៅសម្រេចបានទាំងស្រុងនូវការអនុវត្តស្តង់ដារឃ្យូអរកូតសម្រាប់ការទូទាត់ក្នុងប្រទេសកម្ពុជា និងការធ្វើប្រតិបត្តិការឆ្លងគ្រឹះស្ថានបានក្នុងពេលឆាប់ៗខាងមុខ។

# ២. ការអភិវឌ្ឍប្រព័ន្ធបាគង

ការអភិវឌ្ឍប្រព័ន្ធទូទាត់ជាការងារអាទិភាពមួយរបស់ធនាគារជាតិនៃកម្ពុជាក្នុងការរួមចំណែកអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងសេដ្ឋកិច្ចឌីជីថលប្រកបដោយបរិយាបន្ននៅកម្ពុជា។ ក្នុងការធ្វើទំនើបកម្មប្រព័ន្ធទូទាត់សងប្រាក់ជាតិ កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការជាផ្លូវការប្រព័ន្ធបាគងដែលប្រើប្រាស់បច្ចេកវិទ្យាប្លុកឆេន។ ប្រព័ន្ធបាគងជាប្រព័ន្ធទូទាត់កន្លោងអភិវឌ្ឍឡើងដើម្បីសម្រួលដល់ប្រតិបត្តិការឆ្លងគ្រឹះស្ថាន បង្កើនប្រសិទ្ធភាពក្នុងប្រព័ន្ធទូទាត់ លើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងសម្រួលប្រតិបត្តិការទូទាត់ជាប្រាក់រៀល។ ការដាក់ឱ្យប្រើប្រព័ន្ធបាគងបានផ្តល់អត្ថប្រយោជន៍បន្ថែមដល់សាធារណជនអាចធ្វើប្រតិបត្តិការផ្ទេរប្រាក់និងទូទាត់តាមឃ្យូអរកូតឆ្លងគ្រឹះស្ថានបានភ្លាមៗ ចំណាយប្រតិបត្តិ-ការទាប និងមានសុវត្ថិភាព។ បច្ចុប្បន្នប្រព័ន្ធបាគងមានសមាជិកសរុបចំនួន ៥៥ ដោយក្នុងនោះមានគ្រឹះស្ថានចំនួន ២៥ បានដាក់ឱ្យដំណើរការជាផ្លូវការ និងគ្រឹះស្ថានចំនួន ៣០ ទៀតបាននិងកំពុងបន្តធ្វើសន្ធានកម្មប្រព័ន្ធ (ដូចមានចែងក្នុងឧបសម្ព័ន្ធ២)។




## ២.១. វឌ្ឍនភាព និងសមិទ្ធផលនៃប្រព័ន្ធបាគង

### ២.១.១. អតិថិជនចុះឈ្មោះប្រើប្រាស់ប្រព័ន្ធបាគង

គិតត្រឹមឆមាសទី១ ឆ្នាំ២០២១ អតិថិជនចុះឈ្មោះប្រើប្រាស់បាគងតាមរយៈកម្មវិធីបាគងមានចំនួន ១៨២,៤ ពាន់គណនី កើនឡើង ១.១៨៤,៥% បើធៀបនឹងឆមាសទី១ ឆ្នាំ២០២០។

**ក្រាហ្វ ៣ - ចំនួនអតិថិជនចុះឈ្មោះប្រើប្រាស់ជាមួយកម្មវិធីបាគង**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### ២.១.២. ប្រតិបត្តិការប្រព័ន្ធបាគង

ក្នុងឆមាសទី១ ឆ្នាំ២០២១ ប្រតិបត្តិការផ្ទេរប្រាក់និងទូទាត់ដែលធ្វើឡើងតាមរយៈប្រព័ន្ធបាគង មានចំនួន ២,២៤ លានប្រតិបត្តិការ (០,៤៨ លានប្រតិបត្តិការ ជាប្រាក់រៀល និង ១,៧៦ លានប្រតិបត្តិការ ជាប្រាក់ដុល្លារអាមេរិក) និងមានទំហំប្រាក់ជាប្រាក់រៀលចំនួន ៦៤៩,៥២ ប៊ីលានរៀល និងជាប្រាក់ដុល្លារអាមេរិកចំនួន ៦៥១,២៤ លានដុល្លារអាមេរិក។ បន្ទាប់ពីដាក់ដំណើរការប្រព័ន្ធបាគងបានបង្ហាញឱ្យឃើញថា ប្រតិបត្តិការជាប្រាក់រៀលមានការកើនឡើង បើធៀបនឹងប្រតិបត្តិការទូទាត់សងប្រាក់ជាអេឡិចត្រូនិកតាមមធ្យោបាយផ្សេងៗមុនការដាក់ដំណើរការប្រព័ន្ធបាគង។

**ក្រាហ្វ ៤ - ប្រតិបត្តិការធ្វើឡើងតាមរយៈប្រព័ន្ធបាគង**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៥ - ទំហំប្រតិបត្តិការទូទាត់សងប្រាក់ជាអេឡិចត្រូនិក មុនដាក់និងបន្ទាប់ពីបានដាក់ដំណើរការប្រព័ន្ធបាគង**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ២.២. ការអភិវឌ្ឍបន្ត

ធនាគារជាតិនៃកម្ពុជា បាននិងកំពុងអនុវត្តការងារជាច្រើនទៀតដើម្បីជំរុញការប្រើប្រាស់ប្រព័ន្ធបាគងឱ្យកាន់តែមានភាពងាយស្រួល សុវត្ថិភាព និងកាន់តែទូលំទូលាយ។ ការងារសម្រាប់អភិវឌ្ឍប្រព័ន្ធបាគងជំហានបន្ទាប់រួមមាន៖

### ២.២.១. ប្រព័ន្ធបាគងជាមជ្ឈមណ្ឌលទូទាត់

បច្ចុប្បន្ន គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក៏ដូចជាគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់បាននិងកំពុងប្រកួតប្រជែងដាក់ឱ្យប្រើប្រាស់សេវាទូទាត់តាមយូអរកូដជាបន្តបន្ទាប់ព្រោះការទូទាត់តាមមធ្យោបាយនេះកំពុងទទួលបានប្រជាប្រិយភាពពីសំណាក់អតិថិជន ដោយសារមានភាពងាយស្រួល រហ័ស សុវត្ថិភាព និងមានកម្រៃប្រតិបត្តិការទាប។ ទន្ទឹមនោះ បណ្តាប្រទេសសមាជិកអាស៊ានក៏បានកំណត់យកការទូទាត់តាមរយៈយូអរកូដជាមធ្យោបាយសម្រាប់ការធ្វើសមាហរណកម្មប្រព័ន្ធទូទាត់រាយភ្លាមៗក្នុងតំបន់អាស៊ានផងដែរ។ ទោះជាយ៉ាងនេះក្តី ការទូទាត់តាមរយៈយូអរកូដនៅកម្ពុជានៅពុំទាន់មានប្រសិទ្ធភាពពេញលេញនៅឡើយ ដោយសារគ្រឹះស្ថានធនាគារ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់បានប្រើប្រាស់នូវយូអរកូដដែលពុំមានស្តង់ដាររួម និងពុំទាន់មានមជ្ឈមណ្ឌលទូទាត់មួយដែលអាចសម្រួលការទូទាត់តាមយូអរកូដឆ្លងគ្រឹះស្ថានបាននៅឡើយ។ ដើម្បីដោះស្រាយបញ្ហាប្រឈមនេះ ឆ្លើយតបទៅនឹងតម្រូវការទីផ្សារ ជាជំហានដំបូង ធនាគារជាតិនៃកម្ពុជាសហការជាមួយសមាគមធនាគារនៅកម្ពុជាបានអភិវឌ្ឍស្តង់ដារយូអរកូដ ដោយអនុលោមតាមស្តង់ដារយូអរកូដ EMV។ ជាលទ្ធផល ខេអេចយូអរកូដដែលជាស្តង់ដារយូអរកូដសម្រាប់ប្រទេសកម្ពុជាត្រូវបានបង្កើត និងដាក់ឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអនុវត្តកាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ តាមរយៈប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់គំរូបរិច្ឆិនភាពបច្ចេកទេសខេអេចយូអរកូដ។ នៅជំហានបន្ទាប់ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងអភិវឌ្ឍប្រព័ន្ធបាគងបន្តទៀត ដើម្បីអាចបំពេញមុខងារជាមជ្ឈមណ្ឌលទូទាត់ដែលអាចភ្ជាប់ទៅបណ្តាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីសម្រួលការទូទាត់ឆ្លងគ្រឹះស្ថានតាមរយៈខេអេចយូអរកូដ។ ការដាក់ឱ្យប្រើប្រាស់ស្តង់ដារយូអរកូដ និងការអភិវឌ្ឍមជ្ឈមណ្ឌលទូទាត់ជាកត្តារួមចំណែកមួយយ៉ាងសំខាន់ក្នុងការបង្កើនប្រសិទ្ធភាពប្រព័ន្ធទូទាត់ក្នុងស្រុក និងលទ្ធភាពក្នុងការធ្វើសមាហរណកម្មប្រព័ន្ធទូទាត់ក្នុងតំបន់។

### ២.២.២. ប្រព័ន្ធបាគងសម្រាប់ការផ្ទេរប្រាក់ និងទូទាត់ឆ្លងដែន

ការទូទាត់ឆ្លងដែនបានដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការធ្វើសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់និងក្នុងពិភពលោក ជាពិសេសក្នុងតំបន់អាស៊ាន។ ទន្ទឹមនោះ ការផ្ទេរប្រាក់ឆ្លងដែននឹងរួមចំណែកលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ តាមរយៈការផ្តល់មធ្យោបាយសម្រួលដល់ការផ្ទេរប្រាក់ និង



ទូទាត់ទំនិញមានកម្រៃទាបសម្រាប់ពលករដែលធ្វើការនៅក្រៅប្រទេស និងអ្នកធុរកិច្ច។ ដោយពិនិត្យឃើញពីអត្ថប្រយោជន៍នេះ កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ ធនាគារជាតិនៃកម្ពុជាបានចុះអនុស្សរណៈយោគយល់ជាមួយធនាគារមេយប៊ែង ដើម្បីជំរុញការផ្ទេរប្រាក់និងទូទាត់ឆ្លងដែនរវាងប្រទេសកម្ពុជា និងប្រទេសម៉ាឡេស៊ី តាមរយៈប្រព័ន្ធបាគងរបស់ធនាគារជាតិនៃកម្ពុជា និងផ្លែតហ្វមឌីជីថលមេយប៊ែងធូយូរបស់ធនាគារមេយប៊ែង។ គម្រោងនេះបានដាក់ឱ្យដំណើរការកាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០២១ កន្លងទៅ ដែលនឹងរំពឹងថាផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនរបស់ប្រទេសទាំងពីរ ជាពិសេស ពលករកម្ពុជាដែលកំពុងរស់នៅ និងធ្វើការនៅប្រទេសម៉ាឡេស៊ី និងប្រជាជនម៉ាឡេស៊ីដែលកំពុងរស់នៅប្រទេសកម្ពុជា ក៏ដូចជាអ្នកធុរកិច្ចដើម្បីផ្ទេរមូលនិធិឆ្លងប្រទេសសម្រាប់ការទូទាត់ពាណិជ្ជកម្ម និងការផ្ទេរប្រាក់បានភ្លាមៗក្នុងតម្លៃសមរម្យ។

### ២.២.៣. ប្រព័ន្ធបាគងសម្រាប់ប្រព័ន្ធទូទាត់តម្លៃធំ




បន្ទាប់ពីដាក់ឱ្យដំណើរការប្រព័ន្ធបាគងសម្រាប់ប្រព័ន្ធទូទាត់រាយ ធនាគារជាតិនៃកម្ពុជាបានបន្តសិក្សាលទ្ធភាពក្នុងការអភិវឌ្ឍប្រព័ន្ធបាគងសម្រាប់ការទូទាត់តម្លៃធំ។ ការសិក្សាផ្តោតសំខាន់លើបទពិសោធន៍របស់ប្រទេសនានាដែលកំពុងធ្វើតេស្តសាកល្បងលើការប្រើប្រាស់បច្ចេកវិទ្យា DLT សម្រាប់ការទូទាត់តម្លៃធំ ក៏ដូចជាផលប៉ះពាល់លើគោលនយោបាយរូបិយវត្ថុ និងស្ថិរភាពហិរញ្ញវត្ថុ ព្រមទាំងហានិភ័យផ្សេងៗ។ បច្ចុប្បន្ន មានធនាគារកណ្តាល និងស្ថាប័នពាក់ព័ន្ធជាច្រើនទាំងក្នុងតំបន់ និងពិភពលោក បាននិងកំពុងសិក្សាអំពីអត្ថប្រយោជន៍នៃបច្ចេកវិទ្យា DLT និងធ្វើតេស្តសាកល្បងបច្ចេកវិទ្យានេះក្នុងការគាំទ្រដល់ការទូទាត់តម្លៃធំ និងការទូទាត់ឆ្លងដែនជាដើម។ ទន្ទឹមនោះ កាលពីខែវិច្ឆិកា ឆ្នាំ២០១៩ ក្រុមការងារធនាគារជាតិនៃកម្ពុជាបានទៅបំពេញទស្សនកិច្ចសិក្សានៅប្រទេសថៃ ដើម្បីសិក្សាពីបទពិសោធន៍របស់ធនាគារកណ្តាលថៃក្នុងការអនុវត្តគម្រោង Inthanon ដែលជាគម្រោងសិក្សាអំពីលទ្ធភាពប្រើប្រាស់បច្ចេកវិទ្យា DLT សម្រាប់ការទូទាត់ដុលភ្លាមៗផងដែរ។ ការអភិវឌ្ឍប្រព័ន្ធបាគងសម្រាប់ការទូទាត់តម្លៃធំត្រូវបានអនុវត្តជាដំណាក់កាល ដែលក្នុងនោះមុខងារមូលដ្ឋានរបស់ប្រព័ន្ធនឹងត្រូវបានអភិវឌ្ឍក្នុងដំណាក់កាលដំបូង ចំណែកឯមុខងារសំខាន់ៗផ្សេងទៀតនឹងត្រូវអភិវឌ្ឍក្នុងដំណាក់កាលជាបន្តបន្ទាប់។ បច្ចុប្បន្ន ក្រុមការងារធនាគារជាតិនៃកម្ពុជាកំពុងរៀបចំឯកសារគតិយុត្តស្តីពីវិធាននិងនីតិវិធី ដើម្បីគាំទ្រដំណើរការប្រព័ន្ធនេះ។ ការអនុវត្តគម្រោងបាគងសម្រាប់ប្រព័ន្ធទូទាត់តម្លៃធំនឹងរួមចំណែកលើកកម្ពស់ប្រសិទ្ធភាព និងសុវត្ថិភាពការទូទាត់តម្លៃធំឱ្យកាន់តែប្រសើរឡើង ស្របតាមនិន្នាការនៃការអភិវឌ្ឍប្រព័ន្ធទូទាត់ក្នុងតំបន់ និងសកល។

### ២.២.៤. ប្រព័ន្ធបាគងជាផ្លែតហ្វមធនាគារបើកចំហ

ដើម្បីសម្រួលដល់អតិថិជនក្នុងការធ្វើប្រតិបត្តិការរវាងគណនីបាគងនិងគណនីធនាគារ និងរវាងគណនីធនាគារនិងគណនីធនាគារតាមរយៈប្រព័ន្ធបាគង ធនាគារជាតិនៃកម្ពុជាបាននិងកំពុងបន្តអភិវឌ្ឍប្រព័ន្ធបាគងបន្ថែមទៀតលើមុខងារធនាគារបើកចំហ ដែលអនុញ្ញាតឱ្យប្រព័ន្ធបាគងអាចបំពេញមុខងារផ្ទៀងផ្ទាត់គណនីអ្នកទទួលផល និងមុខងារភ្ជាប់ទៅគណនីធនាគារតាមរយៈកម្មវិធីប្រព័ន្ធបាគង។ បច្ចុប្បន្ន ក្រុមការងារបានបញ្ចប់ការអភិវឌ្ឍមុខងារផ្ទៀងផ្ទាត់គណនីអ្នកទទួលផលសម្រាប់ប្រតិបត្តិការពីគណនីបាគងទៅគណនីធនាគារ និងកំពុងបន្តអភិវឌ្ឍមុខងារនេះសម្រាប់ប្រតិបត្តិការពីគណនីធនាគារទៅគណនីធនាគារ។ ទន្ទឹមនោះ ធនាគារជាតិនៃកម្ពុជាក៏កំពុងបន្តអភិវឌ្ឍមុខងារភ្ជាប់គណនីបាគងជាមួយគណនីធនាគារដើម្បីសម្រួលដល់អតិថិជន ជាពិសេសអតិថិជនរបស់គ្រឹះស្ថានធនាគារដែលមិនទាន់មានកម្មវិធីធនាគារចល័តដោយខ្លួនឯង ក្នុងការទាញយកមូលនិធិពីគណនីធនាគារចូលគណនីបាគងដោយប្រើប្រាស់កម្មវិធីប្រព័ន្ធបាគង។ ការដាក់ឱ្យប្រើប្រាស់មុខងារទាំងនេះនឹងកាត់បន្ថយបានជាអតិបរមានូវកំហុសឆ្គងក្នុងការធ្វើប្រតិបត្តិការផ្ទេរប្រាក់ខុសគណនី រួមចំណែកបង្កើនភាពងាយស្រួល និងជំនឿចិត្តរបស់អតិថិជនក្នុងការប្រើប្រាស់ប្រព័ន្ធបាគង។ ទន្ទឹមនោះ ធនាគារជាតិនៃកម្ពុជាក៏កំពុងពិនិត្យលទ្ធភាព និងសិក្សាលក្ខណៈបច្ចេកទេសដាក់ឱ្យអនុវត្តមុខងារប្តូរប្រាក់នៅក្នុងប្រព័ន្ធបាគង ដែលអាចឱ្យអតិថិជនងាយស្រួលក្នុងការធ្វើប្រតិបត្តិការផ្ទេរប្រាក់រវាងគណនីបាគងជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិកបានដោយប្រើប្រាស់អត្រាប្តូរប្រាក់របស់គ្រឹះស្ថានសមាជិកសាមី។

### ២.២.៥. ការលើកកម្ពស់ចំណេះដឹង និងការផ្សព្វផ្សាយជំរុញការប្រើប្រាស់ប្រព័ន្ធបាគង

ក្នុងគោលដៅបង្កើនការយល់ដឹងអំពីប្រព័ន្ធបាគង ធនាគារជាតិនៃកម្ពុជាបាននិងកំពុងអនុវត្តកម្មវិធីបណ្តុះបណ្តាលមន្ត្រីរបស់ធនាគារជាតិនៃកម្ពុជានៅតាមបណ្តាសាខាខេត្តមួយចំនួន ដោយផ្តោតសំខាន់លើផ្នែកសំខាន់ៗរួមមាន ហេដ្ឋារចនាសម្ព័ន្ធ មុខងារ របៀបប្រើប្រាស់ និងវិធាននិងនីតិវិធីប្រព័ន្ធជាដើម។ នៅក្នុងឆ្នាំ២០២១ នេះ ធនាគារជាតិនៃកម្ពុជានឹងបន្តអនុវត្តការងារនេះតាមផែនការនៅតាមសាខារបស់ធនាគារជាតិនៃកម្ពុជាបន្ថែមទៀត។ ទន្ទឹមនោះ ដើម្បីឱ្យសាធារណជនយល់ដឹងកាន់តែច្បាស់ និងចូលរួមប្រើប្រាស់ប្រព័ន្ធបាគង ធនាគារជាតិនៃកម្ពុជាបានរៀបចំជាឃ្លីបវីឌីអូពាណិជ្ជកម្មខ្លីៗអំពីប្រព័ន្ធបាគងសម្រាប់ផ្សព្វផ្សាយតាមបណ្តាញផ្សព្វផ្សាយនានា។ ជំហានដំបូង ការផ្សព្វផ្សាយត្រូវបានធ្វើឡើងតាមគេហទំព័របាគង ព្រមទាំងបណ្តាញសង្គមហ្វេសប៊ុក និងយូធូប។ បច្ចុប្បន្នសកម្មភាពនៃការផ្សព្វផ្សាយត្រូវបានពង្រីកបន្ថែមទៀតនៅតាមបណ្តាញទូរទស្សន៍ និងគេហទំព័រទូរទស្សន៍អនឡាញ។ ជាមួយគ្នានោះ ធនាគារជាតិនៃកម្ពុជាក៏បានជំរុញឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលជាសមាជិកចូលរួមផ្សព្វផ្សាយប្រព័ន្ធបាគងឱ្យកាន់តែទូលំទូលាយតាមបណ្តាញផ្សព្វផ្សាយរបស់ខ្លួនផងដែរ។



## ប្រអប់ ១ - ការអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ

ក្នុងនាមជាធនាគារកណ្តាល ធនាគារជាតិនៃកម្ពុជាបានដើរតួជានិយ័តករយ៉ាងសំខាន់ ក្នុងការរក្សាតុល្យភាពរវាងគុណសម្បត្តិនៃបច្ចេកវិទ្យាហិរញ្ញវត្ថុសម្រាប់បរិយាបន្នហិរញ្ញវត្ថុ និងផលប៉ះពាល់សេដ្ឋកិច្ច ដែលបច្ចេកវិទ្យាហិរញ្ញវត្ថុអាចបង្កឡើង ជាពិសេសក្នុងវិស័យហិរញ្ញវត្ថុ។ នារយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ បច្ចេកវិទ្យាហិរញ្ញវត្ថុបានចាប់ផ្តើមរីកចម្រើនខ្លាំងនៅប្រទេសកម្ពុជា។ ល្បឿននៃនវានុវត្តន៍បច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងការអភិវឌ្ឍផលិតផល និងទីផ្សារ បានធ្វើឱ្យគ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការដូចជា គ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុមានសក្តានុពលបោះជំហានទៅមុខយ៉ាងឆាប់រហ័ស។

បច្ចេកវិទ្យាហិរញ្ញវត្ថុដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងប្រតិបត្តិការឌីជីថលនៅក្នុងប្រទេសកម្ពុជា។ ដោយមើលឃើញពីសក្តានុពលរបស់បច្ចេកវិទ្យាហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានយកចិត្តទុកដាក់ក្នុងការរៀបចំក្របខណ្ឌគតិយុត្តដែលគាំទ្រដល់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ជាពិសេសផ្តល់លទ្ធភាពឱ្យសហគ្រាសធុនតូចនិងមធ្យម ព្រមទាំងអ្នកប្រើប្រាស់អាចទទួលបានសេវាទូទាត់សងប្រាក់ដែលគាំទ្រដោយបច្ចេកវិទ្យាហិរញ្ញវត្ថុ។ ទោះបីជាមានការរំពឹងទុកពីលទ្ធផលវិជ្ជមានដែលនឹងទទួលបានពីការអភិវឌ្ឍក្នុងដំណាក់កាលដំបូងក៏ដោយ ក៏ការវិវត្តន៍ឥតឈប់ឈរនៃបច្ចេកវិទ្យាហិរញ្ញវត្ថុបានជំរុញឱ្យធនាគារជាតិនៃកម្ពុជាពង្រឹងក្របខណ្ឌគតិយុត្ត ដើម្បីធានាបច្ចេកវិទ្យាហិរញ្ញវត្ថុមានសុវត្ថិភាព និងស្ថិរភាព ព្រមទាំងគាំទ្រដល់ហេដ្ឋារចនាសម្ព័ន្ធចម្បងៗ ដើម្បីធ្វើឱ្យប្រតិបត្តិការទូទាត់ឆ្លងអន្តរគ្រឹះស្ថានកាន់តែប្រសើរ និងមានប្រសិទ្ធភាពផងដែរ។

ម្យ៉ាងវិញទៀត បច្ចេកវិទ្យាហិរញ្ញវត្ថុមានសក្តានុពលខ្ពស់ក្នុងការកាត់បន្ថយចំណាយថ្លៃដើមលើសេវាហិរញ្ញវត្ថុ និងលើកកម្ពស់ការទទួលបានសេវាហិរញ្ញវត្ថុសម្រាប់ប្រជាជនមានប្រាក់ចំណូលទាប ដែលមិនមានលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុទូទៅ។ ប៉ុន្តែបច្ចេកវិទ្យាហិរញ្ញវត្ថុក៏អាចបង្កឱ្យមានហានិភ័យផ្សេងៗពាក់ព័ន្ធនឹងការលួចបន្លំ ការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម សន្តិសុខសាយប័រ និងការបំពានលើឯកជនភាពរបស់បុគ្គល។ ដូច្នេះ ធនាគារជាតិនៃកម្ពុជាបានព្យាយាមរក្សាតុល្យភាពរវាងគុណសម្បត្តិ និងហានិភ័យ ក្នុងការទទួលយកនិងប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុ ដោយមិនធ្វើឱ្យប៉ះពាល់វិស័យធនាគារនិងហិរញ្ញវត្ថុទូទៅនៅកម្ពុជា។

ដោយមានជំនួយបច្ចេកទេសពីធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារជាតិនៃកម្ពុជាបានរៀបចំផែនទីមគ្គុទ្ទេសក៍អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុសម្រាប់រយៈពេល ៥ឆ្នាំ។ ផែនទីមគ្គុទ្ទេសក៍អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុពន្យល់អំពីការអនុវត្តវិធានការពាក់ព័ន្ធនឹងសសរស្តម្ភ និងការអនុវត្តគោលនយោបាយផ្អែកលើក្របខណ្ឌទស្សនទាននៃ "រចនាសម្ព័ន្ធបច្ចេកវិទ្យា

ហិរញ្ញវត្ថុ" រួមមាន សេវាគាំទ្រដោយបច្ចេកវិទ្យាហិរញ្ញវត្ថុ បច្ចេកវិទ្យាគាំទ្រ និងគោលនយោបាយជំរុញ។

ផែនទីមគ្គុទ្ទេសក៍អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ មានទស្សនៈវិស័យក្នុងការបណ្តុះបរិវត្តកម្មឌីជីថលក្នុងវិស័យធនាគារ ស្របតាមរបៀបវារៈរបស់រាជរដ្ឋាភិបាលស្តីពី ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា និងមានវិសាលភាពគ្របដណ្តប់លើបច្ចេកវិទ្យាហិរញ្ញវត្ថុដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ធនាគារជាតិនៃកម្ពុជា ហើយមានទិសដៅដូចខាងក្រោម៖

១. ដាក់ឱ្យអនុវត្តនូវគោលនយោបាយ និងបទប្បញ្ញត្តិជាប្រព័ន្ធដែលផ្តល់តុល្យភាពរវាងហានិភ័យ និងកាលានុវត្តភាព

២. សម្រួលដល់ការផ្តល់សេវា និងផលិតផលបច្ចេកវិទ្យាហិរញ្ញវត្ថុ និងគំរូធុរកិច្ចប្រកបដោយនវានុវត្តន៍ដែលមានប្រសិទ្ធភាពជាងមុន

៣. ជំរុញការប្រើប្រាស់សេវា និងផលិតផលបច្ចេកវិទ្យាហិរញ្ញវត្ថុឱ្យបានទូលំទូលាយ ដែលអាចប្រើប្រាស់បានក្នុងតម្លៃសមរម្យ ដើម្បីលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា។



## ៣. ការត្រួតពិនិត្យតាមដានប្រព័ន្ធទូទាត់សងប្រាក់

ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យដែលបានកំណត់ដោយច្បាប់ ធនាគារជាតិនៃកម្ពុជាមានសិទ្ធិអំណាចក្នុងការត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ ដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ការត្រួតពិនិត្យនេះ អនុវត្តឡើងក្នុងគោលដៅរក្សាសុវត្ថិភាព និងប្រសិទ្ធភាពរបស់ប្រព័ន្ធ និងដើម្បីធានាថាប្រព័ន្ធទាំងនោះគោរពតាមបទដ្ឋានស្តង់ដារ ដែលនឹងរួមចំណែកដល់ដំណើរការស្ថិរភាពនៃប្រព័ន្ធហិរញ្ញវត្ថុទាំងមូល។ ធនាគារជាតិនៃកម្ពុជាត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ ដោយអនុលោមទៅតាមបទដ្ឋានស្តង់ដារ គោលការណ៍ហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ (PFMI) ដែលជាគោលការណ៍ស្នូលរៀបចំឡើងដោយគណៈកម្មការប្រព័ន្ធទូទាត់និងផាត់ទាត់ និងគណៈកម្មការមូលបត្រអន្តរជាតិ (CPSS and IOSCO)។




### ៣.១. និន្នាការទូទៅនៃហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់

#### ៣.១.១. ប្រព័ន្ធផាត់ទាត់ជាតិ - NCS

បន្ទាប់ពីដាក់ដំណើរការជាផ្លូវការអស់រយៈពេល ១១ឆ្នាំ មកឃើញថា ប្រព័ន្ធផាត់ទាត់ជាតិបានរួមចំណែកយ៉ាងសំខាន់ក្នុងការសម្រួលដល់ការផាត់ទាត់និងទូទាត់ជាលក្ខណៈមជ្ឈការលើប្រតិបត្តិការអន្តរធនាគារតាមរយៈមូលប្បទានបត្រ និងបញ្ជាផ្ទេរឥណទានទាំងជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក រវាងគ្រឹះស្ថានជាសមាជិកនៃប្រព័ន្ធផាត់ទាត់ជាតិប្រកបដោយប្រសិទ្ធភាព និងភាពងាយស្រួល។ ប្រព័ន្ធផាត់ទាត់ជាតិមានគ្រឹះស្ថានជាសមាជិកចំនួន ៥២ ដែលក្នុងនោះគ្រឹះស្ថានចំនួន ៣៥ ជាសមាជិកផ្ទាល់របស់ប្រព័ន្ធរួមទាំងធនាគារជាតិនៃកម្ពុជាផងដែរ និង ១៧ គ្រឹះស្ថានជាសមាជិកមិនផ្ទាល់។

ប្រព័ន្ធផាត់ទាត់ជាតិ ជាប្រព័ន្ធដែលផាត់ទាត់ និងទូទាត់ឧបករណ៍ទូទាត់ច្រើនជាងគេក្នុងបណ្ដាប្រព័ន្ធទូទាត់ដែលដំណើរការដោយធនាគារជាតិនៃកម្ពុជា។ ឧបករណ៍ទាំងនោះរួមមាន មូលប្បទានបត្រ (Checks) និងបញ្ជាទូទាត់សងប្រាក់ជាអេឡិចត្រូនិក (Electronic Payment Orders)។

### ក)- មូលប្បទានបត្រ

គិតត្រឹមឆមាសទី១ ឆ្នាំ២០២១ ដោយសារមាននិន្នាការកើនឡើងនៃប្រតិបត្តិការឌីជីថលជាពិសេសក្នុងអំឡុងពេលបិទខ្ទប់ និងការរីករាលដាលនៃជំងឺកូវីដ-១៩ ចំនួនមូលប្បទានបត្រជាប្រាក់រៀលមានការថយចុះ ១២,៧៦% ពី ១៧.៩៦៦ សន្លឹក មក ១៥.៦៧៣ សន្លឹក រីឯទំហំប្រាក់ក៏មានការថយចុះ ៣១,៩១% ពី ១៤.០២៧,៧៥ ប៊ីលានរៀល មកត្រឹម ៩.៦២១,៩០ ប៊ីលានរៀល ដែលមានទំហំប្រាក់ប្រមាណជាង ៩,៣% នៃផលិតផលក្នុងស្រុកសរុប (ផ.ស.ស.)។ ទន្ទឹមគ្នានោះ ចំនួនមូលប្បទានបត្របង្វិលវិញជាប្រាក់រៀល ក៏មានការថយចុះ ២៥,៤២% ពី ៥៩ សន្លឹក មកត្រឹម ៤៤ សន្លឹក និងទំហំប្រាក់របស់មូលប្បទានបត្របង្វិលវិញក៏មានការថយចុះ ៩១% ពី ៤.៥៥៣,២៩ ប៊ីលានរៀល មក ៤១៦,៨៣ ប៊ីលានរៀល ស្មើនឹង ០,៤% នៃផ.ស.ស.។

ស្របគ្នានេះដែរ ចំនួនមូលប្បទានបត្រជាប្រាក់ដុល្លារអាមេរិកក៏មានការថយចុះ ១៤,២៥% ពី ៦០៧.៥១០ សន្លឹក មកត្រឹម ៥២០.៩២៦ សន្លឹក ដែលទំហំប្រាក់ក៏មានការថយចុះប្រមាណ ២៥,១៩% ពី ២៩.១៩១,៤៥ លានដុល្លារអាមេរិក មកត្រឹម ២១.៨០១,០២ លានដុល្លារអាមេរិក ស្មើនឹង ៨៥,៩% នៃផ.ស.ស.។ ទន្ទឹមនោះ ចំនួនមូលប្បទានបត្របង្វិលវិញជាប្រាក់ដុល្លារអាមេរិកបានថយចុះ ១៣,៦% ពី ៤.៥៧៤ សន្លឹក មកត្រឹម ៣.៩៥៤ សន្លឹក និងទំហំប្រាក់ថយចុះ ៩៧% ពី ៨.៣៤០,៤២ លានដុល្លារអាមេរិក មកត្រឹម ២២៣,២៦ លានដុល្លារអាមេរិក ស្មើនឹង ០,៩% នៃផ.ស.ស.។

តារាង ១ - ការផាត់ទាត់ និងទូទាត់មូលប្បទានបត្រ ជាប្រាក់រៀល

| ឆ្នាំ | មូលប្បទានបត្រ ជាប្រាក់រៀល | | មូលប្បទានបត្របង្វិលវិញ ជាប្រាក់រៀល | |
|---|---|---|---|---|
| | ចំនួន | ទំហំប្រាក់ (គិតជាប៊ីលានរៀល) | ចំនួន | ទំហំប្រាក់ (គិតជាប៊ីលានរៀល) |
| ឆ២ - ២០១៩ | ២១.៨៧០ | ៧.០៨៧,០២ | ១១៣ | ១២៤,៦៧ |
| ឆ១ - ២០២០ | ១៧.៩៦៦ | ១៤.០២៧,៧៥ | ៥៩ | ៤.៥៥៣,២៩ |
| ឆ២ - ២០២០ | ១៧.៦០៤ | ៨.៩២៧,៥៧ | ៤២ | ៥២១,៦៣ |
| ឆ១ - ២០២១ | ១៥.៦៧៣ | ៩.៦២១,៩០ | ៤៤ | ៤១៦,៨៣ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

តារាង ២ - ការផាត់ទាត់ និងទូទាត់មូលប្បទានបត្រ ជាប្រាក់ដុល្លារអាមេរិក

| ឆ្នាំ | មូលប្បទានបត្រ ជាប្រាក់ដុល្លារអាមេរិក | | មូលប្បទានបត្របង្វិលវិញ ជាប្រាក់ដុល្លារអាមេរិក | |
|---|---|---|---|---|
| | ចំនួន | ទំហំប្រាក់ (គិតជាលានដុល្លារអាមេរិក) | ចំនួន | ទំហំប្រាក់ (គិតជាលានដុល្លារអាមេរិក) |
| ឆ២ - ២០១៩ | ៦៩២.៧៨៥ | ២៦.៧៦៧,៩៥ | ៥.៩៩៤ | ៣.៤០៩,៨៥ |
| ឆ១ - ២០២០ | ៦០៧.៥១០ | ២៩.១៩១,៤៥ | ៤.៥៧៤ | ៨.៣៤០,៤២ |
| ឆ២ - ២០២០ | ៥៩២.៦០០ | ២១.០៧៨,៥៩ | ៤.០៤៦ | ៣៩៧,៣៧ |
| ឆ១ - ២០២១ | ៥២០.៩២៦ | ២១.៨០១,០២ | ៣.៩៥៤ | ២២៣,២៦ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ក្រាហ្វ ៦ - ការផាត់ទាត់ និងទូទាត់មូលប្បទានបត្រ




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

យោងតាមក្រាហ្វខាងលើ យើងសង្កេតឃើញថា ចំពោះឧបករណ៍មូលប្បទានបត្រដែលធ្វើប្រតិបត្តិការផាត់ទាត់ និងទូទាត់នៅក្នុងប្រព័ន្ធផាត់ទាត់ជាតិទាំងជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិកមានការថយចុះ ដែលឆ្លុះបញ្ចាំងអំពីនិន្នាការកើនឡើងនៃការប្រើប្រាស់ឧបករណ៍ទូទាត់ជាអេឡិចត្រូនិក។ ឧបករណ៍ទូទាត់សងប្រាក់ដែលបានប្រើប្រាស់នៅក្នុងប្រព័ន្ធផាត់ទាត់ជាតិ រួមមានមូលប្បទានបត្រ (Checks) និងបញ្ជាទូទាត់សងប្រាក់អេឡិចត្រូនិក (Electronic Payment Orders)។

បើទោះបីជាការប្រើប្រាស់មូលប្បទានបត្រមានការថយចុះ ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ក៏នៅតែបន្តអនុវត្តវិធានការមួយចំនួន ដើម្បីបន្តកាត់បន្ថយការប្រើប្រាស់មូលប្បទានបត្រ និងមូលប្បទានបត្របង្វិលវិញ ដូចជា៖

- លើកទឹកចិត្តឱ្យគ្រឹះស្ថានជាសមាជិកប្រើប្រាស់បញ្ជាទូទាត់សងប្រាក់ជាអេឡិចត្រូនិក ដោយបន្តអភិវឌ្ឍប្រព័ន្ធទូទាត់ឱ្យកាន់តែមានភាពងាយស្រួល តម្លៃទាប និងសុវត្ថិភាព
- បន្តជំរុញឱ្យគ្រឹះស្ថានជាសមាជិកពង្រឹងការអនុវត្តលក្ខខណ្ឌទាក់ទងនឹងការប្រើប្រាស់មូល-ប្បទានបត្រ ដើម្បីទប់ស្កាត់និងកាត់បន្ថយឱ្យបានជាអតិបរមានូវចំនួនមូលប្បទានបត្របង្វិលវិញ។

## ខ)- បញ្ជាទូទាត់សងប្រាក់ជាអេឡិចត្រូនិក

ក្នុងរយៈពេលដូចគ្នានេះ ចំនួនប្រតិបត្តិការបញ្ជាផ្ទេរឥណទានជាប្រាក់រៀលបានកើនឡើង ៥៨% ពី ៤.៣៤២ បញ្ជាផ្ទេរ ទៅ ៦.៨៥៥ បញ្ជាផ្ទេរ ដែលមានទំហំប្រាក់កើនឡើងប្រមាណ ៨% ពី

២.៣៩០,៨៥ ប៊ីលានរៀល ទៅ ២.៥២១,៨០ ប៊ីលានរៀល ស្មើនឹង ២,៥% នៃផ.ស.ស.។ ដោយឡែក ចំនួនបញ្ជាផ្ទេរឥណទានជាប្រាក់ដុល្លារអាមេរិក មានការកើនឡើងប្រមាណ ៨៦% ពី ១៤០.១២២ បញ្ជាផ្ទេរ ទៅ ២៦០.៤២៣ បញ្ជាផ្ទេរ ស្របគ្នានឹងការកើនឡើងនូវទំហំប្រាក់ ២១% ពី ៤.០៤៩,៥៨ លានដុល្លារអាមេរិក ទៅ ៤.៨៩២,២៥ លានដុល្លារអាមេរិក ដែលមានទំហំប្រាក់ ១៩,៣% នៃផ.ស.ស.។

**តារាង ៣ - បញ្ជាផ្ទេរឥណទានតាមប្រព័ន្ធផាត់ទាត់ជាតិ**

| ឆ្នាំ | បញ្ជាផ្ទេរប្រាក់អេឡិចត្រូនិក ជាប្រាក់រៀល | | បញ្ជាផ្ទេរប្រាក់អេឡិចត្រូនិក ជាប្រាក់ដុល្លារអាមេរិក | |
|---|---|---|---|---|
| | ចំនួន | ទំហំប្រាក់ (គិតជាប៊ីលានរៀល) | ចំនួន | ទំហំប្រាក់ (គិតជាលានដុល្លារអាមេរិក) |
| ឆ២ - ២០១៩ | ៣.៧២៩ | ២.៣៣២,៣២ | ១២៣.០៤៥ | ៤.០៣០,០៩ |
| ឆ១ - ២០២០ | ៤.៣៩២ | ២.៣៩០,៨៥ | ១៤០.១២២ | ៤.០៤៩,៥៨ |
| ឆ២ - ២០២០ | ៥.៧៥៩ | ២.៣២២,៩០ | ១៩៨.៣១២ | ៨.៦៥៧,០១ |
| ឆ១ - ២០២១ | ៦.៨៥៥ | ២.៥២១,៨០ | ២៦០.៤២៣ | ៤.៨៩២,២៥ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៧ - បញ្ជាផ្ទេរប្រាក់អេឡិចត្រូនិក ជាប្រាក់រៀល និងជាប្រាក់ដុល្លារអាមេរិក**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ការប្រើប្រាស់បញ្ជាទូទាត់ជាអេឡិចត្រូនិកនៅក្នុងឆមាសទី១ ឆ្នាំ២០២១ នេះ មានការកើនឡើង ទាំងបរិមាណ និងចំនួនប្រាក់ បើធៀបជាមួយឆមាសទី១ ឆ្នាំ២០២០។ ដើម្បីបន្តជំរុញការប្រើប្រាស់ បញ្ជាទូទាត់ជាអេឡិចត្រូនិក ធនាគារជាតិនៃកម្ពុជាបាននិងកំពុងដាក់ចេញគោលការណ៍មួយចំនួន ដូចខាងក្រោម៖

- ពង្រីកបណ្តាញផ្តល់សេវាបញ្ជាផ្ទេរប្រាក់តាមរយៈសេវាធនាគារអ៊ីនធឺណិត ឬសេវាធនាគារចល័ត ដើម្បីបង្កើនភាពងាយស្រួលសម្រាប់អតិថិជនប្រើប្រាស់
- លើកទឹកចិត្តក្នុងការប្រើប្រាស់បញ្ជាទូទាត់ជាអេឡិចត្រូនិក តាមរយៈការយកកម្រៃប្រតិបត្តិការតិចជាងប្រតិបត្តិការមូលប្បទានបត្រ
- បន្តធ្វើទំនើបកម្ម និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធទូទាត់រាយថ្មីៗដែលងាយស្រួល និងមានសុវត្ថិភាពក្នុងការផ្ទេរប្រាក់ជាអេឡិចត្រូនិក។

### ៣.១.២. ប្រព័ន្ធសេវាទូទាត់រហ័ស - FAST

គិតពីឆ្នាំ២០១៦ រហូតដល់បច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការប្រព័ន្ធសេវាទូទាត់រហ័សអស់រយៈពេល ៥ ឆ្នាំមកហើយ ដើម្បីសម្រួលដល់ការធ្វើប្រតិបត្តិការផ្ទេរមូលនិធិអន្តរធនាគារជាប្រាក់រៀល ដោយអនុញ្ញាតឱ្យអតិថិជនជាអ្នកទទួលផលអាចទទួលបានមូលនិធិភ្លាមៗ។ ប្រព័ន្ធសេវាទូទាត់រហ័សមានគ្រឹះស្ថានជាសមាជិកចំនួន ៥៥ ដែលក្នុងនោះមានធនាគារពាណិជ្ជ ៤៩ ធនាគារឯកទេស ១ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ៥។ បច្ចុប្បន្នមានគ្រឹះស្ថានជាសមាជិកចំនួន ៤៦ បានដាក់ឱ្យដំណើរការប្រព័ន្ធសេវាទូទាត់រហ័សជាផ្លូវការដែលអនុញ្ញាតឱ្យអតិថិជនអាចធ្វើប្រតិបត្តិការផ្ទេរមូលនិធិភ្លាមៗឆ្លងគ្រឹះស្ថានបានប្រកបដោយភាពងាយស្រួល ប្រសិទ្ធភាព រហ័ស និងសុវត្ថិភាព តាមរយៈបញ្ជរបស់គ្រឹះស្ថានសមាជិកទាំងអស់ និងបណ្តាញសេវាធនាគារអ៊ីនធឺណិត និងសេវាធនាគារចល័តរបស់គ្រឹះស្ថានជាសមាជិកមួយចំនួនផងដែរ។ គិតត្រឹមដំណាច់ឆមាសទី១ ឆ្នាំ២០២១ មានគ្រឹះស្ថានសមាជិកចំនួន ៩ បានដាក់ឱ្យដំណើរការប្រព័ន្ធសេវាទូទាត់រហ័សតាមរយៈសេវាធនាគារចល័ត និងគ្រឹះស្ថានចំនួន ៨ ផ្សេងទៀតបានដាក់ឱ្យដំណើរការប្រព័ន្ធសេវាទូទាត់រហ័សតាមរយៈសេវាធនាគារអ៊ីនធឺណិត។ ដើម្បីបង្កើនប្រសិទ្ធភាព និងភាពងាយស្រួលក្នុងការប្រើប្រាស់សេវាទូទាត់រហ័ស ថ្មីៗនេះ ធនាគារជាតិនៃកម្ពុជាបានផ្តួចផ្តើមធ្វើបច្ចុប្បន្នកម្មប្រព័ន្ធសេវាទូទាត់រហ័សឱ្យក្លាយជាប្រព័ន្ធសេវាទូទាត់រហ័សជំនាន់ថ្មី ដោយមានបន្ថែមមុខងារ និងលក្ខណៈពិសេសមួយចំនួនដែលសម្រួលដល់ការធ្វើប្រតិបត្តិការប្រព័ន្ធសេវាទូទាត់រហ័សកាន់តែប្រសើរជាងមុន។

ក្នុងឆមាសទី១ ឆ្នាំ២០២១ នេះ បញ្ជាផ្ទេរឥណទានតាមប្រព័ន្ធទូទាត់រហ័សកើនឡើងប្រមាណ ៨៧% ពី ២១.៣៦៣ បញ្ជាផ្ទេរ ទៅ ៣៩.៩២៥ បញ្ជាផ្ទេរ និងទំហំប្រាក់កើនឡើងប្រមាណ ២% ពី ៩៥,២៥ ប៊ីលានរៀល ទៅ ៩៧,០១ ប៊ីលានរៀល ដែលមានទំហំប្រាក់ប្រមាណ ០,១% នៃផ.ស.ស.។

តារាង ៤ - បញ្ជាផ្ទេរឥណទាន តាមប្រព័ន្ធ FAST

| ឆ្នាំ | បញ្ជាផ្ទេរឥណទាន ជាប្រាក់រៀល តាមប្រព័ន្ធ FAST | |
|---|---|---|
| | ចំនួន | ទំហំប្រាក់ (គិតជាប៊ីលានរៀល) |
| ឆ២ - ២០១៩ | ១១.៥៤៨ | ១០០,២ |
| ឆ១ - ២០២០ | ២១.៣៦៣ | ៩៥,២៥ |
| ឆ២ - ២០២០ | ២៥.៥៧១ | ៨៩,៧៤ |
| ឆ១ - ២០២១ | ៣៩.៩២៥ | ៩៧,០១ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ក្រាហ្វ ៨ - បញ្ជាផ្ទេរឥណទាន តាមប្រព័ន្ធ FAST




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ផ្អែកតាមទិន្នន័យខាងលើបង្ហាញថា ចំនួនប្រតិបត្តិការ និងទំហំប្រាក់ដែលធ្វើឡើងតាមរយៈប្រព័ន្ធសេវាទូទាត់រហ័សមានការកើនឡើងជាងមុន។ ការណ៍នេះបង្ហាញថា អតិថិជនរបស់គ្រឹះស្ថានធនាគារកាន់តែមានការយល់ដឹង និងបានប្រើប្រាស់បញ្ជាផ្ទេរឥណទានកាន់តែច្រើនឡើង។

ដើម្បីលើកកម្ពស់ការប្រើប្រាស់ប្រព័ន្ធនេះឱ្យបានកាន់តែមានប្រសិទ្ធភាព ធនាគារជាតិនៃកម្ពុជាបាននិងកំពុងជំរុញគ្រឹះស្ថានជាសមាជិកឱ្យពង្រីកបណ្តាញផ្តល់ "សេវាទូទាត់រហ័ស" របស់ខ្លួនតាមរយៈសេវាធនាគារអ៊ីនធឺណិត និងសេវាធនាគារចល័ត និងតាមរយៈបណ្តាញផ្សេងៗ។ បច្ចុប្បន្នធនាគារជាតិនៃកម្ពុជាក៏បាននិងកំពុងអភិវឌ្ឍប្រព័ន្ធទូទាត់រហ័សទម្រង់ថ្មី ដើម្បីភ្ជាប់ជាមួយប្រព័ន្ធដទៃទៀត ក្នុងគោលបំណងឱ្យមុខងាររបស់ប្រព័ន្ធទូទាត់រហ័សកាន់តែទូលំទូលាយ។

### ៣.១.៣. ប្រព័ន្ធខេមបូឌានស៊ែស្វីច - CSS

ប្រព័ន្ធខេមបូឌានស៊ែស្វីចមានសមាជិកចំនួន ៥២ គ្រឹះស្ថាន ដែលក្នុងនោះមានគ្រឹះស្ថានសមាជិកចំនួន ២ ជាសមាជិកមិនផ្ទាល់ ក្នុងនោះមានធនាគារពាណិជ្ជចំនួន ៤៥ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន ៦ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ចំនួន ១។ ក្នុងចំណោមគ្រឹះស្ថានសមាជិកទាំង ៥២ មានគ្រឹះស្ថានសមាជិកចំនួន ៣៤ បានដាក់ឱ្យប្រព័ន្ធដំណើរការបឋម ខណៈគ្រឹះស្ថានសមាជិកដទៃទៀតកំពុងស្ថិតក្នុងដំណាក់កាលអភិវឌ្ឍផ្សេងៗគ្នា។

ការដាក់ឱ្យដំណើរការប្រព័ន្ធខេមបូឌានស៊ែស្វីចអនុញ្ញាតឱ្យអ្នកប្រើប្រាស់ធ្វើប្រតិបត្តិការប័ណ្ណឥណពន្ធរបស់ខ្លួនលើគ្រប់ម៉ាស៊ីន ATM និងម៉ាស៊ីន POS របស់គ្រឹះស្ថានសមាជិកដែលមានស្លាកសញ្ញាប្រព័ន្ធខេមបូឌានស៊ែស្វីច និងផ្តល់លទ្ធភាពឱ្យអ្នកប្រើប្រាស់ទាំងនោះធ្វើប្រតិបត្តិការទូទាត់យ៉ាងសម្បូរបែបតាមប្រព័ន្ធនេះគ្រប់ពេលវេលា (២៤/៧) ដែលនឹងជួយលើកកម្ពស់ប្រសិទ្ធភាពនៃការប្រើប្រាស់ប័ណ្ណឥណពន្ធ និងអន្តរប្រតិបត្តិការម៉ាស៊ីន ATM និងម៉ាស៊ីន POS ដែលសម្រួលដល់អតិថិជនក្នុងការធ្វើប្រតិបត្តិការអន្តរធនាគារ និងកាត់បន្ថយការចំណាយវិនិយោគលើម៉ាស៊ីន ATM និងម៉ាស៊ីន POS របស់គ្រឹះស្ថានសមាជិក។

ក្នុងឆមាសទី១ ឆ្នាំ២០២១ នេះ ប្រតិបត្តិការប័ណ្ណឥណពន្ធជាប្រាក់រៀលដែលបានចូលទូទាត់តាមប្រព័ន្ធខេមបូឌានស៊ែស្វីចបានកើនឡើង ១៥៣,៣% ពី ៦៣.៥៦៦ ប្រតិបត្តិការ ទៅ ១៦១.០២៨

ប្រតិបត្តិការ រីឯទំហំប្រាក់ក៏មានការកើនឡើង ១៧៧,៣% ពី ១២.៨៦៨,៤៩ លានរៀល ទៅ ៣៥.៦៨៣,៤៧ លានរៀល ស្មើនឹង ០,០១% នៃផ.ស.ស.។ ជាមួយគ្នានេះ ចំនួនប្រតិបត្តិការប័ណ្ណឥណពន្ធជាប្រាក់ដុល្លារអាមេរិកមានការកើនឡើង ១៤៦,៧% ពី ១៧.៤៧៣ ប្រតិបត្តិការ ទៅ ៤៣.១០២ ប្រតិបត្តិការ និងទំហំប្រាក់កើនឡើង ២០៧% ពី ១.៦៣៦.៨១០,៥៣ ដុល្លារអាមេរិក ទៅ ៥.០២៤.៧១៦,៦៩ ដុល្លារអាមេរិក ដែលមានទំហំប្រាក់ប្រមាណ ០,០២% នៃផ.ស.ស.។

**តារាង ៥ - ការទូទាត់លើប្រតិបត្តិការប័ណ្ណឥណពន្ធតាមប្រព័ន្ធ CSS**

| ឆ្នាំ | ប្រតិបត្តិការប័ណ្ណឥណពន្ធ ជាប្រាក់រៀល | | ប្រតិបត្តិការប័ណ្ណឥណពន្ធ ជាប្រាក់ដុល្លារអាមេរិក | |
|---|---|---|---|---|
| | ចំនួនប្រតិបត្តិការ | ទំហំប្រាក់ (គិតជាលានរៀល) | ចំនួនប្រតិបត្តិការ | ទំហំប្រាក់ (គិតជាលានដុល្លារអាមេរិក) |
| ឆ២ - ២០១៩ | ២៨.៣៥៩ | ៤.៩០២,០៦ | ១៩.៦៤៦ | ១,៥៨ |
| ឆ១ - ២០២០ | ៦៣.៥៦៦ | ១២.៨៦៨,៤៩ | ១៧.៤៧៣ | ១,៦៤ |
| ឆ២ - ២០២០ | ១៥១.២៨៣ | ២៩.៨៦១,៦៣ | ៣០.៣២៧ | ៣,២៥ |
| ឆ១ - ២០២១ | ១៦១.០២៨ | ៣៥.៦៨៣,៤៧ | ៤៣.១០២ | ៥,០២ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៩ - ការទូទាត់លើប្រតិបត្តិការប័ណ្ណឥណពន្ធតាមប្រព័ន្ធ CSS**




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### ៣.១.៤. ប្រព័ន្ធធនាគារអនឡាញ - OBS

គិតមកដល់បច្ចុប្បន្ន ប្រព័ន្ធធនាគារអនឡាញត្រូវបានដាក់ឱ្យដំណើរការជាសាធារណៈអស់រយៈពេលប្រមាណ ៥ ឆ្នាំមកហើយ ក្នុងគោលដៅរួមចំណែកសម្រួលដល់ការអនុវត្តនីតិវិធីរដ្ឋបាលក្នុងការពិនិត្យព័ត៌មានគណនីរបស់គ្រឹះស្ថានសមាជិកដែលមាននៅធនាគារជាតិនៃកម្ពុជា កាត់បន្ថយ

ពេលវេលា និងការប្រើឯកសារលោយលក្ខណ៍អក្សរក្នុងការធ្វើប្រតិបត្តិការផ្ទេរមូលនិធិ ព្រមទាំងបង្កើនប្រសិទ្ធភាព និងភាពងាយស្រួលក្នុងការគ្រប់គ្រងសន្ទនីយភាពក្នុងប្រតិបត្តិការទូទាត់អន្តរធនាគារឱ្យបានកាន់តែប្រសើរជាងមុន។ នាពេលបច្ចុប្បន្ន ប្រព័ន្ធនេះមានសមាជិកសរុបចំនួន ៦៨ គ្រឹះស្ថាន ដែលក្នុងនោះធនាគារពាណិជ្ជចំនួន ៤៦ ធនាគារឯកទេសចំនួន ៣ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ៦ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ចំនួន ១២ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

បើធៀបនឹងឆមាសទី១ ឆ្នាំ២០២០ ប្រតិបត្តិការផ្ទេរប្រាក់តាមរយៈប្រព័ន្ធ OBS ជាប្រាក់រៀលរវាងគណនីនៅស្នាក់ការកណ្តាលធនាគារជាតិនៃកម្ពុជា ក្នុងឆមាសទី១ ឆ្នាំ២០២១ នេះ មានចំនួន ១១.៨៣២ ប្រតិបត្តិការ (កើនឡើង ៣,៩%) ស្មើនឹងទំហំប្រាក់ ៤២,៦៤ ទ្រីលានរៀល (ថយចុះ ០,៨ %) ដោយមានទំហំប្រាក់ប្រមាណ ៤១,២% នៃ ផ.ស.ស.។ ដោយឡែក ប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកមានចំនួន ៦.២៩៨ ប្រតិបត្តិការ (កើនឡើងប្រមាណ ១៨%) ដែលមានទំហំប្រាក់ ១៨.៨៦៤,៨៧ លានដុល្លារអាមេរិក (កើនឡើង ១៨%) ស្មើនឹង ៧៩% នៃផ.ស.ស.។ ក្នុងរយៈពេលដូចគ្នានេះ ប្រតិបត្តិការផ្ទេរប្រាក់តាមរយៈប្រព័ន្ធ OBS ជាប្រាក់រៀល ពីគណនីនៅស្នាក់ការកណ្តាលទៅសាខារាជធានី-ខេត្តមានចំនួន ៦៥៣ ប្រតិបត្តិការ (កើនឡើង ៧៨ %) ដែលមានទំហំប្រាក់ ២,៦ ទ្រីលានរៀល (កើនឡើង ១៦០%) ស្មើនឹង ២,៥% នៃផ.ស.ស. និងប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកមានចំនួន ៥៦៩ ប្រតិបត្តិការ (កើនឡើងប្រមាណ ៥០%) ស្មើនឹងទំហំប្រាក់ ៧០៧,៧២ លានដុល្លារអាមេរិក (កើនឡើង ១១៦%) ដែលមានទំហំប្រាក់ប្រមាណ ២,៨% នៃផ.ស.ស។

**តារាង ៦ - ការផ្ទេរប្រាក់រវាងគណនីនៅស្នាក់ការកណ្តាល តាមប្រព័ន្ធ OBS**

| ឆ្នាំ | ការផ្ទេរប្រាក់រវាងគណនីនៅស្នាក់ការកណ្តាល | | | |
|---|---|---|---|---|
| | ចំនួនប្រតិបត្តិការ ប្រាក់រៀល | ទំហំប្រាក់ (គិតជាទ្រីលានរៀល) | ចំនួនប្រតិបត្តិការ ប្រាក់ដុល្លារអាមេរិក | ទំហំប្រាក់ (គិតជាលានដុល្លារអាមេរិក) |
| ឆ២ - ២០១៩ | ៧.៥៤៤ | ២៥,៧៩ | ៤.៥៤៣ | ១៤.៣៩៥,៥៥ |
| ឆ១ - ២០២០ | ១១.៤៣៨ | ៤៣ | ៥.៣៣៨ | ១៥.៩៦១,៩០ |
| ឆ២ - ២០២០ | ៩.៥២២ | ២៩ | ៥.៩៩២ | ១៥.៨៧៥,១៩ |
| ឆ១ - ២០២១ | ១១.៨៣២ | ៤២,៦៤ | ៦.២៩៨ | ១៨.៨៦៤,៨៧ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**តារាង ៧ - ការផ្ទេរប្រាក់ពីគណនីនៅស្នាក់ការកណ្តាលទៅសាខារាជធានី-ខេត្ត តាមប្រព័ន្ធ OBS**

| ឆ្នាំ | ការផ្ទេរប្រាក់ពីគណនីនៅស្នាក់ការកណ្តាលទៅសាខារាជធានី-ខេត្ត | | | |
|---|---|---|---|---|
| | ចំនួនប្រតិបត្តិការ ប្រាក់រៀល | ទំហំប្រាក់ (គិតជាទ្រីលានរៀល) | ចំនួនប្រតិបត្តិការ ប្រាក់ដុល្លារអាមេរិក | ទំហំប្រាក់ (គិតជាលានដុល្លារអាមេរិក) |
| ឆ២ - ២០១៩ | ៣៨០ | ១,៤ | ២១៦ | ២៩០,២១ |
| ឆ១ - ២០២០ | ៣៦៥ | ១ | ៣៨១ | ៣២៧,០២ |
| ឆ២ - ២០២០ | ៥៦៨ | ១,៥ | ៤៧២ | ៤២៩,៣៩ |
| ឆ១ - ២០២១ | ៦៥៣ | ២,៦ | ៥៦៩ | ៧០៧,៧២ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ក្រាហ្វ ១០ - ប្រតិបត្តិការផ្ទេរប្រាក់ តាមប្រព័ន្ធ OBS




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ក្នុងរយៈពេលដំណើរការប្រមាណ ៥ ឆ្នាំនេះ យើងសង្កេតឃើញថា ប្រព័ន្ធ OBS កាន់តែមានប្រជាប្រិយភាព និងត្រូវបានប្រើប្រាស់ទូលំទូលាយជាងមុន។ យ៉ាងណាមិញ ធនាគារជាតិនៃកម្ពុជានៅតែបន្តជំរុញឱ្យគ្រឹះស្ថានជាសមាជិកប្រើប្រាស់ប្រព័ន្ធនេះឱ្យបានកាន់តែទូលំទូលាយ និងមានប្រសិទ្ធភាព ដើម្បីជំរុញការទូទាត់ជាអេឡិចត្រូនិក និងសម្រួលដល់ប្រតិបត្តិការផ្ទេរប្រាក់ឱ្យកាន់តែងាយស្រួល។

### ៣.១.៥. ប្រព័ន្ធរីថែលផេ - RPS

ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការជាផ្លូវការប្រព័ន្ធរីថែលផេ កាលពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ ហើយគិតមកដល់បច្ចុប្បន្ន ប្រព័ន្ធរីថែលផេមានគ្រឹះស្ថានសមាជិកសរុបចំនួន ២៣ ដែលក្នុងនោះមានគ្រឹះស្ថានចំនួន ១៩ បានដាក់ឱ្យដំណើរការសេវារបស់ប្រព័ន្ធរីថែលផេជាសាធារណៈតាមគ្រប់បណ្ដាញប្រតិបត្តិការរបស់ខ្លួនដែលរួមមាន ការធ្វើប្រតិបត្តិការតាមបញ្ជររបស់គ្រឹះស្ថាន និងតាមបណ្ដាញសេវាធនាគារចល័តរបស់ខ្លួន ដោយអនុញ្ញាតឱ្យអតិថិជនអាចធ្វើប្រតិបត្តិការផ្ទេរមូលនិធិអន្តរធនាគាររវាងគ្រឹះស្ថានជាសមាជិកបានប្រកបដោយភាពងាយស្រួល រហ័ស សុវត្ថិភាព និងប្រសិទ្ធភាព។ ការដាក់ឱ្យដំណើរការផ្លូវការប្រព័ន្ធរីថែលផេនេះបានរួមចំណែកជំរុញការធ្វើប្រតិបត្តិការទូទាត់ជាអេឡិចត្រូនិក បង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងនិងប្រើប្រាស់ធនធានហិរញ្ញវត្ថុ លើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ព្រមទាំងគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថលរបស់រាជរដ្ឋាភិបាល។

បច្ចុប្បន្ន ក្នុងចំណោមប្រព័ន្ធទាំង ៤ (១/-ប្រព័ន្ធផ្ទេរមូលនិធិភ្លាមៗ-RFT ២/-ប្រព័ន្ធទូទាត់ចល័ត-MPS ៣/-ប្រព័ន្ធទូទាត់តាម QR-QPS និង ៤/-ប្រព័ន្ធផាត់ទាត់អេឡិចត្រូនិក-ECS) មានតែប្រព័ន្ធផ្ទេរមូលនិធិភ្លាមៗ (RFT) និងប្រព័ន្ធផាត់ទាត់អេឡិចត្រូនិក (ECS) ប៉ុណ្ណោះដែលដាក់ឱ្យប្រើប្រាស់ ចំណែកប្រព័ន្ធផ្សេងទៀតកំពុងធ្វើសន្ទានកម្មនៅឡើយ។

គិតត្រឹមឆមាសទី១ ឆ្នាំ២០២១ ប្រព័ន្ធ RFT បានដំណើរការទូទាត់លើប្រតិបត្តិការបញ្ជាផ្ទេរអេឡិចត្រូនិកចំនួន ១១៩ថ្ងៃ ដែលប្រតិបត្តិការជាប្រាក់រៀលមានសរុបចំនួន ១៥.៤៧៣ ប្រតិបត្តិការ និងទំហំប្រាក់ចំនួន ១២៣.០១៣,៤៧ លានរៀល (០,១២% នៃផ.ស.ស.) និងចំនួនប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិកមានចំនួន ៣០.១៧៤ ប្រតិបត្តិការ ស្មើនឹងទំហំប្រាក់ចំនួន ៨៧,៣៥ លានដុល្លារអាមេរិក (០,៣៩% នៃផ.ស.ស)។

តារាង ៨ - ប្រតិបត្តិការបញ្ជាផ្ទេរអេឡិចត្រូនិកតាមប្រព័ន្ធ RFT

| ឆ្នាំ | បញ្ជាផ្ទេរ ជាប្រាក់រៀល | | បញ្ជាផ្ទេរ ជាប្រាក់ដុល្លារអាមេរិក | |
|---|---|---|---|---|
| | ចំនួន | ទំហំប្រាក់ (គិតជាលានរៀល) | ចំនួន | ទំហំប្រាក់ (គិតជាលានដុល្លារអាមេរិក) |
| ឆ១ - ២០២០ | ១.៧២០ | ១០.៧០៣,២៣ | ២.៧៩៧ | ១៦,០៨ |
| ឆ២ - ២០២០ | ៧.៣០២ | ៣៣.៥៥៨,១៦ | ១២.៦០០ | ៤១,៤៩ |
| ឆ១ - ២០២១ | ១៥.៤៧៣ | ១២៣.០១៣,៤៧ | ៣០.១៧៤ | ៨៧,៣៥ |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ក្រាហ្វ ១១ - ប្រតិបត្តិការបញ្ជាផ្ទេរអេឡិចត្រូនិក តាមប្រព័ន្ធ RFT




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ប្រព័ន្ធទូទាត់សងប្រាក់ចម្បងៗដែលកំពុងធ្វើប្រតិបត្តិការក្រោមការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជានាពេលបច្ចុប្បន្ន រួមមាន ប្រព័ន្ធផាត់ទាត់ជាតិ ប្រព័ន្ធសេវាទូទាត់រហ័ស ប្រព័ន្ធធនាគារអនឡាញ ប្រព័ន្ធខេមបូឌានស៊ែស្វីច និងប្រព័ន្ធរីថៃលផេ។ ក្នុងចំណោមប្រព័ន្ធទូទាត់ចម្បងៗទាំងនេះ យើងសង្កេតឃើញថា ប្រព័ន្ធផាត់ទាត់ជាតិជាប្រព័ន្ធដែលពេញនិយមប្រើប្រាស់ច្រើនជាងប្រព័ន្ធផ្សេងៗទៀត បើផ្អែកលើចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការដូចមានបង្ហាញក្នុងក្រាហ្វខាងក្រោម។

ក្រាហ្វ ១២ - ចំនួន និងទំហំប្រាក់ប្រតិបត្តិការនៃប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជា




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ៣.២. ការពង្រឹងស្ថិរភាពប្រព័ន្ធទូទាត់សងប្រាក់

ការពង្រឹងស្ថិរភាពប្រព័ន្ធទូទាត់សងប្រាក់ត្រូវបានអនុវត្តឡើងក្នុងគោលបំណងកាត់បន្ថយហានិភ័យចម្បងៗដែលអាចកើតមានក្នុងប្រព័ន្ធទូទាត់ ដូចជា ហានិភ័យសន្ទនីយភាព ហានិភ័យទូទាត់ ហានិភ័យឥណទាន ហានិភ័យប្រតិបត្តិការ និងហានិភ័យដួលរលំជាប្រព័ន្ធ។

### ៣.២.១. ការគ្រប់គ្រងហានិភ័យសន្ទនីយភាព ហានិភ័យទូទាត់ និងហានិភ័យឥណទាន

ដើម្បីបង្ការនូវហានិភ័យក្នុងប្រព័ន្ធផាត់ទាត់ជាតិ ធនាគារជាតិនៃកម្ពុជាបានរៀបចំយន្តការដោះស្រាយ និងគ្រប់គ្រង ដូចខាងក្រោម៖

- រៀបចំប្រព័ន្ធតាមដានសន្ទនីយភាព ដើម្បីអនុញ្ញាតឱ្យសមាជិកនីមួយៗអាចពិនិត្យមើលសមតុល្យមូលនិធិដែលមានក្នុងគណនីទូទាត់ជាប្រចាំ
- ផ្តល់សន្ទនីយភាពក្នុងថ្ងៃដល់សមាជិកដែលជួបប្រទះកង្វះខាតសាច់ប្រាក់ ក្នុងការទូទាត់ (ឥណទានវិបារូបន៍ដោយមានវត្ថុធានា)
- សមាជិកអាចស្នើសុំឥណទានវិបារូបន៍ស្មើនឹង ១០០% នៃតម្លៃប្រាតិភោគ
- ប្រសិនបើសមាជិកពុំមានសន្ទនីយភាពគ្រប់គ្រាន់សម្រាប់បំពេញកាតព្វកិច្ចទូទាត់សុទ្ធពហុភាគីរបស់ខ្លួនតាមពេលកំណត់ក្នុងករណីចាំបាច់ ធនាគារជាតិនៃកម្ពុជាអាចពន្យារពេលបិទការទូទាត់ ដើម្បីឱ្យសមាជិកដែលខ្វះសន្ទនីយភាពមានពេលវេលាបន្ថែមក្នុងការសម្របសម្រួលរកសន្ទនីយភាពពីប្រភពផ្សេងៗសម្រាប់បំពេញកាតព្វកិច្ចទូទាត់សុទ្ធ។ ក្នុងករណីនេះ សមាជិកនោះនឹងត្រូវរងពិន័យក្នុងការបណ្តាលឱ្យមានការពន្យារការទូទាត់

– ការផាត់ទាត់ឡើងវិញ (Unwinding of Clearing) ជាមធ្យោបាយចុងក្រោយ ដែលអាចត្រូវបានអនុវត្តនៅពេលដែលសមាជិកផ្ទាល់ណាមួយគ្មានលទ្ធភាពរកសន្ទនីយភាពសម្រាប់បំពេញកាតព្វកិច្ចទូទាត់បានទាន់ពេលវេលា។ ប្រសិនបើមានករណីនេះកើតឡើង ការផាត់ទាត់ត្រូវធ្វើឡើងវិញ ហើយរាល់អ៊ីនភុតឧបករណ៍ដែលត្រូវទូទាត់របស់សមាជិកទាំងអស់ត្រូវបញ្ជូនជាថ្មីមកសភាផាត់ទាត់ជាតិ ដើម្បីដំណើរការផាត់ទាត់ និងទូទាត់ឡើងវិញ លើកលែងតែឧបករណ៍ទូទាត់របស់សមាជិកដែលគ្មានលទ្ធភាពទូទាត់សងត្រូវបានដកចេញទាំងអស់។

## ៣.២.២. ការគ្រប់គ្រងហានិភ័យប្រតិបត្តិការ និងហានិភ័យដួលរលំជាប្រព័ន្ធ

ដើម្បីគ្រប់គ្រងហានិភ័យប្រតិបត្តិការ និងហានិភ័យដួលរលំជាប្រព័ន្ធក្នុងប្រព័ន្ធផាត់ទាត់ជាតិឱ្យដំណើរការប្រតិបត្តិការដោយរលូន ធនាគារជាតិនៃកម្ពុជាបានរៀបចំយន្តការគ្រប់គ្រងដូចជា រៀបចំប្រព័ន្ធសម្រាប់សង្គ្រោះទិន្នន័យពេញលេញដែលបានបំពាក់នៅស្នាក់ការកណ្តាលនៃធនាគារជាតិនៃកម្ពុជា និងនៅមណ្ឌលសង្គ្រោះ។ ប្រព័ន្ធសង្គ្រោះទិន្នន័យនៅស្នាក់ការកណ្តាលមានសមត្ថភាពបច្ចេកទេសរឹងមាំធន់នឹងគ្រោះមហន្តរាយជាអតិបរមា ដែលអាចធានាការស្រោចស្រង់ទិន្នន័យបានភ្លាមៗដោយស្វ័យប្រវត្តិ និងអាចដំណើរការវិញក្នុងរយៈពេលមួយម៉ោង។ ទន្ទឹមនឹងនោះ ក្នុងករណីមានភាពរអាក់រអួលនៃប្រព័ន្ធប្រតិបត្តិការរបស់សមាជិកណាមួយ ធនាគារជាតិនៃកម្ពុជាផ្តល់យន្តការសម្រួលភ្លាមៗនៅនឹងកន្លែងជា Back-Up Bureau Services ចំពោះសមាជិកណាដែលមិនអាចបញ្ជូនទិន្នន័យជាអេឡិចត្រូនិកមកសភាផាត់ទាត់ជាតិបានដោយសារបញ្ហាផ្នែកបច្ចេកទេស។ ទន្ទឹងនេះដែរ ធនាគារជាតិនៃកម្ពុជាបានរៀបចំជា Secondary site ដោយបំពាក់ឧបករណ៍កុំព្យូទ័រ Software និង Hardware ក្នុងករណីមានករណីប្រធានសក្តិ ឬជំងឺឆ្លងដែលមិនអាចចូលមកកន្លែងធ្វើការបាន។

ក្នុងឆមាសទី១ ឆ្នាំ២០២១ ទោះបីជាបានជួបបញ្ហារអាក់រអួលផ្នែកបច្ចេកទេសខ្លះៗដែលបណ្តាលមកពីដាច់បណ្តាញប្រព័ន្ធមិនអាចទំនាក់ទំនងគ្នាទៅវិញទៅមកជាមួយប្រព័ន្ធធនាគារស្នូលបានក៏ដោយ ប៉ុន្តែបញ្ហានេះត្រូវបានដោះស្រាយភ្លាមៗទាន់ពេលវេលា។ ដោយឡែក ចំពោះការពន្យារពេលទូទាត់ដោយមូលហេតុកង្វះសន្ទនីយភាពពុំធ្លាប់ជួបប្រទះឡើយ ដោយសារសមាជិកនីមួយៗបានយកចិត្តទុកដាក់ក្នុងការពិនិត្យតាមដានសមតុល្យនៅក្នុងគណនីទូទាត់ ដើម្បីធានាថាមានមូលនិធិគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ចទូទាត់នៅក្នុងថ្ងៃ។ ជារួម ប្រព័ន្ធផាត់ទាត់ជាតិបានដំណើរការដោយរលូន ដែលបច្ចុប្បន្នប្រព័ន្ធនេះអាចរក្សាបាននូវការអនុវត្តសម្រេចបានកម្រិតស្តង់ដារបច្ចេកទេស ៩៥% (កៅសិបប្រាំភាគរយ) នៃរង្វាស់គោល ១០០%។ ការអនុវត្តប្រចាំថ្ងៃត្រូវបានគណនាដោយធៀបនឹងកម្រិតគោលសម្រាប់ដំណើរការប្រចាំថ្ងៃដូចជា ពេលវេលាផាត់ទាត់និងទូទាត់ជាក់ស្តែង (៨០%) ពេលវេលាចាប់ផ្តើមជាក់ស្តែងក្នុងថ្ងៃ (៥%) ម៉ោងឈប់ទទួល Input (៥%) ពេលវេលាទូទាត់ជាក់ស្តែង (៥%) ព្រមទាំងបញ្ហាផ្សេងៗនៃកិច្ចដំណើរការជាក់ស្តែងដែលកើតឡើងដោយសារការធ្វើបច្ចុប្បន្នកម្ម និងការផ្លាស់ប្តូរកម្មវិធី (៥%)។

# ៤. ការគ្រប់គ្រងសេវាទូទាត់សងប្រាក់

## ៤.១. ការវិវត្តន៍នៃសេវាទូទាត់សងប្រាក់

ថ្មីៗនេះ សេវាទូទាត់សងប្រាក់មានការរីកចម្រើនគួរឱ្យកត់សម្គាល់ និងបានវិវត្តទៅរកការទូទាត់បែបឌីជីថល ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អតិថិជនលើសេវាទូទាត់ថ្មីៗប្រកបដោយនវានុវត្តន៍ ងាយស្រួល សុវត្ថិភាព និងចំណាយទាប។ ទាំងនេះជាសមិទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរបស់ធនាគារជាតិនៃកម្ពុជាដែលជាអាជ្ញាធរត្រួតពិនិត្យលើគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្ដល់សេវាទូទាត់សងប្រាក់ដែលជាអ្នកផ្ដល់សេវាដល់អតិថិជន។ គិតត្រឹមឆមាសទី១ ឆ្នាំ២០២១ គ្រឹះស្ថានផ្ដល់សេវាទូទាត់សងប្រាក់ចំនួន ២៨ បានទទួលអាជ្ញាប័ណ្ណ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួន ២ ទទួលបានលិខិតអនុញ្ញាតធ្វើប្រតិបត្តិការទូទាត់សងប្រាក់ពីធនាគារជាតិនៃកម្ពុជា។ គំរូផលិតផល និងសេវាដែលផ្ដល់ដោយគ្រឹះស្ថានទាំងនេះ ជាទូទៅមានលក្ខណៈជាការទូទាត់បែបឌីជីថល ដែលអតិថិជនអាចធ្វើប្រតិបត្តិការដោយផ្ទាល់តាមរយៈកម្មវិធីទូទាត់ចល័ត ឬនៅតាមបញ្ជរភ្នាក់ងារ និងបណ្ដាញទូទាត់ជាច្រើនដែលគ្របដណ្ដប់ទូទាំងប្រទេស។ នេះឆ្លុះបញ្ចាំងឱ្យឃើញថាការប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងការផ្ដល់សេវាទូទាត់ ជាកត្តាមួយជួយលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ជំរុញការប្រកួតប្រជែង បង្កើនភាពច្នៃប្រឌិត និងផ្ដល់នូវជំនឿទុកចិត្តដល់សាធារណជនក្នុងការប្រើប្រាស់សេវាទូទាត់សងប្រាក់។

នៅក្នុងបរិបទនៃជំងឺកូវីដ-១៩ នេះ ការប្រើប្រាស់សេវាទូទាត់សងប្រាក់មានការកើនឡើងគួរឱ្យកត់សម្គាល់។ អតិថិជនបានធ្វើការផ្លាស់ប្ដូរឥរិយាបទពីការចាយវាយដោយពឹងផ្អែកលើសាច់ប្រាក់មកជាការទូទាត់បែបឌីជីថល ដើម្បីជួយកាត់បន្ថយការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩។ គិតត្រឹមឆមាសទី១ ឆ្នាំ២០២១ ទិន្នន័យអតិថិជនចុះឈ្មោះបង្កើតគណនីអ៊ីវ៉ាឡេតសរុបមានចំនួន ១១,៧ លាននាក់ កើនឡើង ៣៦,០៥% ធៀបនឹងឆមាសមុន រីឯភ្នាក់ងារមានចំនួនសរុប ៤២,៩ ពាន់ទីតាំង ដែលមានការថយចុះបន្តិចបន្តួចស្មើនឹង ៥,៩២% ដែលនេះអាចបណ្ដាលមកពីវិធានការបិទខ្ទប់របស់រាជរដ្ឋាភិបាល និងអតិថិជនងាកមកប្រើប្រាស់ការទូទាត់តាមរយៈទូរស័ព្ទដៃជាជាងការធ្វើប្រតិបត្តិការជាមួយភ្នាក់ងារដោយផ្ទាល់។ ចំណែកចំនួនប្រតិបត្តិការសរុបចំនួន ១៥០,៤ លានប្រតិបត្តិការ ដែលកើនឡើង ៤,២៣% និងមានទំហំប្រាក់សរុបចំនួន ២៤ ប៊ីលានដុល្លារអាមេរិក ប្រមាណ ៩៤,៥៥% នៃផលិតផលក្នុងស្រុកសរុប (ផ.ស.ស)។ ម៉្យាងវិញទៀត ការគ្រប់គ្រងមូលនិធិរបស់គ្រឹះស្ថានផ្ដល់សេវាទូទាត់សងប្រាក់ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្ដល់សេវាទូទាត់សងប្រាក់មានភាពល្អប្រសើរ ដោយគ្រឹះស្ថានរក្សាបាននូវសមតុល្យក្នុងគណនីអាណត្តិព្យាបាលបានខ្ពស់ជាងសមតុល្យរូបិយវត្ថុអេឡិចត្រូនិកសរុបដែលបានចេញផ្សាយ។ គិតត្រឹមឆមាសទី១ ឆ្នាំ២០២១ សមតុល្យប្រាក់សរុបដែលបានរក្សាទុកក្នុងគណនីអាណត្តិព្យាបាលមានចំនួន ០,៣២ ប៊ីលានដុល្លារអាមេរិក និងសមតុល្យរូបិយវត្ថុអេឡិចត្រូនិកសរុបដែលបានចេញផ្សាយមានចំនួន ០,៣១ ប៊ីលានដុល្លារអាមេរិក។

ក្រាហ្វ ១៣ - ចំនួនភ្នាក់ងារ អតិថិជនចុះឈ្មោះអ៊ីវ៉ាឡេត និងអតិថិជន Walk-in របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផ្តល់សេវាទូទាត់ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ក្រាហ្វ ១៤ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការនៃសេវាទូទាត់ចល័តតាមកាបូបអេឡិចត្រូនិក (Mobile E-wallet)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ក្រាហ្វ ១៥ - សមតុល្យប្រូបិយវត្ថុអេឡិចត្រូនិកសរុបដែលបានចេញផ្សាយ




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

បច្ចុប្បន្ន គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានបន្តដាក់ឱ្យដំណើរការសេវាធនាគារអ៊ីនធឺណិត និងសេវាធនាគារចល័តជូនអតិថិជនប្រើប្រាស់យ៉ាងទូលំទូលាយ (Internet and Mobile Banking) មានដូចជា ការទូទាត់ឥណទាន ការទូទាត់វិក្កយបត្រ (ថ្លៃទឹក/ភ្លើង អ៊ីនធឺណិត ទូរទស្សន៍ខ្សែកាប ធានារ៉ាប់រង) សេវាបញ្ចូលប្រាក់ទូរស័ព្ទ សេវាបើកប្រាក់បៀវត្សរ៍ និងសេវាទូទាត់ផ្សេងៗទៀត ដូចជា ការផ្ទេរមូលនិធិ និងការពិនិត្យមើលសមតុល្យនៅក្នុងគណនីជាដើម។

គិតត្រឹមឆមាសទី១ ឆ្នាំ២០២១ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួន ៣៥ គ្រឹះស្ថាន បានផ្តល់សេវាធនាគារអ៊ីនធឺណិត និងគ្រឹះស្ថានចំនួន ២៩ ផ្សេងទៀតបានផ្តល់សេវាធនាគារចល័ត។ ចំពោះចំនួនប្រតិបត្តិការតាមរយៈសេវាធនាគារអ៊ីនធឺណិតមានចំនួន ១,៥ លានប្រតិបត្តិការ ដែលមានទំហំប្រាក់ចំនួន ៦,៦ ប៊ីលានដុល្លារអាមេរិក ប្រមាណ ២៦% នៃផ.ស.ស។ ចំណែកឯ ចំនួនប្រតិបត្តិការរបស់សេវាធនាគារចល័តមានចំនួន ១០០,៥ លានប្រតិបត្តិការ និងទំហំប្រាក់ចំនួន ៤៧,១ ប៊ីលានដុល្លារអាមេរិក ប្រមាណ ១៨៥,៥៥% នៃផ.ស.ស។

ក្រាហ្វ ១៦ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការរបស់សេវាធនាគារអ៊ីនធឺណិត និងសេវាធនាគារចល័ត (Internet Banking and Mobile Banking)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ក្រៅពីការរីកចម្រើននៃសេវាទូទាត់សងប្រាក់ ឧបករណ៍ទូទាត់សងប្រាក់ក៏មានការប្រើប្រាស់កាន់តែច្រើនឡើងគួរឱ្យកត់សម្គាល់ផងដែរ ជាពិសេសប័ណ្ណទូទាត់ដែលមានដូចជា ប័ណ្ណឥណពន្ធ (Debit Card) ប័ណ្ណឥណទាន (Credit Card) ប័ណ្ណទូទាត់ក្នុងស្រុក (Proprietary Card) និងប័ណ្ណបង់ប្រាក់ជាមុន (Prepaid Card) ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយសម្រាប់ការទូទាត់តម្លៃរាយ និងតាមប្រព័ន្ធអនឡាញ[1]។

គិតត្រឹមឆមាសទី១ ឆ្នាំ២០២១ មានគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួន ៣៩ បានចេញផ្សាយប័ណ្ណទូទាត់សម្រាប់អតិថិជនរបស់ខ្លួន ក្នុងគោលបំណងផ្តល់ភាពងាយស្រួលដល់អតិថិជនក្នុងការ

---

[1] **ប័ណ្ណឥណពន្ធ (Debit Card)** - ជាប្រភេទប័ណ្ណចេញផ្សាយដោយគ្រឹះស្ថានធនាគារសហការជាមួយក្រុមហ៊ុនបណ្តាញប័ណ្ណទូទាត់អន្តរជាតិ សម្រាប់ទូទាត់ទំនិញ និងដក/ដាក់ប្រាក់តាមរយៈម៉ាស៊ីន ATM បានទាំងក្នុង/ក្រៅប្រទេស ដោយប្រាក់ត្រូវបានដកដោយផ្ទាល់ចេញពីគណនីរបស់អ្នកកាន់ប័ណ្ណតាមកម្រិតសមតុល្យដែលនៅសល់។
**ប័ណ្ណឥណទាន (Credit Card)** - ជាប្រភេទប័ណ្ណចេញផ្សាយដោយគ្រឹះស្ថានធនាគារសហការជាមួយក្រុមហ៊ុនបណ្តាញប័ណ្ណទូទាត់អន្តរជាតិ សម្រាប់ទូទាត់ទំនិញ និងដកប្រាក់បានទាំងក្នុង/ក្រៅប្រទេស តាមកម្រិតឥណទានដែលបានផ្តល់ឱ្យ ហើយត្រូវទូទាត់សងវិញតាមកាលកំណត់ជាក់លាក់របស់គ្រឹះស្ថានធនាគារ។
**ប័ណ្ណទូទាត់ក្នុងស្រុក (Proprietary Card)** - ជាប្រភេទប័ណ្ណចេញផ្សាយដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ សម្រាប់ទូទាត់ទំនិញ និងដក/ដាក់ប្រាក់ តាមរយៈម៉ាស៊ីន ATM នៅក្នុងប្រទេសតែប៉ុណ្ណោះ។
**ប័ណ្ណបង់ប្រាក់ជាមុន (Prepaid Card)** - ជាប្រភេទប័ណ្ណចេញផ្សាយដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ សម្រាប់ទូទាត់ទំនិញបានទាំងក្នុង/ក្រៅប្រទេស ដោយប្រាក់ត្រូវបានដកដោយផ្ទាល់ចេញពីគណនីភ្ជាប់ជាមួយ។

ធ្វើប្រតិបត្តិការទូទាត់សងប្រាក់។ ប័ណ្ណទូទាត់ដែលបានចេញផ្សាយមានចំនួនសរុប ៩,៥ លានប័ណ្ណ និងប្រតិបត្តិការទូទាត់តាមប័ណ្ណទូទាត់ក្នុងស្រុកសរុបចំនួន ៩១,៧ លានប្រតិបត្តិការ ស្មើនឹងទំហំប្រាក់ ១០,២ ប៊ីលានដុល្លារអាមេរិក ប្រមាណ ៤០,១៨% នៃផ.ស.ស។ ចំណែកឯចំនួនប្រតិបត្តិការប័ណ្ណទូទាត់នៅក្រៅប្រទេសមានចំនួនសរុប ២,២ លានប្រតិបត្តិការ ស្មើនឹងទំហំប្រាក់ ០,១៩ ប៊ីលានដុល្លារអាមេរិក ប្រមាណ ០,៧៤% នៃផ.ស.ស។ ទន្ទឹមគ្នានេះដែរ ប្រតិបត្តិការទូទាត់ទំនិញតាមប្រព័ន្ធអនឡាញមានចំនួនសរុប ៦,៣ លានប្រតិបត្តិការ ស្មើនឹងទំហំប្រាក់ចំនួន ០,២២ ប៊ីលានដុល្លារអាមេរិក ប្រមាណ ០,៨៦% នៃផ.ស.ស។ ស្របគ្នានេះដែរ មានគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួន ៣៩ គ្រឹះស្ថាន បានតម្លើងម៉ាស៊ីនដក/ដាក់ប្រាក់ (ATM) ចំនួន ៣,៣ ពាន់គ្រឿង និង ២៧ គ្រឹះស្ថានបានតម្លើងម៉ាស៊ីនឆូតកាត (POS) ចំនួន ៤៤,៥ ពាន់គ្រឿង នៅទូទាំងប្រទេសកម្ពុជា។

ក្រាហ្វ ១៧ - ចំនួនប័ណ្ណទូទាត់ដែលបានចេញផ្សាយ (រួមទាំងប័ណ្ណទូទាត់អន្តរជាតិ)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ក្រាហ្វ ១៨ - ចំនួនម៉ាស៊ីន ATM និង ម៉ាស៊ីនឆូតកាត POS




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ស្របពេលដែលប្រទេសកម្ពុជាកំពុងប្រឈមនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ ការទូទាត់សងប្រាក់តាមយូអរកូត (QR Code) កំពុងមានការពេញនិយមយកមកប្រើប្រាស់ក្នុងការទូទាត់បែបអេឡិចត្រូនិកជំនួសឱ្យការទូទាត់ជាប្រាក់សុទ្ធ។ សេវានេះផ្តល់អត្ថប្រយោជន៍ឱ្យអតិថិជនទូទាត់ទំនិញ

បានរហ័ស ចំណេញពេលវេលា កម្រៃសេវាសមរម្យ និងសុវត្ថិភាពដែលធ្វើឱ្យអតិថិជនកាន់តែមានទំនុកចិត្តក្នុងការប្រើប្រាស់ និងទទួលបានបទពិសោធន៍ថ្មីពីសេវាទូទាត់តាម QR Code នេះ។

គិតត្រឹមឆមាសទី១ ឆ្នាំ២០២១ យើងសង្កេតឃើញថា ចំនួនប្រតិបត្តិការទូទាត់តាម QR Code មានការកើនឡើងជាលំដាប់ ដោយប្រតិបត្តិការមានចំនួន ២,៦ លាន ស្មើនឹងទំហំប្រាក់ចំនួន ៧៧,៩ លានដុល្លារអាមេរិក ប្រមាណ ០,៣% នៃផ.ស.ស។ កំណើននៃការទូទាត់តាម QR Code បានបង្ហាញឱ្យឃើញពីវឌ្ឍនភាពថ្មីៗក្នុងវិស័យធនាគារដោយប្រើប្រាស់បច្ចេកវិទ្យាក្នុងការផ្ដល់សេវាហិរញ្ញវត្ថុទៅអតិថិជន។ ទោះជាយ៉ាងនេះក្ដី ការទូទាត់តាម QR Code ក៏នៅមានបញ្ហាប្រឈមខ្លះ ដោយសារគ្រឹះស្ថានផ្ដល់សេវានេះនីមួយៗប្រើប្រាស់ស្តង់ដារផ្សេងៗគ្នាដែលធ្វើឱ្យអតិថិជនមិនអាចធ្វើប្រតិបត្តិការឆ្លងគ្រឹះស្ថានបាន។ ថ្មីៗនេះ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យប្រើប្រាស់គំរូបរិច្ឆិនភាពបច្ចេកទេសខេអេចឃ្យូអរកូត (KHQR Code) ដើម្បីសម្រួលដល់ការទូទាត់ឆ្លងគ្រឹះស្ថានបានតាម QR Code ដែលប្រព្រឹត្តទៅដោយរលូន និងមានប្រសិទ្ធភាព។

ក្រាហ្វ ១៩ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការទូទាត់តាម QR Code




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ៤.២. ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិសេវាទូទាត់សងប្រាក់

ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យលើប្រព័ន្ធទូទាត់សងប្រាក់ ដូចមានចែងក្នុងច្បាប់ស្ដីពី "ការរៀបចំនិងការប្រព្រឹត្តនៃធនាគារជាតិនៃកម្ពុជា" ច្បាប់ស្ដីពី "គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ" និងច្បាប់ស្ដីពី "ឧបករណ៍អាចជួញដូរបាននិងប្រតិបត្តិការទូទាត់សងប្រាក់" មានតួនាទីសំខាន់ក្នុងការត្រួតពិនិត្យ អភិវឌ្ឍ និងរៀបចំបទប្បញ្ញត្តិគ្រប់គ្រងប្រព័ន្ធទូទាត់សងប្រាក់ដើម្បីធានាបាននូវស្ថិរភាព និងនិរន្តរភាពនៃដំណើរការប្រព័ន្ធ កាត់បន្ថយហានិភ័យជាប្រព័ន្ធការពារផលប្រយោជន៍អតិថិជន ជំរុញការប្រកួតប្រជែងនិងការប្រើប្រាស់ការទូទាត់ជាអេឡិចត្រូនិក ប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ។ ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិសំខាន់ៗពាក់ព័ន្ធនឹងប្រព័ន្ធទូទាត់សងប្រាក់ដែលធនាគារជាតិនៃកម្ពុជាបានអនុម័តកន្លងមកមានភ្ជាប់ក្នុងឧបសម្ព័ន្ធ១។

ការវិវត្តន៍យ៉ាងឆាប់រហ័សនៃវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ បានធ្វើឱ្យកំណើននៃការប្រើប្រាស់សេវាទូទាត់ និងឧបករណ៍ទូទាត់សងប្រាក់នៅក្នុងប្រទេសកម្ពុជាមានការកើនឡើងជាលំដាប់ ជាពិសេស

ការផ្លាស់ប្តូរបរិបទនៃការផ្តល់សេវាហិរញ្ញវត្ថុ និងការដាក់ឱ្យដំណើរការសេវាទូទាត់ និងឧបករណ៍ទូទាត់ដែលប្រកបដោយនវានុវត្តន៍។ ដើម្បីឆ្លើយតបទៅនឹងការរីកចម្រើននៃបច្ចេកវិទ្យាទាំងនោះ ធនាគារជាតិនៃកម្ពុជាបានយកចិត្តទុកដាក់ក្នុងការរៀបចំក្របខណ្ឌគតិយុត្តដែលគាំទ្រដល់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ជាពិសេសផ្តល់លទ្ធភាពឱ្យសហគ្រាសធុនតូចនិងមធ្យម ព្រមទាំងអ្នកប្រើប្រាស់អាចទទួលបានសេវាទូទាត់សងប្រាក់ដែលគាំទ្រដោយបច្ចេកវិទ្យាហិរញ្ញវត្ថុ។ ក្នុងនាមជានិយ័តករ ធនាគារជាតិនៃកម្ពុជាព្យាយាមរក្សាតុល្យភាពរវាងគុណសម្បត្តិនៃបច្ចេកវិទ្យាហិរញ្ញវត្ថុសម្រាប់បរិយាបន្នហិរញ្ញវត្ថុ និងផលប៉ះពាល់ដែលបច្ចេកវិទ្យាហិរញ្ញវត្ថុបង្កឡើង ដើម្បីសម្រេចបាននូវគោលនយោបាយរូបិយវត្ថុ ស្ថិរភាពថ្លៃ និងស្ថិរភាពហិរញ្ញវត្ថុ សំដៅជំរុញកំណើនសេដ្ឋកិច្ច។

ក្នុងគោលបំណងគ្រប់គ្រងប្រតិបត្តិការប្រព័ន្ធទូទាត់សងប្រាក់ និងការផ្តល់សេវាទូទាត់សងប្រាក់ ធនាគារជាតិនៃកម្ពុជាក៏កំពុងរៀបចំក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិថ្មីៗបន្ថែមទៀត ដូចជាការកំណត់អំពីនីតិវិធីក្នុងការគណនាមូលនិធិផ្ទាល់សុទ្ធរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ការកំណត់ពីលក្ខខណ្ឌ និងនីតិវិធីសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុស្នើសុំការអនុញ្ញាតក្នុងការជ្រើសរើសភ្នាក់ងារ ការគ្រប់គ្រងគណនីអាណត្តិព្យាបាល និងនីតិវិធីត្រួតពិនិត្យគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់។ បន្ថែមពីនេះ ដើម្បីពង្រឹងសុវត្ថិភាព និងប្រសិទ្ធភាពប្រតិបត្តិការទីផ្សារតណទានតាមប្រព័ន្ធអេឡិចត្រូនិក ធនាគារជាតិនៃកម្ពុជាក៏កំពុងរៀបចំប្រកាសដែលកំណត់អំពីនីតិវិធីគ្រប់គ្រងប្រតិបត្តិការ និងប្រតិបត្តិករទីផ្សារតណទានតាមប្រព័ន្ធអេឡិចត្រូនិកក្នុងព្រះរាជាណាចក្រកម្ពុជា។




## ៤.៣. ការពង្រឹងស្ថិរភាពសេវាទូទាត់សងប្រាក់

ការរៀបចំក្របខណ្ឌគ្រប់គ្រងសេវាទូទាត់សងប្រាក់ធ្វើឡើងក្នុងគោលដៅរក្សាសុវត្ថិភាព តម្លាភាព ជំរុញការប្រកួតប្រជែង លើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងផ្តល់ទំនុកចិត្តដល់សាធារណជនមកលើសេវាទូទាត់សងប្រាក់។ ធនាគារជាតិនៃកម្ពុជាមានតួនាទីក្នុងការផ្តល់អាជ្ញាប័ណ្ណ ធ្វើនិយ័តកម្ម និងត្រួតពិនិត្យលើគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ដែលប្រកបអាជីវកម្មក្នុងព្រះរាជាណាចក្រកម្ពុជា ដែលស្ថិតក្រោមប្រកាសស្តីពី "ការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់"។ ធនាគារជាតិនៃកម្ពុជាត្រួតពិនិត្យជាប្រចាំលើគ្រឹះស្ថានដែលបានទទួលអាជ្ញាប័ណ្ណ ដោយផ្តោតលើវិធីសាស្ត្រត្រួតពិនិត្យលើហានិភ័យ (Risk Based Approach) ក៏ដូចជាការត្រួតពិនិត្យលើការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ (Compliance Based Approach) សំដៅកាត់បន្ថយហានិភ័យ និងធានាបានសុវត្ថិភាព និងភាពរឹងមាំរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់។ ការត្រួតពិនិត្យត្រូវបានបែងចែកជាពីរប្រភេទ រួមមាន ការត្រួតពិនិត្យលើឯកសារ និងការត្រួតពិនិត្យដល់ទីកន្លែង។ ការត្រួតពិនិត្យលើឯកសារ ជា

ការពិនិត្យ សិក្សា និងវាយតម្លៃលើសំណុំឯកសារស្នើសុំរបស់គ្រឹះស្ថាន និងវិភាគលើរបាយការណ៍ប្រតិបត្តិការ និងព័ត៌មានហិរញ្ញវត្ថុដែលគ្រឹះស្ថានផ្ញើជាប្រចាំមកធនាគារជាតិនៃកម្ពុជា។ ចំណែកឯការត្រួតពិនិត្យដល់ទីកន្លែង ជាការចុះត្រួតពិនិត្យដល់ទីស្នាក់ការរបស់គ្រឹះស្ថាន ដែលធ្វើឡើងបន្ទាប់ពីការត្រួតពិនិត្យលើឯកសារ ហើយជាកាតព្វកិច្ចមួយដ៏សំខាន់ក្នុងការពិនិត្យរកឱ្យឃើញពីស្ថានភាពជាក់ស្តែងរបស់គ្រឹះស្ថាននីមួយៗ។

ការវាយតម្លៃហានិភ័យជាលក្ខណៈមីក្រូផ្តោតសំខាន់លើសូចនាករហានិភ័យសំខាន់ៗ និងការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ ដើម្បីធានាពីភាពរឹងមាំរបស់គ្រឹះស្ថាន ហើយសូចនាករដទៃផ្សេងទៀត ក៏ត្រូវបានប្រើប្រាស់ផងដែរទៅតាមភាពជាក់ស្តែងនៃស្ថានភាពរបស់គ្រឹះស្ថាន។ សូចនាករហានិភ័យនីមួយៗដែលត្រូវយកមកវាយតម្លៃជាលក្ខណៈមីក្រូរួមមានដូចខាងក្រោម៖

- អភិបាលកិច្ច
- ហានិភ័យឥណទាន
- ហានិភ័យសន្ទនីយភាព
- ហានិភ័យយុទ្ធសាស្ត្រ
- ហានិភ័យប្រតិបត្តិការ
- ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- ការការពារអតិថិជន
- លទ្ធភាពរកប្រាក់ចំណេញ និង
- ភាពគ្រប់គ្រាន់នៃដើមទុន។



## ប្រអប់ ២ - ទិដ្ឋភាពទូទៅនៃសេវាទូទាត់សងប្រាក់នៅកម្ពុជា

ការរីកចម្រើននៃវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech) និងតម្រូវការទីផ្សារលើសេវានិងឧបករណ៍ទូទាត់បានជំរុញឱ្យគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ពង្រីកវិសាលភាពសេវាទូទាត់សងប្រាក់របស់ខ្លួនឱ្យបានកាន់តែទូលំទូលាយ ប្រកបដោយភាពងាយស្រួល តម្លៃសមរម្យ និងមានសុវត្ថិភាព ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អតិថិជន និងចូលរួមចំណែកលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា។

ទន្ទឹមនោះ សេវាទូទាត់សងប្រាក់មានតួនាទីយ៉ាងសំខាន់ក្នុងជីវភាពប្រចាំថ្ងៃ និងការប្រកបអាជីវកម្មរបស់ប្រជាពលរដ្ឋទូទៅ តាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់បណ្តាគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ក្នុងការពង្រីកបណ្តាញសេវាទូទាត់ មានដូចជា ម៉ាស៊ីនដក/ដាក់ប្រាក់ (ATM) ម៉ាស៊ីន Kiosk ពាណិជ្ជករ ភ្នាក់ងារ កម្មវិធីទូទាត់ចល័ត និងការសហការជាមួយដៃគូមានលក្ខណៈល្អប្រសើរ តម្លៃសេវាសមរម្យ ព្រមទាំងកាត់បន្ថយការប្រើប្រាស់សាច់ប្រាក់ ក៏ដូចជាចូលរួមចំណែកក្នុងការទប់ស្កាត់ការចម្លងជំងឺកូវីដ-១៩ ពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត។ ដោយគិតត្រឹមត្រីមាសទី២ ឆ្នាំ២០២១ ទំហំប្រតិបត្តិការនៃសេវាទូទាត់របស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលផ្តល់សេវាទូទាត់សងប្រាក់សរុបមានចំនួន ១៥០,៤ លានប្រតិបត្តិការ និងមានទំហំប្រាក់សរុបចំនួន ២៤ ប៊ីលានដុល្លារអាមេរិក ប្រមាណ ៩៤,៥៥% នៃផ.ស.ស។

ក្នុងគោលបំណងគ្រប់គ្រង និងត្រួតពិនិត្យគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យប្រើប្រាស់ប្រកាសស្តីពី ការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ និងបទប្បញ្ញត្តិផ្សេងៗ ដើម្បីរក្សាបាននូវសុវត្ថិភាពសេវាទូទាត់សងប្រាក់ និងអាចចាត់វិធានការបានទាន់ពេលក្នុងករណីដែលគ្រឹះស្ថានណាមួយប្រកបអាជីវកម្មមិនត្រឹមត្រូវតាមច្បាប់បានកំណត់។ ទន្ទឹមនឹងនេះ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ក៏ត្រូវយកចិត្តទុកដាក់លើបញ្ហាប្រឈមមួយចំនួន ដែលតម្រូវឱ្យគ្រឹះស្ថាននីមួយៗចាំបាច់ត្រូវរៀបចំនូវបទប្បញ្ញត្តិផ្ទៃក្នុង និងដាក់គោលការណ៍អនុវត្តឱ្យបានពេញលេញ ព្រមទាំងត្រូវរាយការណ៍ជាប្រចាំអំពីសកម្មភាពអាជីវកម្មរបស់ខ្លួនមកធនាគារជាតិនៃកម្ពុជា។

គិតត្រឹមត្រីមាសទី២ ឆ្នាំ២០២១ គ្រឹះស្ថាននីមួយៗបានផ្តោតសំខាន់តែលើការវិនិយោគលើសេវាទូទាត់សងប្រាក់ប៉ុណ្ណោះ។ គ្រឹះស្ថាននីមួយៗបានដាក់ចេញនូវគំរូអាជីវកម្មច្បាស់លាស់ តម្លៃសេវាប្រកបដោយតម្លាភាព ដើម្បីប្រកួតប្រជែងក្នុងទីផ្សារសេរីភាវូបនីយកម្ម និងបានគោរពតាមបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការអនុវត្តទាក់ទងទៅនឹងការរៀបចំយន្តការអភិបាលកិច្ច ការគ្រប់គ្រងសាច់ប្រាក់ងាយស្រួល ការការពារអតិថិជន និងការគ្រប់គ្រងហានិភ័យការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។ ម្យ៉ាងវិញទៀត គ្រឹះស្ថានភាគច្រើនកំពុងពង្រីកសេវារបស់ខ្លួន ដើម្បីបង្កើនកម្រិតប្រាក់ចំណូលបន្ថែមទៀត ចំណែកគ្រឹះស្ថានខ្លះកំពុងស្តារមកវិញនូវមូលធនដែលបានចំណាយលើប្រតិបត្តិការអាជីវកម្ម ធនធានមនុស្ស ការផ្សាយពាណិជ្ជកម្ម និងចំណាយផ្សេងៗ តាមរយៈការពង្រីក និងធ្វើឱ្យសេវាទូទាត់កាន់តែប្រសើរឡើងផងដែរ។ ការចូលរួមយ៉ាងសកម្មក្នុងការបម្រើសេវាជូនអតិថិជនរបស់គ្រឹះស្ថានទាំងនេះ រួមទាំងការគ្រប់គ្រងយ៉ាងជិតដល់ និងការជួយសម្រួលផ្នែកយន្តការទូទាត់រវាងគ្រឹះស្ថាននិងគ្រឹះស្ថាន ពីធនាគារជាតិនៃកម្ពុជា បានធ្វើឱ្យប្រព័ន្ធទូទាត់នៅកម្ពុជាកាន់តែមានភាពរីកចម្រើនជឿនលឿនយ៉ាងឆាប់រហ័ស និងប្រកបដោយបរិយាបន្ន។



# ៥. ការផ្ទេរប្រាក់ឆ្លងដែននៅកម្ពុជា

## ៥.១. ទិដ្ឋភាពទូទៅ

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ភាគច្រើនកំពុងបំពេញតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់សេវាផ្ទេរប្រាក់ទូទាំងប្រទេស តាមរយៈការពង្រីកវិសាលភាពនៃសេវាផ្ទេរប្រាក់របស់ខ្លួនឱ្យកាន់តែប្រសើរឡើង ជាពិសេសការចូលជាសមាជិកប្រព័ន្ធទូទាត់របស់ធនាគារជាតិនៃកម្ពុជា និងការបង្កើនដៃគូសហការផ្ទេរប្រាក់ទាំងក្នុងនិងក្រៅប្រទេស។ នាពេលបច្ចុប្បន្ន យើងសង្កេតឃើញថាប្រជាជនកម្ពុជាភាគច្រើនអាចទទួលបានសេវាផ្ទេរប្រាក់ផ្លូវការ ដែលផ្តល់ដោយគ្រឹះស្ថានទាំងនេះប្រកបដោយទំនុកចិត្តខ្ពស់ រហ័ស និងចំណាយតិចក្នុងការផ្ទេរប្រាក់ដោយអ្នកទទួលផលទាំងក្នុងនិងក្រៅស្រុកមាន ឬមិនមានគណនីធនាគារឬអ៊ីវ៉ាឡេត ហើយថែមទាំងអាចធ្វើការផ្ទេរប្រាក់ឆ្លងគ្រឹះស្ថានបានផងដែរសម្រាប់ប្រតិបត្តិការក្នុងស្រុក។

ទន្ទឹមនឹងភាពរីកចម្រើនយ៉ាងឆាប់រហ័សនៃប្រព័ន្ធបច្ចេកវិទ្យាទំនើបនៅក្នុងវិស័យធនាគារនិងហិរញ្ញវត្ថុ គ្រឹះស្ថានភាគច្រើនបានដាក់ឱ្យដំណើរការសេវាផ្ទេរប្រាក់ទាំងក្នុង និងក្រៅស្រុកជូនអតិថិជនតាមប្រព័ន្ធអនឡាញបន្ថែមពីលើការផ្តល់សេវាផ្ទេរប្រាក់នៅតាមភ្នាក់ងារ និងបញ្ជរ។ សេវាតាមប្រព័ន្ធអនឡាញមានច្រើនប្រភេទដូចជា កម្មវិធីទូទាត់តាមទូរស័ព្ទ (Mobile Payment App) សេវាធនាគារអ៊ីនធឺណិត (Internet Banking) និងសេវាធនាគារចល័ត (Mobile Banking) ដែលកំពុងទទួលបានការពេញនិយមសម្រាប់ការប្រើប្រាស់ផ្ទេរប្រាក់ក្នុងនិងក្រៅប្រទេសបាននៅគ្រប់ទីកន្លែង គ្រប់ពេលវេលា និងមានសុវត្ថិភាពខ្ពស់។ តាមរយៈសេវាខាងលើទាំងនេះ អតិថិជនអាចផ្ទេរប្រាក់ទៅក្រៅប្រទេសតាមប្រព័ន្ធស្វីស (SWIFT) អ្នកដំណើរការតតិយភាគី ឬដៃគូសហការផ្ទេរប្រាក់ក្រៅប្រទេសនានារបស់គ្រឹះស្ថាន ដោយត្រូវភ្ជាប់ជាមួយឯកសារដែលតម្រូវដោយគ្រឹះស្ថាន។ លើសពីនេះទៀត អតិថិជនក៏អាចធ្វើប្រតិបត្តិការផ្ទេរប្រាក់តាមរយៈប័ណ្ណទូទាត់អន្តរជាតិទៅបណ្តាប្រទេសមួយចំនួននៅអាស៊ីអាគ្នេយ៍ និងទូទាត់ទំនិញតាមអនឡាញទៅប្រទេសជាច្រើនទូទាំងសកលលោកបានភ្លាមៗផងដែរ។ ម្យ៉ាងវិញទៀត មានគ្រឹះស្ថានមួយចំនួនបានផ្តល់សេវាជាអ្នកទទួលការទូទាត់ (Acquiring Services) ជាមួយក្រុមហ៊ុនធំៗមានដូចជា វីឆាតផេ (WeChat Pay) និងអាលីផេ (Alipay) ដែលផ្តល់សេវាទូទាត់ទំនិញនៅតាមបណ្តាពាណិជ្ជករទូទាត់រាយតាម QR Code ហើយសេវានេះកំពុងទទួលបានការពេញនិយមជាខ្លាំងនៅប្រទេសចិនដោយសារមានសុវត្ថិភាព ងាយស្រួល និងរហ័ស។ ដូចនេះ គ្រឹះស្ថានបានផ្តល់សេវានេះឱ្យពាណិជ្ជកររបស់ខ្លួន ដើម្បីទទួលយកការទូទាត់ពីភ្ញៀវទេសចរចិនបានកាន់តែច្រើនឡើង។

បច្ចុប្បន្ន កម្រៃសេវាផ្ទេរប្រាក់ឆ្លងដែននៅប្រទេសកម្ពុជាមានលក្ខណៈល្អប្រសើរច្រើនដោយសារគ្រឹះស្ថានអាចមានលទ្ធភាពសហការជាមួយដៃគូផ្ទេរប្រាក់ក្រៅប្រទេសដែលមានសក្តានុពលនៅលើទីផ្សារផ្ទេរប្រាក់អន្តរជាតិ ហើយមានអាជ្ញាប័ណ្ណផ្ទេរប្រាក់ក្រៅប្រទេសត្រឹមត្រូវពីធនាគារកណ្តាល ឬអាជ្ញាធរពាក់ព័ន្ធ ដើម្បីផ្តល់សេវាផ្ទេរប្រាក់ និងអតិថិជនអាចទទួលប្រាក់បានភ្លាមៗជាមួយកម្រៃសេវាសមរម្យ។ កម្រៃសេវាត្រូវបានគិតផ្អែកលើចន្លោះទំហំប្រាក់ដែលផ្ទេរ ឬគិតក្នុងមួយប្រតិបត្តិការក្នុងតម្លៃជាក់លាក់ណាមួយ ដែលជាទូទៅការផ្ទេរពីគណនីទៅគណនីមានតម្លៃទាបជាងការផ្ទេរទៅលេខទូរស័ព្ទ។ សម្រាប់កម្រៃសេវាផ្ទេរប្រាក់ដោយការសហការរវាងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់

និងដៃគូផ្ទេរប្រាក់ក្រៅប្រទេស និងកិច្ចសហការជាមួយអ្នកដំណើរការតតិយភាគី ក្នុងរង្វង់ពី ០,៦% ទៅ ៥,២% នៃទំហំប្រាក់ផ្ទេរក្នុងមួយប្រតិបត្តិការ កម្រៃសេវានេះមិនរួមបញ្ចូលថ្លៃសេវាផ្សេងៗទៀតនោះទេ។ ដោយឡែក សម្រាប់កម្រៃសេវាផ្ទេរប្រាក់តាមអ្នកដំណើរការតតិយភាគីស្ថិតនៅចន្លោះ ០,៣៩% ទៅ ៣,០% បូករួមទាំងតម្លៃ Cable Charge ជាមធ្យម ៥០ ដុល្លារអាមេរិក ក្នុងមួយប្រតិបត្តិការ។ រីឯកម្រៃសេវាផ្ទេរប្រាក់តាមប្រព័ន្ធ SWIFT មានតម្លៃ ០,១៥% នៃទំហំប្រាក់ប្រតិបត្តិការ និងរួមបញ្ចូលតម្លៃ Cable Charge ១៥ ដុល្លារអាមេរិក (តាមការកំណត់របស់ធនាគារភាគច្រើន)។

ទំហំប្រាក់នៃសេវាផ្ទេរប្រាក់តាមប្រព័ន្ធ SWIFT ដែលផ្តល់ដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវបានគេនិយមប្រើសម្រាប់ការទូទាត់ទំនិញក្នុងការធ្វើពាណិជ្ជកម្មមានទំហំប្រាក់ធំៗ ហើយអតិថិជនអាចប្រើសេវានេះបាននៅតាមបញ្ជរ ឬតាមសេវាអនឡាញ។ ជាទូទៅ យើងសង្កេតឃើញថា ទំហំប្រាក់សរុបនៃការផ្ទេរចេញតាមប្រព័ន្ធ SWIFT នេះមានចំនួនធំជាងការផ្ទេរចូល។ ចំណែកឯសេវាផ្ទេរប្រាក់តាមរយៈកិច្ចសហការក្នុងភាពជាដៃគូរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ជាមួយក្រុមហ៊ុនផ្ទេរប្រាក់ក្រៅប្រទេស ត្រូវបានប្រើប្រាស់ច្រើនសម្រាប់ការផ្ទេរប្រាក់ឱ្យក្រុមគ្រួសារ និងសម្រាប់ការធ្វើអាជីវកម្មខ្នាតតូចនិងមធ្យម ដោយសារសេវានេះមានកម្រៃសេវាទាប។ ដូចនេះ យើងពិនិត្យឃើញថា ទំហំប្រតិបត្តិការតាមសេវានេះមានការកើនឡើងច្រើន និងមានទំហំប្រាក់ផ្ទេរចូលច្រើនជាងការផ្ទេរចេញ។ អតិថិជនអាចប្រើសេវានេះដើម្បីផ្ទេរនិងទទួលប្រាក់បានតាមបញ្ជរ ភ្នាក់ងារ និងសេវាអនឡាញរបស់គ្រឹះស្ថាន។ គិតត្រឹមឆមាសទី១ ឆ្នាំ២០២១ ចំនួនប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែនសរុបរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ អ្នកដំណើរការតតិយភាគី និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់មានចំនួន ១,៤៧ លានប្រតិបត្តិការ និងមានទំហំប្រាក់ចំនួន ២៦,៥ ប៊ីលានដុល្លារអាមេរិក ស្មើនឹង ១០៤,៤% នៃផ.ស.ស។

ក្រាហ្វ ២០ - ចំនួនប្រតិបត្តិការ និងទំហំប្រាក់ប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែន




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ៥.២. គោលនយោបាយគាំទ្រ

ក្នុងគោលបំណងគ្រប់គ្រង និងពង្រីកបណ្ដាញសេវាផ្ទេរប្រាក់ក្រៅប្រទេស ធនាគារជាតិនៃកម្ពុជាបានដាក់ចេញប្រកាសស្ដីពី អ្នកដំណើរការតតិយភាគី ដើម្បីអនុញ្ញាតឱ្យបណ្ដាធនាគារសហការជាមួយក្រុមហ៊ុនផ្ទេរប្រាក់ក្រៅប្រទេសមួយ ឬច្រើនឱ្យដំណើរការជាអ្នកដំណើរការតតិយភាគីរបស់ខ្លួន ដោយត្រូវស្នើសុំការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជាជាមុន។ បន្ទាប់ពីទទួលបានការអនុញ្ញាត និងអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ធនាគារអាចប្រគល់ផ្នែកខ្លះនៃសេវាប្រតិបត្តិការទូទាត់សងប្រាក់ឱ្យក្រុមហ៊ុនទាំងនោះធ្វើប្រតិបត្តិការជំនួសបានតាមកិច្ចព្រមព្រៀងដែលបានកំណត់។ ទន្ទឹមនឹងនេះ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញប្រកាសស្ដីពី ការគ្រប់គ្រងគ្រឹះស្ថានផ្ដល់សេវាទូទាត់សងប្រាក់ដែលបានកំណត់អំពីលក្ខខណ្ឌនិងនីតិវិធីនៃការដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណរបស់នីតិបុគ្គលដែលមានបំណងផ្ដល់សេវាទូទាត់សងប្រាក់នៅកម្ពុជា។ បន្ថែមលើនេះ ប្រកាសមានគោលបំណងធានាសុវត្ថិភាព និងភាពរឹងមាំនៃសេវាទូទាត់សងប្រាក់ ជំរុញការប្រកួតប្រជែងឱ្យមានតម្លាភាព និងលើកកម្ពស់គំនិតច្នៃប្រឌិត ព្រមទាំងផ្ដល់ទំនុកចិត្តដល់សាធារណជនមកលើសេវាទូទាត់សងប្រាក់។

ស្របពេលតម្រូវការផ្ទេរប្រាក់ទៅក្រៅប្រទេសសម្រាប់ធ្វើអាជីវកម្មផ្ទេរប្រាក់ឱ្យក្រុមគ្រួសារ និងការទូទាត់ទំនិញរបស់ភ្ញៀវទេសចរអន្តរជាតិមានការកើនឡើង ធនាគារជាតិនៃកម្ពុជាបានបន្តជំរុញការប្រកួតប្រជែងក្នុងការផ្ដល់សេវាផ្ទេរប្រាក់ឆ្លងដែន តាមរយៈការអនុញ្ញាតឱ្យសហការសាកល្បង (Bilateral Connection) ជាមួយបណ្ដាក្រុមហ៊ុនផ្ទេរប្រាក់ក្រៅប្រទេស និងការអនុញ្ញាតឱ្យសហការជាមួយក្រុមហ៊ុនផ្ដល់ការទូទាត់តាមប័ណ្ណ និងការស្កេន QR Code ដែលគ្រឹះស្ថានត្រូវស្នើសុំមកធនាគារជាតិនៃកម្ពុជាជាមុនផងដែរ។ ដើម្បីពិនិត្យអំពីលទ្ធភាព និងហានិភ័យដែលអាចកើតមានឡើងសម្រាប់ការសហការនេះ ធនាគារជាតិនៃកម្ពុជាបានពិនិត្យ និងសិក្សាយ៉ាងល្អិតល្អន់ទៅលើអត្តសញ្ញាណរបស់ក្រុមហ៊ុននីមួយៗ រួមទាំងលំហូរប្រតិបត្តិការរបស់សេវា ការកំណត់ទំហំប្រាក់របស់ប្រតិបត្តិការ ការកំណត់ចំនួនប្រទេសធ្វើប្រតិបត្តិការ ការគ្រប់គ្រងហានិភ័យនៃការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងការការពារអតិថិជនជាដើម។ គ្រឹះស្ថានចាំបាច់ត្រូវអនុវត្តនិងគោរពតាមលក្ខខណ្ឌដែលបានអនុញ្ញាតឱ្យបានខ្ជាប់ខ្ជួន និងអនុញ្ញាតឱ្យផ្ដល់សេវាបានជាមួយប្រទេសដែលមានទំនាក់ទំនងជាមួយប្រទេសកម្ពុជា ភាគច្រើនជាប្រទេសក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកដែលមានអ្នកវិនិយោគ អ្នកជំនួញ ភ្ញៀវទេសចរទៅមកច្រើន និងជាពិសេសប្រទេសដែលមានពលករកម្ពុជារស់នៅច្រើន មានដូចជាប្រទេសចិន ជប៉ុន កូរ៉េខាងត្បូង ម៉ាឡេស៊ី ថៃ និងប្រទេសផ្សេងៗទៀត ក្នុងទំហំប្រាក់សមស្របដែលធនាគារជាតិនៃកម្ពុជាអាចគ្រប់គ្រងបាន។ ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជាក៏តភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ជាមួយប្រទេសក្នុងតំបន់ដូចជា ថៃ និងម៉ាឡេស៊ី ក្នុងគោលបំណងធ្វើប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែនជាមួយគ្នាបាន ដើម្បីជួយកាត់បន្ថយចំណាយរបស់គ្រឹះស្ថានក្នុងការតភ្ជាប់ប្រព័ន្ធជាមួយក្រុមហ៊ុនក្រៅប្រទេសដោយខ្លួនឯង និងសម្រួលដល់ប្រជាពលរដ្ឋអាចទទួលបានសេវាផ្ទេរប្រាក់ដែលអាចជឿទុកចិត្តបាន និងមានកម្រៃសេវាទាប។

បច្ចុប្បន្ន ដោយមានការគាំទ្រពីសំណាក់ធនាគារជាតិនៃកម្ពុជាក្នុងការដាក់ឱ្យប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech) ការផ្ដល់ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់រួម និងការគ្រប់គ្រងត្រួតពិនិត្យ

យ៉ាងជិតដល់ ព្រមទាំងការអនុវត្តកាតព្វកិច្ចរបស់គ្រឹះស្ថានផ្តល់សេវាផ្ទេរប្រាក់ឆ្លងដែនបានល្អប្រសើរផងនោះ ការណ៍នេះធ្វើឱ្យសេវាផ្ទេរប្រាក់ឆ្លងដែនមានរីកចម្រើនគួរឱ្យកត់សម្គាល់ គឺប្រជាពលរដ្ឋទាំងក្នុងនិងក្រៅប្រទេស ពលករ អ្នកវិនិយោគ និងអ្នកជំនួញ អាចទទួលបានសេវាផ្លូវការច្រើនជម្រើសដែលមានសុវត្ថិភាព តម្លៃសមរម្យ និងប្រកបដោយបរិយាបន្ន។

## ៥.៣. របាយការណ៍ផ្ទេរប្រាក់ឯកជនឆ្លងដែនតាមប្រព័ន្ធរបាយការណ៍ប្រតិបត្តិការអន្តរជាតិ - ITRS

ធនាគារជាតិនៃកម្ពុជា បានដាក់ឱ្យដំណើរការប្រព័ន្ធរបាយការណ៍ប្រតិបត្តិការអន្តរជាតិ (International Transactions Reporting System - ITRS) ក្នុងឆ្នាំ២០០៣ ក្នុងគោលបំណងផ្តល់ភាពងាយស្រួល និងជាមធ្យោបាយដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុសម្រាប់រាយការណ៍អំពីការផ្ទេរប្រាក់ឆ្លងដែនជាលក្ខណៈឯកជន។ បច្ចុប្បន្ន មានគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុចំនួន ៥៧ កំពុងរាយការណ៍តាមរយៈប្រព័ន្ធ ITRS នេះ។ ការផ្ទេរប្រាក់ឆ្លងដែនជាលក្ខណៈឯកជន ជាការផ្ទេរប្រាក់ផ្លូវការបែបអេឡិចត្រូនិកចម្បងមួយ តាមរយៈប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ ហើយការផ្ទេរប្រាក់នេះភាគច្រើនធ្វើឡើងដោយពលករចំណាកស្រុកនៅក្រៅប្រទេស។ ក្នុងឆមាសទី១ ឆ្នាំ២០២១ ពលករចំណាកស្រុកបានផ្ទេរប្រាក់មកក្រុមគ្រួសារពីប្រទេសកូរ៉េខាងត្បូងប្រមាណ ៦៨% នៃទំហំប្រាក់ផ្ទេរឆ្លងដែនជាលក្ខណៈឯកជនសរុប ហើយសហរដ្ឋអាមេរិកចំនួន ៦% និងបន្តដោយប្រទេសអូស្ត្រាលី ៤,៨% និងប្រទេសម៉ាឡេស៊ី ៤,២%។ ធនាគារជាតិនៃកម្ពុជាដែលជាបញ្ញត្តិករ និងអាជ្ញាធរត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់បានជំរុញឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា ឬផលិតផលថ្មីៗប្រកបដោយនវានុវត្តន៍ ដើម្បីលើកកម្ពស់ដល់ការប្រកួតប្រជែង ក៏ដូចជារួមចំណែកធ្វើឱ្យការផ្តល់សេវាផ្ទេរប្រាក់កាន់តែមាននកម្រៃទាប ងាយស្រួលឆាប់រហ័ស និងមានតម្លាភាពសម្រាប់អតិថិជន។ សរុបមក ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា ឬផលិតផលថ្មីៗទាំងនេះ ជាកត្តាដ៏សំខាន់ក្នុងការលើកទឹកចិត្តឱ្យសាធារណជនងាកមកប្រើប្រាស់សេវាផ្ទេរប្រាក់តាមបណ្តាញផ្លូវការវិញ៕

ក្រាហ្វ ២១ - ទំហំប្រតិបត្តិការផ្ទេរប្រាក់ឆ្លងដែនជាលក្ខណៈឯកជន តាមប្រព័ន្ធ ITRS




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ១ - ច្បាប់ និងបទប្បញ្ញត្តិ

| លរ. | ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិ | ឆ្នាំចេញផ្សាយ |
|---|---|---|
| ១ | ច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារនៃកម្ពុជា | ១៩៩៦ |
| ២ | ច្បាប់ស្តីពី ការគ្រប់គ្រងការប្តូរប្រាក់ | ១៩៩៧ |
| ៣ | ច្បាប់ស្តីពី គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ | ១៩៩៩ |
| ៤ | ច្បាប់ស្តីពី ឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ | ២០០៥ |
| ៥ | ច្បាប់ស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម | ២០២០ |
| ៦ | ប្រកាសស្តីពី ការគ្រប់គ្រងហានិភ័យមានលក្ខណៈជាប្រព័ន្ធនៃប្រព័ន្ធទូទាត់សងប្រាក់ | ២០០៦ |
| ៧ | ប្រកាសស្តីពី ប្រតិបត្តិការនៃគណនីទូទាត់ | ២០០៦ |
| ៨ | ប្រកាសស្តីពី មូលប្បទានបត្រស្តង់ដារ | ២០០៨ |
| ៩ | ប្រកាសស្តីពី ការកំណត់លេខអត្តសញ្ញាណធនាគារ | ២០០៨ |
| ១០ | ប្រកាសស្តីពី ការដាក់ឱ្យប្រើគំរូបញ្ជាទូទាត់សម្រាប់ការផ្ទេរឥណទាន | ២០១០ |
| ១១ | ប្រកាសស្តីពី អ្នកដំណើរការតតិយភាគី | ២០១០ |
| ១២ | ប្រកាសស្តីពី ការផ្តល់សន្ទនីយភាពចំពោះសមាជិកសភាផាត់ទាត់ជាតិ | ២០១៤ |
| ១៣ | ប្រកាសស្តីពី សមាជិកភាពនៃប្រព័ន្ធ FAST System និង Central Shared Switch | ២០១៦ |
| ១៤ | ប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់វិធាន និងនីតិវិធីសភាផាត់ទាត់ជាតិ | ២០១៦ |
| ១៥ | ប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់វិធាន និងនីតិវិធី Cambodian Shared Switch | ២០១៧ |
| ១៦ | ប្រកាសស្តីពី ការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ | ២០១៧ |
| ១៧ | ប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់ស្លាកសញ្ញាសម្រាប់ប្រព័ន្ធសេវាទូទាត់រហ័ស (FAST Payment) និងប្រព័ន្ធខេមបូឌានស៊ែស្វីច (Cambodian Shared Switch) | ២០១៨ |

| លរ. | ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិ | ឆ្នាំចេញផ្សាយ |
|---|---|---|
| ១៨ | ប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់ស្លាកសញ្ញាសម្រាប់ប្រព័ន្ធ Retail Pay | ២០១៩ |
| ១៩ | ប្រកាសស្តីពី ការដាក់ឱ្យប្រើវិធាននិងនីតិវិធី Retail Pay | ២០២០ |
| ២០ | ប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់គំរូបរិច្ឆិនភាពបច្ចេកទេស ខេអេចឃ្យូអរកូត (KHQR Code) សម្រាប់ការទូទាត់សងប្រាក់ | ២០២០ |
| ២១ | ប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់វិធាននិងនីតិវិធីប្រព័ន្ធបាគង | ២០២០ |
| ២២ | ប្រកាសស្តីពី ការដាក់ឱ្យប្រើប្រាស់ស្លាកសញ្ញាប្រព័ន្ធបាគង | ២០២០ |
| ២៣ | ក្របខណ្ឌត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ | ២០២០ |
| ២៤ | សារាចរណែនាំស្តីពី ការពង្រឹងការអនុវត្តច្បាប់ឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ | ២០១៦ |
| ២៥ | សារាចរណែនាំស្តីពី នីតិវិធីស្គាល់អត្តសញ្ញាណអតិថិជន និងការកំណត់ទំហំប្រាក់ប្រតិបត្តិការសម្រាប់សេវាទូទាត់សងប្រាក់នៅកម្ពុជា | ២០២១ |
| ២៦ | សេចក្តីជូនដំណឹងស្តីពី កម្រៃប្រតិបត្តិការផ្ទេរប្រាក់សម្រាប់ "សេវាទូទាត់រហ័ស" (FAST Payment System) | ២០១៧ |
| ២៧ | សេចក្តីជូនដំណឹងស្តីពី កម្រៃ សោហ៊ុយ និងការពិន័យសម្រាប់ប្រព័ន្ធខេមបូឌានស៊ែស្វីច | ២០១៧ |
| ២៨ | សេចក្តីជូនដំណឹងស្តីពី ការកែសម្រួលគោលនយោបាយសមាជិកភាពប្រព័ន្ធផាត់ទាត់ជាតិ (National Clearing System) របស់សភាផាត់ទាត់ជាតិ | ២០១៨ |
| ២៩ | សេចក្តីជូនដំណឹងស្តីពី គោលការណ៍ណែនាំក្នុងការចូលរួមជាសមាជិកមិនផ្ទាល់ និងកិច្ចសហការរវាងសមាជិកផ្ទាល់និងសមាជិកមិនផ្ទាល់ក្នុងប្រព័ន្ធផាត់ទាត់ជាតិ | ២០១៩ |
| ៣០ | សេចក្តីជូនដំណឹងស្តីពី ការអនុវត្តគោលនយោបាយសម្រាប់ប្រព័ន្ធខេមបូឌានស៊ែស្វីច | ២០២០ |
| ៣១ | សេចក្តីជូនដំណឹងស្តីពី គោលនយោបាយពាក់ព័ន្ធនឹងសមាជិកភាពប្រព័ន្ធខេមបូឌាន-ស៊ែស្វីច | ២០២០ |
| ៣២ | សេចក្តីណែនាំស្តីពី កាលបរិច្ឆេទ និងរយៈពេលសម្រាប់ការបញ្ជូនរបាយការណ៍របស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ | ២០១៩ |
| ៣៣ | សេចក្តីណែនាំស្តីពី ការជ្រើសរើស និងការទទួលស្គាល់សវនករគណនេយ្យឯករាជ្យចំពោះគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ | ២០១៩ |
| ៣៤ | ឯកសារបាគង White Paper | ២០២០ |

# ឧបសម្ព័ន្ធ២ - បញ្ជីរាយនាមឈ្មោះសមាជិកប្រព័ន្ធបាគង

| ល.រ | គ្រឹះស្ថានដែលបានដាក់ដំណើរការជាផ្លូវការ | ល.រ | គ្រឹះស្ថានកំពុងធ្វើសន្ទានកម្មតភ្ជាប់ប្រព័ន្ធ |
|---|---|---|---|
| ១ | ធនាគារ អេស៊ីលីដា ភីអិលស៊ី | ១ | ធនាគារ ផេនដា ខមមើសល ប៊ែង ម.ក |
| ២ | ធនាគារ វីង (ខេមបូឌា) ម.ក | ២ | ធនាគារ ស៊ិនហាន (ខេមបូឌា) ម.ក |
| ៣ | ធនាគារ ពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា | ៣ | ធនាគារ កម្ពុជាពាណិជ្ជ ចំកាត់ |
| ៤ | ធនាគារ វឌ្ឍនៈ | ៤ | ធនាគារ គូកមីន កម្ពុជា ភីអិលស៊ី |
| ៥ | ធនាគារ ស្ថាបនា ភីអិលស៊ី | ៥ | សាជីវកម្មធនាគារ កាថេយ្យូណៃធីតកម្ពុជា ចំកាត់ |
| ៦ | ធនាគារ ប្រៃសណីយ៍ កម្ពុជា ក.អ | ៦ | ធនាគារ អភិវឌ្ឍន៍ជនបទ និងកសិកម្ម |
| ៧ | ធនាគារ ព្រីនស៍ ម.ក | ៧ | ធនាគារ ចិន (ហុងកុង) លីមីធីត សាខាភ្នំពេញ |
| ៨ | ធនាគារ កាណាឌីយ៉ា ក.អ | ៨ | ធនាគារ ហុងលីអុង (ខេមបូឌា) ភីអិលស៊ី |
| ៩ | ធនាគារ ជីប ម៉ុង ខមមើសល ប៊ែង ម.ក | ៩ | ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក |
| ១០ | ធនាគារ ភ្នំពេញពាណិជ្ជ ម.ក | ១០ | ធនាគារ អេស ប៊ី អាយ លីហ្វូ ម.ក |
| ១១ | ធនាគារ វិនិយោគ និងអភិវឌ្ឍន៍ កម្ពុជា ភីអិលស៊ី | ១១ | ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក |
| ១២ | ធនាគារ ហ្វីលីព ភីអិលស៊ី | ១២ | ធនាគារ សហគ្រាសធុនតូច និងមធ្យម កម្ពុជា ម.ក |
| ១៣ | ធនាគារ វឌ្ឍនៈ អាស៊ី ចំកាត់ | ១៣ | ធនាគារ ពាណិជ្ជទីមួយ សាខាភ្នំពេញ |
| ១៤ | ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក | ១៤ | ធនាគារ សហពាណិជ្ជ ក.អ |
| ១៥ | ធនាគារ ហត្ថា ម.ក | ១៥ | ធនាគារ ប្រេដ ប៊ែង (ខេមបូឌា) ភីអិលស៊ី |
| ១៦ | ធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី | ១៦ | ធនាគារ កម្ពុជាអាស៊ី ចំកាត់ |
| ១៧ | ធនាគារ មេយប៊ែង (ខេមបូឌា) ម.ក | ១៧ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ អម្រឹត ម.ក |
| ១៨ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ប្រាសាក់ ម.ក | ១៨ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ មហានគរ ម.ក |
| ១៩ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ អេ អឹម ខេ ភីអិលស៊ី | ១៩ | គ្រឹះស្ថាន អេស៊ា ឃែស អិចប្រេស ម.ក |
| ២០ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ដាប់ប៊ែលយូប៊ី ហ្វាយនែន ឯ.ក | ២០ | គ្រឹះស្ថាន បងឡូយ ផេម៉ិន ម.ក |
| ២១ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី | ២១ | គ្រឹះស្ថាន ដ្រាហ្គនហ្វ្លាយ ហ្វីនថេក (ខេមបូឌា) ម.ក |
| ២២ | គ្រឹះស្ថាន ស្ពឺត ផេ ម.ក | ២២ | គ្រឹះស្ថាន ផាយ ផេ ម.ក |
| ២៣ | គ្រឹះស្ថាន ទ្រូ ម៉ាន់នី (ខេមបូឌា) ម.ក | ២៣ | គ្រឹះស្ថាន កាណាឌីយ៉ា ម៉ូបៃល ម៉ាន់នី ម.ក |
| ២៤ | គ្រឹះស្ថាន អ៊ី-ម៉ាន់នី ផេម៉ិន សឺលូសិន ម.ក | ២៤ | គ្រឹះស្ថាន អាយផេ88 (ខេមបូឌា) ម.ក |
| ២៥ | គ្រឹះស្ថាន លីហ្វូ ផេប្រ៊ូ ភីអិលស៊ី | ២៥ | គ្រឹះស្ថានធានស្វ៊ិនធើណេសិនណលថេកណឡជី ម.ក |
| | | ២៦ | គ្រឹះស្ថាន យេស អ៊ិននើវេសិន ម.ក |
| | | ២៧ | គ្រឹះស្ថាន អ៊ីឌាល (ខេមបូឌា) ម.ក |
| | | ២៨ | គ្រឹះស្ថាន ជីប៊ីស៊ីអាយ វេនឈ័រ ម.ក |
| | | ២៩ | គ្រឹះស្ថាន តារាសាគរ ផេ ម.ក |

# ឧបសម្ព័ន្ធ៣ - បញ្ជីរាយនាមឈ្មោះគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់

| ល.រ. | គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ | | |
|---|---|---|---|
| ១ | នាមករណ៍ | គ្រឹះស្ថាន អ៊ីឌាល (ខេមបូឌា) ម.ក | |
| | អាជ្ញាប័ណ្ណធនាគារជាតិនៃកម្ពុជា | អ.០០១.១៧ ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៧ | |
| | អាសយដ្ឋាន | អាគារលេខ ១៥ ផ្លូវលេខ ៣៤៧ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| | លេខទូរស័ព្ទទំនាក់ទំនង | (+៨៥៥) ៩៦ ៤៦៦ ៣៣៣៣ / ៩៦ ៨១៥ ៧៣៨៨ | |
| | សារអេឡិចត្រូនិក | info@edeel.com | |
| | គេហទំព័រ | www.edeel.com | |
| | ពាណិជ្ជសញ្ញា (យីហោគ្រឹះស្ថាន & យីហោផលិតផល) | | |
| ២ | នាមករណ៍ | គ្រឹះស្ថាន ស៊ីធេល ហ្វាយនែនសល សឺវីស ម.ក | |
| | អាជ្ញាប័ណ្ណធនាគារជាតិនៃកម្ពុជា | អ.០០១.១៨ ថ្ងៃទី០២ ខែមករា ឆ្នាំ២០១៨ | |
| | អាសយដ្ឋាន | អាគារលេខ១៨៩ ផ្លូវលេខ៨៣២ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| | លេខទូរស័ព្ទទំនាក់ទំនង | (+៨៥៥) ១៨ ៨ ៨០០ ៨០០ | |
| | សារអេឡិចត្រូនិក | mpay@bestmpay.com | |
| | គេហទំព័រ | bestmpay.com | |
| | ពាណិជ្ជសញ្ញា (យីហោគ្រឹះស្ថាន & យីហោផលិតផល) | | |
| ៣ | នាមករណ៍ | គ្រឹះស្ថាន ឃូប៊ីល ម.ក | |
| | អាជ្ញាប័ណ្ណធនាគារជាតិនៃកម្ពុជា | អ.០០២.១៨ ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨ | |
| | អាសយដ្ឋាន | អាគារលេខ B៣ & C៣-១ ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| | លេខទូរស័ព្ទទំនាក់ទំនង | (+៨៥៥) ៣៨ ៣៣០០ ៨៨៨ | |
| | សារអេឡិចត្រូនិក | support@coobill.com.kh | |
| | គេហទំព័រ | www.coobill.com.kh | |
| | ពាណិជ្ជសញ្ញា (យីហោគ្រឹះស្ថាន & យីហោផលិតផល) | | |
| ៤ | នាមករណ៍ | គ្រឹះស្ថាន ទ្រូ ម៉ាន់នី (ខេមបូឌា) ម.ក | |
| | អាជ្ញាប័ណ្ណធនាគារជាតិនៃកម្ពុជា | អ.០០៣.១៨ ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ | |
| | អាសយដ្ឋាន | អគារ Keystone (#១៨៦) ជាន់ទី១ ទី២ និងទី៤ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ | |
| | លេខទូរស័ព្ទទំនាក់ទំនង | (+៨៥៥) ២៣ ៩៩៩ ៦៣៩ | |
| | សារអេឡិចត្រូនិក | info@truemoney.com.kh | |
| | គេហទំព័រ | www.truemoney.com.kh | |
| | ពាណិជ្ជសញ្ញា (យីហោគ្រឹះស្ថាន & យីហោផលិតផល) | | |

| ល.រ | គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ | | |
|---|---|---|---|
| ៥ | នាមករណ៍ | គ្រឹះស្ថាន លី ហួរ ផេ ប្រូ ភីអិលស៊ី | |
| | អាជ្ញាប័ណ្ណធនាគារជាតិនៃកម្ពុជា | អ.០០៤.១៨ ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨ | |
| | អាសយដ្ឋាន | ដីឡូត៍លេខ ២៤៣-២៤៤ ផ្លូវលេខ៥៩៨ ភូមិទួលថ្មាន់ សង្កាត់ទួលសង្កែទី២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| | លេខទូរស័ព្ទទំនាក់ទំនង | (+៨៥៥) ៨៧ ៦០១ ១១១ | |
| | សារអេឡិចត្រូនិក | info@lyhourpay.com | |
| | គេហទំព័រ | www.lyhourpay.com | |
| | ពាណិជ្ជសញ្ញា (យីហោគ្រឹះស្ថាន & យីហោផលិតផល) | | |
| ៦ | នាមករណ៍ | គ្រឹះស្ថាន ស្ពីត ផេ ម.ក | |
| | អាជ្ញាប័ណ្ណធនាគារជាតិនៃកម្ពុជា | អ.០០៥.១៨ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៨ | |
| | អាសយដ្ឋាន | ផ្ទះលេខ B៤៨ - B៤៩ ផ្លូវបុរីឡាសែន ភូមិ១៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| | លេខទូរស័ព្ទទំនាក់ទំនង | (+៨៥៥) ៧០ ៩៩៧ ៧៧៥ | |
| | សារអេឡិចត្រូនិក | info@speedpayplc.com | |
| | គេហទំព័រ | www.speedpayplc.com | |
| | ពាណិជ្ជសញ្ញា (យីហោគ្រឹះស្ថាន & យីហោផលិតផល) | | |
| ៧ | នាមករណ៍ | គ្រឹះស្ថាន កាណាឌីយ៉ា ម៉ូបៃល ម៉ាន់នី ម.ក | |
| | អាជ្ញាប័ណ្ណធនាគារជាតិនៃកម្ពុជា | អ.០០៦.១៨ ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៨ | |
| | អាសយដ្ឋាន | វិមានកាណាឌីយ៉ា លេខ៣១៥ ជាន់ទី២៧ មហាវិថីព្រះមុន្នីវង្ស កែងវិថីព្រះអង្គឌួង សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| | លេខទូរស័ព្ទទំនាក់ទំនង | (+៨៥៥) ២៣ ៩៨៩ ៨០៩ | |
| | សារអេឡិចត្រូនិក | info@darapay.com.kh | |
| | គេហទំព័រ | www.darapay.com.kh | |
| | ពាណិជ្ជសញ្ញា (យីហោគ្រឹះស្ថាន & យីហោផលិតផល) | | |
| ៨ | នាមករណ៍ | គ្រឹះស្ថាន អាយផេ88 (ខេមបូឌា) ម.ក | |
| | អាជ្ញាប័ណ្ណធនាគារជាតិនៃកម្ពុជា | អ.០០៧.១៨ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៨ | |
| | អាសយដ្ឋាន | ខុនដូកាសា មេរីឌាន អាគារ Orient ជាន់ទី២ លេខ A០១០១ អាគារលេខ០១ ផ្លូវហាវើក កោះពេជ្រ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| | លេខទូរស័ព្ទទំនាក់ទំនង | (+៨៥៥) ២៣ ៩០១ ៧៨៨ | |
| | សារអេឡិចត្រូនិក | info@ipay88.com.kh | |
| | គេហទំព័រ | www.ipay88.com.kh | |
| | ពាណិជ្ជសញ្ញា (យីហោគ្រឹះស្ថាន & យីហោផលិតផល) | | |

| ល.រ | គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ | | |
|---|---|---|---|
| ៩ | នាមករណ៍ | គ្រឹះស្ថាន ផាយ ផេ ម.ក | |
| | អាជ្ញាប័ណ្ណធនាគារជាតិនៃកម្ពុជា | អ.០០៨.១៨ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ | |
| | អាសយដ្ឋាន | ផ្ទះលេខ២០ ផ្លូវលេខ២១៧ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| | លេខទូរស័ព្ទទំនាក់ទំនង | (+៨៥៥) ២៣ ៩៨៨ ៩៨៩ / ២៣ ៨៨៩ ៩៩៨ | |
| | សារអេឡិចត្រូនិក | info@pipay.com | |
| | គេហទំព័រ | www.pipay.com | |
| | ពាណិជ្ជសញ្ញា (យីហោគ្រឹះស្ថាន & យីហោផលិតផល) | | |
| ១០ | នាមករណ៍ | គ្រឹះស្ថាន ធានស៊ូ អ៊ិនធើណេសិនណល ថេកណឡូជី ម.ក | |
| | អាជ្ញាប័ណ្ណធនាគារជាតិនៃកម្ពុជា | អ.០០៩.១៨ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ | |
| | អាសយដ្ឋាន | អាគារលេខ៩៨៨ ផ្លូវលេខ១២៨ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| | លេខទូរស័ព្ទទំនាក់ទំនង | (+៨៥៥) ២៣ ៩៨៨ ៧៧៧ | |
| | សារអេឡិចត្រូនិក | info@coolcashcam.com | |
| | គេហទំព័រ | www.coolcashcam.com | |
| | ពាណិជ្ជសញ្ញា (យីហោគ្រឹះស្ថាន & យីហោផលិតផល) | | |
| ១១ | នាមករណ៍ | គ្រឹះស្ថាន បងឡួយ ផេមិន ម.ក | |
| | អាជ្ញាប័ណ្ណធនាគារជាតិនៃកម្ពុជា | អ.០១០.១៨ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ | |
| | អាសយដ្ឋាន | ផ្ទះលេខ៨៧ ផ្លូវលេខ៦៣ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| | លេខទូរស័ព្ទទំនាក់ទំនង | (+៨៥៥) ២៣ ៥៣២ ០៨៨៨ | |
| | សារអេឡិចត្រូនិក | contact@bongloy.com | |
| | គេហទំព័រ | www.bongloy.com | |
| | ពាណិជ្ជសញ្ញា (យីហោគ្រឹះស្ថាន & យីហោផលិតផល) | | |
| ១២ | នាមករណ៍ | គ្រឹះស្ថាន អេស៊ា វ៉ៃស អិចប្រេស ម.ក | |
| | អាជ្ញាប័ណ្ណធនាគារជាតិនៃកម្ពុជា | អ.០១១.១៨ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ | |
| | អាសយដ្ឋាន | ផ្ទះលេខB២-០៣៥-០៣៦ ផ្លូវកោះពេជ្រ (ស្ពានឥន្ទនូ) សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| | លេខទូរស័ព្ទទំនាក់ទំនង | (+៨៥៥) ៩៨ ៦៦៦ ៦៧៨ / ៩៩ ៦៦៦ ៦៧៨ / ៧១ ៦៦៦ ៦៧៨ | |
| | សារអេឡិចត្រូនិក | info@asiaweiluy.com | |
| | គេហទំព័រ | www.asiaweiluy.com | |
| | ពាណិជ្ជសញ្ញា (យីហោគ្រឹះស្ថាន & យីហោផលិតផល) | | |

| ល.រ. | គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ | | |
|---|---|---|---|
| ១៣ | នាមករណ៍ | គ្រឹះស្ថាន ហួយវ៉ន ផេ ម.ក | |
| | អាជ្ញាប័ណ្ណធនាគារជាតិនៃកម្ពុជា | អ.០១២.១៨ ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៨ | |
| | អាសយដ្ឋាន | អាគារលេខ៦២ មហាវិថីព្រះនរោត្តម សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| | លេខទូរស័ព្ទទំនាក់ទំនង | (+៨៥៥) ២៣ ២៣១ ៩៩៩ | |
| | សារអេឡិចត្រូនិក | 41018@huione.com | |
| | គេហទំព័រ | www.7572.com | |
| | ពាណិជ្ជសញ្ញា (យីហោគ្រឹះស្ថាន & យីហោផលិតផល) | HUIONE PAY | |
| ១៤ | នាមករណ៍ | គ្រឹះស្ថាន អ៊ី-ម៉ាន់នី ផេមិុន សឺលូសិន ម.ក | |
| | អាជ្ញាប័ណ្ណធនាគារជាតិនៃកម្ពុជា | អ.០១៣.១៨ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៨ | |
| | អាសយដ្ឋាន | អាគារលេខ១៩៩ ផ្លូវលេខ២៤៥ សង្កាត់ទួលស្វាយព្រៃទី២ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| | លេខទូរស័ព្ទទំនាក់ទំនង | (+៨៥៥) ២៣ ៦៨៦ ៨៨៦៨ | |
| | សារអេឡិចត្រូនិក | emoney@metfone.com.kh | |
| | គេហទំព័រ | www.emoney.com.kh | |
| | ពាណិជ្ជសញ្ញា (យីហោគ្រឹះស្ថាន & យីហោផលិតផល) | money | money |
| ១៥ | នាមករណ៍ | គ្រឹះស្ថាន ដ្រាហ្គនហ្វ្លាយ ហ្វីនថេក (ខេមបូឌា) ម.ក | |
| | អាជ្ញាប័ណ្ណធនាគារជាតិនៃកម្ពុជា | អ.០០១.១៩ ថ្ងៃទី០៨ ខែកុម្ភៈឆ្នាំ២០១៩ | |
| | អាសយដ្ឋាន | អាគារ ROSE GARDEN លេខ២៥២ ជាន់ផ្ទាល់ដី មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| | លេខទូរស័ព្ទទំនាក់ទំនង | (+៨៥៥) ៩៨ ២១៨ ៥៥៥ / ៩៨ ២០៩ ៥៥៥ | |
| | សារអេឡិចត្រូនិក | Helpdesk@payluy.com.kh | |
| | គេហទំព័រ | www.payluy.com.kh | |
| | ពាណិជ្ជសញ្ញា (យីហោគ្រឹះស្ថាន & យីហោផលិតផល) | dragonfly FINTECH | PL Payluy |
| ១៦ | នាមករណ៍ | គ្រឹះស្ថាន ដាយនែមិក ផេមិុន ម.ក | |
| | អាជ្ញាប័ណ្ណធនាគារជាតិនៃកម្ពុជា | អ.០០២.១៩ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩ | |
| | អាសយដ្ឋាន | ដីឡូត៍លេខ ៥៨ អាគារវៃនផាក ជាន់ទី១ បន្ទប់លេខ ១៣អិន ភូមិ១ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| | លេខទូរស័ព្ទទំនាក់ទំនង | (+៨៥៥) ២៣ ៩៨៩ ១៨៦ | |
| | សារអេឡិចត្រូនិក | dpkh@dynamicg.com | |
| | គេហទំព័រ | http://dpkh@dynamicg.com | |
| | ពាណិជ្ជសញ្ញា (យីហោគ្រឹះស្ថាន & យីហោផលិតផល) | | |

| ល.រ | គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ | | |
|---|---|---|---|
| ១៧ | នាមករណ៍ | គ្រឹះស្ថាន ដាប់បែលយូ អាយ ប៊ី អេស.ខេអេច.ផេម៉ិន ស៊ីវីស ម.ក | |
| | អាជ្ញាប័ណ្ណធនាគារជាតិនៃកម្ពុជា | អ.០០៣.១៩ ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៩ | |
| | អាសយដ្ឋាន | ផ្ទះលេខ១១៤ ផ្លូវសហភាពរុស្ស៊ី សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| | លេខទូរស័ព្ទទំនាក់ទំនង | (+៨៥៥) ៨១ ៩៩៩ ០៦៩ | |
| | សារអេឡិចត្រូនិក | info@m.wibs-khplc.com | |
| | គេហទំព័រ | www.wibs-khplc.com | |
| | ពាណិជ្ជសញ្ញា (យីហោគ្រឹះស្ថាន & យីហោផលិតផល) | | |
| ១៨ | នាមករណ៍ | គ្រឹះស្ថាន តារាសាគរ ផេ ម.ក | |
| | អាជ្ញាប័ណ្ណធនាគារជាតិនៃកម្ពុជា | អ.០០៥.១៩ ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៩ | |
| | អាសយដ្ឋាន | អាគារលេខ i៩៦ D.I.Riviera វិថី Road Park កោះពេជ្រ ភូមិ១៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| | លេខទូរស័ព្ទទំនាក់ទំនង | (+៨៥៥) ៩៣ ៩៣៩ ៩៧៧ | |
| | សារអេឡិចត្រូនិក | service@darasakorpay.com | |
| | គេហទំព័រ | www.darasakorpay.com | |
| | ពាណិជ្ជសញ្ញា (យីហោគ្រឹះស្ថាន & យីហោផលិតផល) | 七星支付 DARA SAKOR PAY | DSP DSP |
| ១៩ | នាមករណ៍ | គ្រឹះស្ថាន បៃ សេន ថេកណូឡូជី ម.ក | |
| | អាជ្ញាប័ណ្ណធនាគារជាតិនៃកម្ពុជា | អ.០០៦.១៩ ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩ | |
| | អាសយដ្ឋាន | Elite Town លេខ ០៥ ផ្លូវ Stanford សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| | លេខទូរស័ព្ទទំនាក់ទំនង | (+៨៥៥) ៧១ ៩៩៩ ៧៧៧៩ | |
| | សារអេឡិចត្រូនិក | មិនមាន | |
| | គេហទំព័រ | មិនមាន | |
| | ពាណិជ្ជសញ្ញា (យីហោគ្រឹះស្ថាន & យីហោផលិតផល) | BST | BST |
| ២០ | នាមករណ៍ | គ្រឹះស្ថាន អ៊ែរទ្រីណូ គ្លូបល ម.ក | |
| | អាជ្ញាប័ណ្ណធនាគារជាតិនៃកម្ពុជា | អ.០០៧.១៩ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩ | |
| | អាសយដ្ឋាន | ផ្ទះលេខ៥៤B (ជាន់ផ្ទាល់ដី និងជាន់ទី១) ផ្លូវលេខ៩៥ សង្កាត់បឹងកេងកងទី៣ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| | លេខទូរស័ព្ទទំនាក់ទំនង | (+៨៥៥) ៩៦ ៩៥៥ ៥៥៥៦ | |
| | សារអេឡិចត្រូនិក | Wei.chen@aetrino.com | |
| | គេហទំព័រ | មិនមាន | |
| | ពាណិជ្ជសញ្ញា (យីហោគ្រឹះស្ថាន & យីហោផលិតផល) | AETRINO | |

| ល.រ | គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ | | |
|---|---|---|---|
| ២១ | នាមករណ៍ | គ្រឹះស្ថាន ផារ៉ាហ្គន ផេមិន សឺវីស ម.ក | |
| | អាជ្ញាប័ណ្ណធនាគារជាតិនៃកម្ពុជា | អ.០០១.២០ ថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០ | |
| | អាសយដ្ឋាន | អាគារលេខ២១៦ ផ្លូវនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| | លេខទូរស័ព្ទទំនាក់ទំនង | (+៨៥៥) ១២ ៨៥៦ ២៣៧ | |
| | សារអេឡិចត្រូនិក | មិនមាន | |
| | គេហទំព័រ | មិនមាន | |
| | ពាណិជ្ជសញ្ញា (យីហោគ្រឹះស្ថាន & យីហោផលិតផល) | | |
| ២២ | នាមករណ៍ | គ្រឹះស្ថាន ឃេស អ៊ិននើវេសិន ម.ក | |
| | អាជ្ញាប័ណ្ណធនាគារជាតិនៃកម្ពុជា | អ.០០២.២០ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០ | |
| | អាសយដ្ឋាន | អាគារលេខ១០៥ ជាន់ទី៤ ផ្លូវ១៩៨៤A សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| | លេខទូរស័ព្ទទំនាក់ទំនង | (+៨៥៥) ៧០ ២២២ ៧០៣ | |
| | សារអេឡិចត្រូនិក | management@kesspay.io | |
| | គេហទំព័រ | kessinnovation.io | |
| | ពាណិជ្ជសញ្ញា (យីហោគ្រឹះស្ថាន & យីហោផលិតផល) | | |
| ២៣ | នាមករណ៍ | គ្រឹះស្ថាន ជីប៊ីស៊ីអាយ វេនឈ័រ ម.ក | |
| | អាជ្ញាប័ណ្ណធនាគារជាតិនៃកម្ពុជា | អ.០០៣.២០ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០ | |
| | អាសយដ្ឋាន | អាគារលេខ B2-033 ផ្លូវកោះពេជ្រ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| | លេខទូរស័ព្ទទំនាក់ទំនង | (+៨៥៥) ៧០ ៣៣៣ ៥៣០ | |
| | សារអេឡិចត្រូនិក | kh@gbci.vc | |
| | គេហទំព័រ | www.fincy.com | |
| | ពាណិជ្ជសញ្ញា (យីហោគ្រឹះស្ថាន & យីហោផលិតផល) | | |
| ២៤ | នាមករណ៍ | គ្រឹះស្ថាន អិលអឹម ផេ ម.ក | |
| | អាជ្ញាប័ណ្ណធនាគារជាតិនៃកម្ពុជា | អ.០០៤.២០ ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០ | |
| | អាសយដ្ឋាន | អគារលេខ៦៣៥ ជាន់ទី២ មហាវិថីព្រះមុន្នីវង្ស សង្កាត់បឹងកេងកង៣ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| | លេខទូរស័ព្ទទំនាក់ទំនង | (+៨៥៥) ១០ ៨០០ ៦០២ / ១០ ៥៣៣ ៨៨៨ | |
| | សារអេឡិចត្រូនិក | lmpay@lmpayplc.com | |
| | គេហទំព័រ | Lmpay.com | |
| | ពាណិជ្ជសញ្ញា (យីហោគ្រឹះស្ថាន & យីហោផលិតផល) | | |

| ល.រ | គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ | | |
|---|---|---|---|
| ២៥ | នាមករណ៍ | គ្រឹះស្ថាន តាំងគួង ផេ ម.ក | |
| | អាជ្ញាប័ណ្ណធនាគារជាតិនៃកម្ពុជា | អ.០០៥.២០ ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២០ | |
| | អាសយដ្ឋាន | អគារលេខ៩០៩-៩០៩ មហាវិថីព្រះមុន្នីវង្ស សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| | លេខទូរស័ព្ទទំនាក់ទំនង | (+៨៥៥) ៩៩ ២៣៣ ២៣៣ | |
| | សារអេឡិចត្រូនិក | cus1@tangkungpay.com | |
| | គេហទំព័រ | www.tangkungpay.com | |
| | ពាណិជ្ជសញ្ញា (យីហោគ្រឹះស្ថាន & យីហោផលិតផល) | | |
| ២៦ | នាមករណ៍ | គ្រឹះស្ថាន លីន ផេ ផេម៉ិន សឹលូសិន ម.ក | |
| | អាជ្ញាប័ណ្ណធនាគារជាតិនៃកម្ពុជា | អ.០០៦.២០ ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២០ | |
| | អាសយដ្ឋាន | ផ្ទះលេខ៩០-៩២&៩៤ ជាន់ទី១ (E1) ផ្លូវលេខ២១៧ សង្កាត់អូឬស្សីទី៤ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| | លេខទូរស័ព្ទទំនាក់ទំនង | (+៨៥៥) ៩៦ ៦៧៥ ៣៥៥៤ | |
| | សារអេឡិចត្រូនិក | មិនមាន | |
| | គេហទំព័រ | www.lync-pay.com | |
| | ពាណិជ្ជសញ្ញា (យីហោគ្រឹះស្ថាន & យីហោផលិតផល) | | |
| ២៧ | នាមករណ៍ | គ្រឹះស្ថាន យូ-ផេ ឌីជីថល ម.ក | |
| | អាជ្ញាប័ណ្ណធនាគារជាតិនៃកម្ពុជា | អ.០០៧.២០ ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២០ | |
| | អាសយដ្ឋាន | អាគារលេខ១ ផ្លូវលេខ៣១០ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| | លេខទូរស័ព្ទទំនាក់ទំនង | (+៨៥៥) ៨១ ៩៧៨ ៨៨៩ / ៨៥ ៩៧៨ ៨៨៩ | |
| | សារអេឡិចត្រូនិក | inquiry@u-pay.com | |
| | គេហទំព័រ | www.u-pay.com | |
| | ពាណិជ្ជសញ្ញា (យីហោគ្រឹះស្ថាន & យីហោផលិតផល) | | |
| ២៨ | នាមករណ៍ | គ្រឹះស្ថាន ស្ការផេ ហ្វីនផេក ម.ក | |
| | អាជ្ញាប័ណ្ណធនាគារជាតិនៃកម្ពុជា | អ.០០៨.២០ ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២០ | |
| | អាសយដ្ឋាន | ដីឡូត៍លេខ ២៧៨៧ ភូមិទួលក្រសាំង ឃុំកាខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល ព្រះរាជាណាចក្រកម្ពុជា | |
| | លេខទូរស័ព្ទទំនាក់ទំនង | (+៨៥៥) ៨១ ៩១៦ ១០៩ | |
| | សារអេឡិចត្រូនិក | មិនមាន | |
| | គេហទំព័រ | មិនមាន | |
| | ពាណិជ្ជសញ្ញា (យីហោគ្រឹះស្ថាន & យីហោផលិតផល) | | |

# ឧបសម្ព័ន្ធ៤ - គ្រឹះស្ថានផ្តល់សេវាធនាគារអេឡិចត្រូនិក

## ១. គ្រឹះស្ថានផ្តល់សេវាធនាគារអ៊ីនធឺណិត

| ល.រ | គ្រឹះស្ថានផ្តល់សេវាធនាគារអ៊ីនធឺណិត | ល.រ | គ្រឹះស្ថានផ្តល់សេវាធនាគារអ៊ីនធឺណិត |
|---|---|---|---|
| ១ | ធនាគារ វឌ្ឍនៈ អាស៊ី ចំកាត់ | ១៩ | ធនាគារ គូកមីន កម្ពុជា ភីអិលស៊ី |
| ២ | ធនាគារ អេស៊ីលីដា ភីអិលស៊ី | ២០ | ធនាគារ មេហ្គា អ៊ីនធើណេសិនណល ខមមើសល |
| ៣ | ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក | ២១ | ធនាគារ មីហ្សូហូ អិលធីឌី |
| ៤ | ធនាគារ ចិន (ហុងកុង) លីមីធីត សាខាភ្នំពេញ | ២២ | ធនាគារ មេយប៊ែង (ខេមបូឌា) ម.ក |
| ៥ | ធនាគារ ប្រេដ ប៊ែង (ខេមបូឌា) ភីអិលស៊ី | ២៣ | ធនាគារ ភ្នំពេញពាណិជ្ជ ម.ក |
| ៦ | ធនាគារ កម្ពុជាអាស៊ី ចំកាត់ | ២៤ | ធនាគារ ហ្វីលីព ភីអិលស៊ី |
| ៧ | ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី | ២៥ | ធនាគារ ព្រីនស៍ ម.ក |
| ៨ | ធនាគារ ជីប ម៉ុង ខមមើសល ប៊ែង ម.ក | ២៦ | ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក |
| ៩ | ធនាគារ កាណាឌីយ៉ា ក.អ | ២៧ | ធនាគារ សាខមប៊ែង (ខេមបូឌា) ភីអិលស៊ី |
| ១០ | ធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី | ២៨ | ធនាគារ ស្ថាបនា ភីអិលស៊ី |
| ១១ | សាជីវកម្មធនាគារ កាថេយូណៃធីតកម្ពុជា ចំកាត់ | ២៩ | ធនាគារ សែហ្គូន-ហាណូយ កម្ពុជា ភីអិលស៊ី |
| ១២ | ធនាគារ ពាណិជ្ជទីមួយ សាខាភ្នំពេញ | ៣០ | ធនាគារ ស៊ិនហាន (ខេមបូឌា) ម.ក |
| ១៣ | ធនាគារ ពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា | ៣១ | ធនាគារ តៃវ៉ាន់ ខូអបភើរេធីវ សាខាភ្នំពេញ |
| ១៤ | ធនាគារ ហត្ថា ម.ក | ៣២ | ធនាគារ សហពាណិជ្ជ ក.អ |
| ១៥ | ធនាគារ ហុងលីអុង (ខេមបូឌា) ភីអិលស៊ី | ៣៣ | ធនាគារ វឌ្ឍនៈ |
| ១៦ | ធនាគារ អ៊ិនដាសស្ទៀល ប៊ែង អហ្វ ខូរៀ ភ្នំពេញ | ៣៤ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី |
| ១៧ | ធនាគារ អាយស៊ីប៊ីស៊ី លីមីធីត សាខាភ្នំពេញ | ៣៥ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ប្រាសាក់ ម.ក |
| ១៨ | ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក | | |

## ២. គ្រឹះស្ថានផ្ដល់សេវាធនាគារចល័ត

| ល.រ | គ្រឹះស្ថានផ្ដល់សេវាធនាគារចល័ត | ល.រ | គ្រឹះស្ថានផ្ដល់សេវាធនាគារចល័ត |
|---|---|---|---|
| ១ | ធនាគារ វឌ្ឍនៈ អាស៊ី ចំកាត់ | ១៦ | ធនាគារ ភ្នំពេញពាណិជ្ជ ម.ក |
| ២ | ធនាគារ ប៊ី.អាយ.ស៊ី (ខេមបូឌា) ប៊ែង ម.ក | ១៧ | ធនាគារ ហ្វីលីព ភីអិលស៊ី |
| ៣ | ធនាគារវិនិយោគ និងអភិវឌ្ឍន៍ កម្ពុជា ភីអិលស៊ី | ១៨ | ធនាគារ ប្រៃសណីយ៍ កម្ពុជា ក.អ |
| ៤ | ធនាគារ ចិន (ហុងកុង) លីមីធីត សាខាភ្នំពេញ | ១៩ | ធនាគារ ព្រីនស៍ ម.ក |
| ៥ | ធនាគារ ប្រេដ ប៊ែង (ខេមបូឌា) ភីអិលស៊ី | ២០ | ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក |
| ៦ | ធនាគារ កម្ពុជាអាស៊ី ចំកាត់ | ២១ | ធនាគារ សាខមប៊ែង (ខេមបូឌា) ភីអិលស៊ី |
| ៧ | ធនាគារពាណិជ្ជ ឈីហ្វ (ខេមបូឌា) ម.ក | ២២ | ធនាគារ ស្ថាបនា ភីអិលស៊ី |
| ៨ | ធនាគារ ជីប ម៉ុង ខមមើសល ប៊ែង ម.ក | ២៣ | ធនាគារ អេស ប៊ី អាយ លីហ្សូ ម.ក |
| ៩ | ធនាគារ កាណាឌីយ៉ា ក.អ | ២៤ | ធនាគារ ស៊ិនហាន (ខេមបូឌា) ម.ក |
| ១០ | ធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី | ២៥ | ធនាគារ សហពាណិជ្ជ ក.អ |
| ១១ | ធនាគារ ពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា | ២៦ | ធនាគារ វឌ្ឍនៈ |
| ១២ | ធនាគារ ហត្ថា ម.ក | ២៧ | ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី |
| ១៣ | ធនាគារ ហុងលីអុង (ខេមបូឌា) ភីអិលស៊ី | ២៨ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី |
| ១៤ | ធនាគារ អាយស៊ីប៊ីស៊ី លីមីធីត សាខាភ្នំពេញ | ២៩ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ដាប់ប៊ែលយូប៊ី ហ្វាយនែន ឯ.ក |
| ១៥ | ធនាគារ មេយប៊ែង (ខេមបូឌា) ម.ក | | |

## ឧបសម្ព័ន្ធ៥ - លំហូរប្រតិបត្តិការរបស់ប្រព័ន្ធទូទាត់សងប្រាក់

**ប្រព័ន្ធផាត់ទាត់ជាតិ - ប្រតិបត្តិការផាត់ទាត់ និងទូទាត់មូលប្បទានបត្រ**




១. អតិថិជន A បញ្ជូនមូលប្បទានបត្ររបស់អតិថិជន B ដែលមានគណនីនៅធនាគារ B ទៅបញ្ញរធនាគារខ្លួន (ធនាគារ A) ដើម្បីដាក់ប្រាក់ចូលគណនីរបស់ខ្លួន

២. ធនាគារ A ទទួលមូលប្បទានបត្រ និងបញ្ចូលទិន្នន័យរបស់មូលប្បទានបត្រនោះទៅក្នុងប្រព័ន្ធផាត់ទាត់ជាតិ

៣. ប្រព័ន្ធផាត់ទាត់ជាតិបញ្ជូនទិន្នន័យនៃមូលប្បទានបត្រដែលទទួលបានទៅកាន់ធនាគារទទួល (ធនាគារ B)

៤. មូលប្បទានបត្រនឹងត្រូវបញ្ជូនមកដោះដូរនៅមណ្ឌលដោះដូរមូលប្បទានបត្ររបស់សភាផាត់ទាត់ជាតិ

៥. ធនាគារ B នឹងពិនិត្យសមតុល្យរបស់អតិថិជន B បន្ទាប់ពីទទួលបានទិន្នន័យពីធនាគារ A

៦. ប្រសិនបើអតិថិជន B មានសមតុល្យគ្រប់គ្រាន់ នោះធនាគារ B នឹងដកចំនួនប្រាក់តាមមូលប្បទានបត្រដែលបានទទួលពីគណនីអតិថិជន B ដើម្បីធ្វើការទូទាត់ឱ្យអតិថិជន A ដែលមានគណនីនៅធនាគារ A

៧. ប្រសិនបើគ្មានការបង្វិលវិញនៃមូលប្បទានបត្រ សភាផាត់ទាត់ជាតិនឹងធ្វើការផាត់ទាត់និងទូទាត់ប្រតិបត្តិការ រវាងធនាគារA និងធនាគារ B

៨. ធនាគារ A ចុះឥណទានគណនីអតិថិជន A

៩. ប្រសិនបើអតិថិជន B ពុំមានសមតុល្យគ្រប់គ្រាន់ឬមូលប្បទានបត្រពុំអាចធ្វើការទូទាត់បានដោយមូលហេតុណាមួយក្នុងចំណោមមូលហេតុនៃមូលប្បទានបត្របង្វិលវិញនោះ ធនាគារ B ត្រូវបញ្ជូនមូលប្បទានបត្រនោះ ត្រឡប់ទៅឱ្យធនាគារ A ដើម្បីប្រគល់ឱ្យអតិថិជន A វិញ។

ក្នុងករណីនេះ សភាផាត់ទាត់ត្រូវផាត់ទាត់ (គណនា Net Position) រវាងធនាគារ A និងធនាគារ B ឡើងវិញ សម្រាប់ធ្វើការទូទាត់ដោយដកចេញមូលប្បទានបត្រដែលមិនអាចទូទាត់បាន។

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**ប្រព័ន្ធផាត់ទាត់ជាតិ - ប្រតិបត្តិការបញ្ជាផ្ទេរឥណទានជាអេឡិចត្រូនិក**




១. អតិថិជន A បញ្ជូនបញ្ជាទូទាត់តាមរយៈធនាគាររបស់ខ្លួន (ធនាគារ A) ដើម្បីផ្ទេរប្រាក់ឱ្យអតិថិជន B ដែលមានគណនីនៅធនាគារ B

២. ធនាគារ A នឹងពិនិត្យសមតុល្យគណនីនិងភាពត្រឹមត្រូវនៃបញ្ជាទូទាត់របស់អតិថិជន A ប្រសិនបើត្រឹមត្រូវ ធនាគារ A និងដកប្រាក់ពីគណនីអតិថិជន A ដើម្បីត្រៀមទូទាត់ឱ្យអតិថិជន B ដែលមានគណនីនៅធនាគារ B

៣. ធនាគារ A បញ្ចូលទិន្នន័យនៃបញ្ជាទូទាត់នោះទៅក្នុងប្រព័ន្ធផាត់ទាត់ជាតិ

៤. ប្រព័ន្ធផាត់ទាត់ជាតិនឹងបញ្ជូនទិន្នន័យនៃបញ្ជាទូទាត់ដែលទទួលបានទៅកាន់ធនាគារ B

៥. បន្ទាប់ពីទទួលបានបញ្ជាទូទាត់ពីធនាគារ A ធនាគារ B នឹងពិនិត្យពីភាពត្រឹមត្រូវនៃបញ្ជាទូទាត់នោះ ដើម្បីត្រៀមដាក់ប្រាក់ (ចុះឥណទាន) ក្នុងគណនីអតិថិជន B តាមចំនួនប្រាក់លើបញ្ជាទូទាត់នោះ

៦. សភាផាត់ទាត់ជាតិនឹងធ្វើការផាត់ទាត់និងទូទាត់ប្រតិបត្តិការ រវាងធនាគារ A និងធនាគារ B

៧. បន្ទាប់ពីការទូទាត់រវាងធនាគារ A និងធនាគារ B បានបញ្ចប់ ធនាគារ B នឹងដាក់ប្រាក់(ចុះឥណទាន) ចូលគណនីអតិថិជន B តាមចំនួនប្រាក់នៃបញ្ជាទូទាត់។

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

ប្រព័ន្ធសេវាទូទាត់រហ័ស - ប្រតិបត្តិការតាមបញ្ជរគ្រឹះស្ថាន




១. អតិថិជន A ទៅកាន់បញ្ជរធនាគាររបស់ខ្លួនគឺធនាគារ A ដើម្បីផ្ទេរប្រាក់ឱ្យអតិថិជន B ដែលមានគណនីនៅធនាគារ B

២. ធនាគារ A ពិនិត្យសមតុល្យគណនីរបស់អតិថិជន A ប្រសិនបើមានសមតុល្យគ្រប់គ្រាន់ នោះធនាគារ A នឹងបញ្ចូលទិន្នន័យនៃបញ្ជាផ្ទេរប្រាក់នោះទៅក្នុងប្រព័ន្ធសេវាទូទាត់រហ័ស

៣. ធនាគារ A នឹងកាត់ប្រាក់ (ចុះឥណពន្ធ) ពីគណនីអតិថិជន A ដើម្បីត្រៀមទូទាត់ឱ្យធនាគារ B

៤. ប្រព័ន្ធសេវាទូទាត់រហ័សបញ្ជូនទិន្នន័យនៃបញ្ជាផ្ទេរប្រាក់ដែលទទួលបានទៅកាន់ធនាគារ B

៥. ធនាគារ B នឹងពិនិត្យភាពត្រឹមត្រូវនៃបញ្ជាផ្ទេរប្រាក់

៦. ប្រសិនបើព័ត៌មានគ្រប់គ្រាន់និងត្រឹមត្រូវ ធនាគារ B នឹងដាក់ប្រាក់ (ចុះឥណទាន) ចូលគណនីរបស់អតិថិជន B តាមចំនួនប្រាក់នៃបញ្ជាផ្ទេរប្រាក់នោះ

៧. សភាផាត់ទាត់ជាតិនឹងធ្វើការផាត់ទាត់និងទូទាត់ប្រតិបត្តិការ រវាងធនាគារ A និងធនាគារ B។

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**ប្រព័ន្ធសេវាទូទាត់រហ័ស - ប្រតិបត្តិការតាមកម្មវិធីទូរស័ព្ទរបស់គ្រឹះស្ថាន**




១. អតិថិជន A ត្រូវពិនិត្យសមតុល្យគណនីរបស់ខ្លួន មុនពេលបញ្ជូនបញ្ជាផ្ទេរប្រាក់តាមរយៈកម្មវិធីទូរស័ព្ទរបស់ធនាគារខ្លួន (ធនាគារ A ) ដើម្បីផ្ទេរប្រាក់ឱ្យអតិថិជន B ដែលមានគណនីនៅធនាគារ B

២. ធនាគារ A ពិនិត្យភាពត្រឹមត្រូវរបស់ទិន្នន័យនៃបញ្ជាផ្ទេរប្រាក់ដែលបានបញ្ចូលទៅក្នុងកម្មវិធីទូរស័ព្ទនោះ

៣. បន្ទាប់ពីពិនិត្យមើលភាពត្រឹមត្រូវនៃព័ត៌មានលើបញ្ជាផ្ទេរប្រាក់ និងភាពគ្រប់គ្រាន់នៃសមតុល្យ ធនាគារ A នឹងបញ្ជូនទិន្នន័យនោះទៅកាន់ប្រព័ន្ធសេវាទូទាត់រហ័ស

៤. ធនាគារ A នឹងកាត់ប្រាក់ (ចុះឥណពន្ធ) ពីគណនីរបស់អតិថិជន A ដើម្បីត្រៀមទូទាត់ទៅឱ្យធនាគារ B

៥. ប្រព័ន្ធសេវាទូទាត់រហ័សនឹងបញ្ជូនទិន្នន័យនៃបញ្ជាផ្ទេរប្រាក់ដែលទទួលបានពីធនាគារ A ទៅកាន់ធនាគារ B

៦. ធនាគារ B នឹងពិនិត្យភាពត្រឹមត្រូវលើបញ្ជាផ្ទេរប្រាក់

៧. ប្រសិនបើព័ត៌មានគ្រប់គ្រាន់និងត្រឹមត្រូវ ធនាគារ B នឹងដាក់ប្រាក់ (ចុះឥណទាន) ចូលគណនីរបស់អតិថិជន B តាមចំនួនប្រាក់នៃបញ្ជាផ្ទេរប្រាក់នោះ

៨. សភាផាត់ទាត់ជាតិនឹងធ្វើការផាត់ទាត់និងទូទាត់ប្រតិបត្តិការ រវាងធនាគារ A និងធនាគារ B។

សម្គាល់៖ ករណីនេះសម្រាប់តែគ្រឹះស្ថានសមាជិកដែលបានភ្ជាប់សេវាធនាគារចល័ត ឬសេវាធនាគារអ៊ីនធឺណិតជាមួយប្រព័ន្ធសេវាទូទាត់រហ័សប៉ុណ្ណោះ។

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

ប្រព័ន្ធសេវាទូទាត់រហ័ស - ប្រតិបត្តិការផ្ទេរប្រាក់ តាមរយៈម៉ាស៊ីនអេធីអឹម




១. អតិថិជន A បញ្ចូលប័ណ្ណទូទាត់ទៅក្នុងម៉ាស៊ីន ATM របស់ធនាគារ ACQ រួចវាយ PIN និងជ្រើសរើសប្រភេទប្រតិបត្តិការផ្ទេរប្រាក់ បន្ទាប់មកបញ្ចូលចំនួនប្រាក់ដែលត្រូវផ្ទេរទៅឱ្យអតិថិជន B ដែលមានគណនីនៅធនាគារ Beneficiary

២. ធនាគារ ACQ នឹងពិនិត្យមើលភាពត្រឹមត្រូវនៃបញ្ជាផ្ទេរប្រាក់នោះ រួចបញ្ជូនទៅកាន់ប្រព័ន្ធសេវាទូទាត់រហ័ស

៣. ប្រព័ន្ធសេវាទូទាត់រហ័ស នឹងបញ្ជូនបញ្ជាផ្ទេរប្រាក់ដែលទទួលបានទៅកាន់ធនាគារ ISS

៤. ធនាគារ ISS នឹងបញ្ជាក់ពីភាពត្រឹមត្រូវនៃបញ្ជាផ្ទេរប្រាក់ដោយបញ្ជូនការបញ្ជាក់នោះទៅកាន់ធនាគារ ACQ តាមរយៈប្រព័ន្ធសេវាទូទាត់រហ័ស

៥. ស្របពេលជាមួយគ្នានេះ ប្រព័ន្ធសេវាទូទាត់រហ័ស នឹងបញ្ជូនDeposit advice messageទៅធនាគារ Beneficiary

៦. ធនាគារ ACQ អនុញ្ញាតឱ្យអតិថិជន A ផ្ទេរប្រាក់ដោយជោគជ័យ បន្ទាប់មកម៉ាស៊ីន ATM បោះផ្សាយវិក្កយបត្រសម្រាប់អតិថិជន

៧. ធនាគារ IS S នឹងដកប្រាក់ចេញពីគណនីអតិថិជន A

៨. ធនាគារ Beneficiary នឹងដាក់ប្រាក់ចូលទៅក្នុងគណនីរបស់អតិថិជន B តាមចំនួនប្រាក់នៃបញ្ជាផ្ទេរប្រាក់

៩. សភាផាត់ទាត់ជាតិនឹងធ្វើការផាត់ទាត់និងទូទាត់ប្រតិបត្តិការ រវាងធនាគារ ACQ , ធនាគារ ISS និងធនាគារ Beneficiary។

<u>សម្គាល់៖</u> - ធនាគារ ISS សំដៅលើសមាជិកដែលមានគណនីអ្នកកាន់ប័ណ្ណ និងចេញផ្សាយប័ណ្ណទៅឱ្យអ្នកកាន់ប័ណ្ណ។

- ធនាគារ ACQ សំដៅលើសមាជិកជាម្ចាស់ ATM ឬ POS។

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

ប្រព័ន្ធខេមប៊ូឌានស៊ែស្វីច - ប្រតិបត្តិការដកសាច់ប្រាក់




១. អតិថិជន A បញ្ចូលបណ្ណទូទាត់ទៅក្នុងម៉ាស៊ីន ATM /POS របស់ធនាគារ ACQ រួចវាយ PIN និងជ្រើសរើសប្រភេទប្រតិបត្តិការដកប្រាក់ បន្ទាប់មកត្រូវវាយចំនួនប្រាក់ដែលត្រូវដក

២. ធនាគារ ACQ នឹងពិនិត្យមើលភាពត្រឹមត្រូវនៃបញ្ជាដកប្រាក់នោះ រួចបញ្ជូនទៅកាន់ប្រព័ន្ធ CSS

៣. ប្រព័ន្ធ CSS នឹងបញ្ជូនបញ្ជាដកប្រាក់ដែលទទួលបានពីធនាគារ ACQ ទៅកាន់ធនាគារ ISS

៤. ធនាគារ ISS នឹងបញ្ជាក់ពីភាពត្រឹមត្រូវនៃបញ្ជាផ្ទេរប្រាក់ រួចបញ្ជូនការបញ្ជាក់ពីភាពត្រឹមត្រូវទៅកាន់ធនាគារ ACQ វិញតាមរយៈប្រព័ន្ធ CSS

៥. ធនាគារ ISS នឹងដកប្រាក់ពីគណនីរបស់អតិថិជន A តាមចំនួនប្រាក់នៃបញ្ជាដកប្រាក់

៦. ធនាគារ ACQ អនុញ្ញាតឱ្យអតិថិជន A ដកប្រាក់

៧. ម៉ាស៊ីន ATM/POS បោះផ្សាយវិក្កយបត្រសម្រាប់អតិថិជន

៨. សភាផាត់ទាត់ជាតិនឹងធ្វើការផាត់ទាត់និងទូទាត់ប្រតិបត្តិការរវាងធនាគារ ACQ និងធនាគារ ISS។

<u>សម្គាល់៖</u> - ធនាគារ ISS សំដៅលើសមាជិកដែលមានគណនីអ្នកកាន់បណ្ណ និងចេញផ្សាយប័ណ្ណទៅឱ្យអ្នកកាន់បណ្ណ។

- ធនាគារ ACQ សំដៅលើសមាជិកជាម្ចាស់ ATM ឬ POS។

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

ប្រព័ន្ធខេមប៊ូខានស៊ែស្វីច - ប្រតិបត្តិការពិនិត្យសមតុល្យ




១. អតិថិជន A ស៊កប័ណ្ណទូទាត់ទៅក្នុងម៉ាស៊ីន ATM របស់ធនាគារ ACQ បន្ទាប់មកបញ្ចូល PIN រួចជ្រើសរើសយកប្រតិបត្តិការពិនិត្យសមតុល្យគណនី

២. ធនាគារ ACQ នឹងពិនិត្យមើលភាពត្រឹមត្រូវនៃសំណើពិនិត្យសមតុល្យ រួចបញ្ជូនទៅកាន់ប្រព័ន្ធ CSS

៣. ប្រព័ន្ធ CSS នឹងបញ្ជូនសំណើពិនិត្យសមតុល្យដែលទទួលបានទៅកាន់ធនាគារ ISS

៤. ធនាគារ ISS នឹងបញ្ជូនព័ត៌មានសមតុល្យគណនីរបស់អតិថិជន A មកធនាគារ ACQ តាមរយៈប្រព័ន្ធ CSS

៥. ធនាគារ ACQ នឹងបង្ហាញព័ត៌មានលម្អិតនៃសមតុល្យគណនីនោះ នៅលើអេក្រង់ម៉ាស៊ីន ATM។

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

ប្រព័ន្ធខេមប៊ូខាន់ស៊ែស្វីច - ប្រតិបត្តិការប្តូរលេខសម្ងាត់




១. អតិថិជន A ស៊កបញ្ចូលប័ណ្ណទូទាត់ទៅក្នុងម៉ាស៊ីន ATM របស់ធនាគារ ACQ បន្ទាប់មកបញ្ចូល PIN រួចជ្រើសរើសយកប្រតិបត្តិការប្តូរលេខសម្ងាត់

២. ធនាគារ ACQ នឹងពិនិត្យមើលភាពត្រឹមត្រូវនៃសំណើសុំប្តូរលេខសម្ងាត់ រួចបញ្ជូនទៅកាន់ប្រព័ន្ធ CSS

៣. ប្រព័ន្ធ CSS នឹងបញ្ជូនសំណើសុំប្តូរលេខសម្ងាត់ដែលទទួលបានទៅកាន់ធនាគារ ISS

៤. ធនាគារ ISS នឹងបញ្ជាក់ពីភាពត្រឹមត្រូវនៃសំណើសុំប្តូរលេខសម្ងាត់ រួចបញ្ជូនការបញ្ជាក់នោះ មកកាន់ធនាគារ ACQ តាមរយៈប្រព័ន្ធ CSS តាមជំហាននីមួយៗ

៥. អតិថិជនត្រូវធ្វើតាមការណែនាំដែលមាននៅលើអេក្រង់ម៉ាស៊ីន ATM ដើម្បីផ្លាស់ប្តូរលេខសម្ងាត់។

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**ប្រព័ន្ធខេមប៊ុខានស៊ែស្វីច - ប្រតិបត្តិការពិនិត្យរបាយការណ៍សង្ខេប**




១. អតិថិជន A ស៊ិកប័ណ្ណទូទាត់ទៅក្នុងម៉ាស៊ីន ATM របស់ធនាគារ ACQ បន្ទាប់មកបញ្ចូល PIN រួចជ្រើសរើសយកប្រតិបត្តិការពិនិត្យរបាយការណ៍សង្ខេប

២. ធនាគារ ACQ នឹងពិនិត្យមើលភាពត្រឹមត្រូវនៃសំណើសុំពិនិត្យរបាយការណ៍សង្ខេបរួចបញ្ជូនទៅកាន់ប្រព័ន្ធ CSS

៣. ប្រព័ន្ធ CSS នឹងបញ្ជូនសំណើសុំពិនិត្យរបាយការណ៍សង្ខេបដែលទទួលបានទៅកាន់ធនាគារ ISS

៤. ធនាគារ ISS នឹងបញ្ជូនរបាយការណ៍សង្ខេបនោះទៅកាន់ធនាគារ ACQ វិញតាមរយៈប្រព័ន្ធ CSS

៥. ធនាគារ ACQ នឹងបង្ហាញរបាយការណ៍សង្ខេបនោះលើអេក្រង់ម៉ាស៊ីន ATM បន្ទាប់មកម៉ាស៊ីន ATM បោះផ្សាយរបាយការណ៍សង្ខេបសម្រាប់អតិថិជន A។

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

ប្រព័ន្ធខេមប៊ិខានស៊ែស្វិច - ប្រតិបត្តិការទូទាត់ទំនិញ




១. ភ្នាក់ងារអាជីវកម្ម (Merchant) ស៊កប័ណ្ណទូទាត់របស់អតិថិជនទៅក្នុងម៉ាស៊ីន POS របស់ខ្លួន បន្ទាប់មកបញ្ចូលចំនួនប្រាក់ដែលអតិថិជន A ត្រូវទូទាត់និងស្នើសុំឱ្យអតិថិជនបញ្ចូល PIN រួចបញ្ជូនមកធនាគារ ACQ

២. ធនាគារ ACQ នឹងពិនិត្យមើលភាពត្រឹមត្រូវនៃបញ្ជាទូទាត់នោះរួចបញ្ជូនទៅកាន់ប្រព័ន្ធ CSS

៣. ប្រព័ន្ធ CSS នឹងបញ្ជូនទិន្នន័យនៃបញ្ជាទូទាត់ដែលទទួលបានពីធនាគារ ACQ ទៅកាន់ធនាគារ ISS

៤. ធនាគារ ISS នឹងបញ្ជាក់ពីភាពត្រឹមត្រូវនៃបញ្ជាទូទាត់នោះ រួចបញ្ជូនការបញ្ជាក់ពីភាពត្រឹមត្រូវនោះទៅកាន់ធនាគារ ACQ វិញ តាមរយៈប្រព័ន្ធ CSS

៥. ធនាគារ ACQ អនុញ្ញាតឱ្យអតិថិជន A ធ្វើការទូទាត់

៦. ធនាគារ ISS នឹងដកប្រាក់ពីគណនីរបស់អតិថិជន A តាមចំនួនប្រាក់នៃបញ្ជាទូទាត់ដើម្បីត្រៀមទូទាត់ឱ្យ Merchant ដែលមានគណនីនៅធនាគារ ACQ

៧. ម៉ាស៊ីន POS នឹងបោះផ្សាយវិក្កយប័ត្រប្រតិបត្តិការនោះសម្រាប់អតិថិជន

៨. សភាផាត់ទាត់ជាតិនឹងធ្វើការផាត់ទាត់និងទូទាត់ប្រតិបត្តិការ រវាងធនាគារ ISS និងធនាគារ ACQ

៩. ធនាគារ ACQ នឹងដាក់ប្រាក់ (ចុះឥណទាន) ក្នុងគណនីរបស់ Merchant នៅថ្ងៃបន្ទាប់។

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**ប្រព័ន្ធរីធែលផេ - ប្រតិបត្តិការផ្ទេរប្រាក់នៃ RFT - Real Time Fund Transfer**




១. អតិថិជន A ទៅកាន់ធនាគាររបស់ខ្លួន (ធនាគារ A) ឬតាមរយៈទូរស័ព្ទចល័ត ដើម្បីផ្ទេរប្រាក់ទៅកាន់អតិថិជន B ដែលមានគណនីនៅធនាគារ B

២. ធនាគារ A នឹងពិនិត្យមើល ភាពត្រឹមត្រូវនៃបញ្ជាផ្ទេរប្រាក់ នឹងកាត់ចំនួនប្រាក់ដែលត្រូវផ្ទេរ (ចុះឥណពន្ធ) ពីគណនីអតិថិជន A រួចបញ្ជូនបញ្ជាផ្ទេរប្រាក់ទៅកាន់ប្រព័ន្ធ Retail Pay

៣. ប្រព័ន្ធ Retail Pay នឹងបញ្ជូនបញ្ជាផ្ទេរប្រាក់ដែលទទួលបានទៅកាន់ធនាគារ B

៤. ធនាគារ B នឹងពិនិត្យមើលពីភាពត្រឹមត្រូវនៃបញ្ជាផ្ទេរប្រាក់ ប្រសិនបើត្រឹមត្រូវ ធនាគារ B នឹងដាក់ប្រាក់ (ចុះឥណទាន) ចូលក្នុងគណនីរបស់អតិថិជន B ភ្លាមៗ

៥. ធនាគារ B នឹងបញ្ជាក់ពីភាពជោគជ័យនៃប្រតិបត្តិការទៅធនាគារ A វិញតាមប្រព័ន្ធ RFT

៦. Electronic Clearing System (ECS) នៃប្រព័ន្ធរីធែលផេ នឹងផាត់ទាត់ប្រតិបត្តិការទាំងនោះ បន្ទាប់មកបញ្ជូនលទ្ធផលផាត់ទាត់សរុបទៅកាន់ប្រព័ន្ធ Core Banking ដើម្បីទូទាត់

សម្គាល់ ៖ តាមរយៈការប្រើប្រាស់ប្រព័ន្ធ RFT អតិថិជនអាចផ្ទេរប្រាក់បាន ១)ពីគណនីទៅគណនី និង ២)ពីគណនីទៅលេខទូរស័ព្ទ។ ករណីនៃការផ្ទេរប្រាក់ពីគណនីទៅលេខទូរស័ព្ទ អតិថិជនទទួលត្រូវបង្ហាញអត្តសញ្ញាណរបស់ខ្លួន លេខទូរស័ព្ទរបស់ខ្លួន លេខទូរស័ព្ទអ្នកផ្ញើ និងលេខសម្គាល់ OTP ដែលទទួលបានពីអតិថិជនផ្ញើ នៅពេលទៅដកប្រាក់ នៅតាមគ្រឹះស្ថានជាសមាជិកនៃប្រព័ន្ធ RFT ណាមួយ។

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**ប្រព័ន្ធបាគង - លក្ខណៈ Backbone**





- អ្នកផ្ញើរ បញ្ជូនបញ្ជាផ្ញើរទៅធនាគារអ្នកផ្ញើរ (ឧ. តាមបណ្តាញធនាគារ ឬធនាគារអេឡិចត្រូនិក)
- ធនាគារអ្នកផ្ញើរ ពិនិត្យអត្តសញ្ញាណរបស់អ្នកផ្ញើរ និងចំនួនមូលនិធិនៅក្នុងគណនីធនាគារ
- ធនាគារអ្នកផ្ញើរ នឹងបញ្ជូនបញ្ជាផ្ញើរទៅប្រព័ន្ធបាគង ប្រសិនគណនីរបស់អ្នកផ្ញើរមានមូលនិធិគ្រប់គ្រាន់

- បញ្ជាផ្ញើរត្រូវបានទទួល និងផ្ទៀងផ្ទាត់
- ប្រតិបត្តិការត្រូវបានទូទាត់

- មូលនិធិ ត្រូវបានផ្ញើរចូលក្នុងគណនីធនាគាររបស់អ្នកទទួល
- ផ្ទៀងផ្ទាត់ព័ត៌មាន ក្នុងចំណោម Nodes
- ធនាគារអ្នកផ្ញើរ និងធនាគារអ្នកទទួល នឹងទទួលបានព័ត៌មានអំពី ប្រតិបត្តិការទូទាត់ជោគជ័យ

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**ប្រព័ន្ធបាគង - លក្ខណៈ Extended**




- អ្នកផ្ញើរ បញ្ជូនបញ្ជាផ្ទេរតាម BAKONG App
- ធនាគារអ្នកផ្ញើរ ពិនិត្យអត្តសញ្ញាណរបស់អ្នកផ្ញើរ និងចំនួនមូលនិធិនៅក្នុងគណនីធនាគារ
- ធនាគារអ្នកផ្ញើរ នឹងបញ្ជូនបញ្ជាផ្ទេរ និងព័ត៌មានទៅប្រព័ន្ធបាគង ប្រសិនមូលនិធិរបស់អ្នកផ្ញើរមានគ្រប់គ្រាន់

- បញ្ជាផ្ទេរត្រូវបានទទួល និងផ្ទៀងផ្ទាត់
- ប្រតិបត្តិការត្រូវបានទូទាត់

- មូលនិធិ ត្រូវបានផ្ទេរចូលគណនីបាគងរបស់អ្នកទទួល
- ធនាគារអ្នកផ្ញើរ និងធនាគារអ្នកទទួល នឹងទទួលបានព័ត៌មានអំពីប្រតិបត្តិការទូទាត់ជោគជ័យ

ប្រភព ៖ ធនាគារជាតិនៃកម្ពុជា


@Mardy Suong